







# គម្រោងអភិបាលកិច្ចសុខភាពភ្នែក

# Eye Health Governance Project

July 2026 - June 2031

# គម្រោង

# អភិបាលកិច្ចសុខភាពភ្នែក

## (Eye Health Governance)

កក្កដា ២០២៦-មិថុនា ២០៣១

## ព្រះរាជាណាចក្រកម្ពុជា

**KH26-01**

## មាតិកា


i. សង្ខេបគម្រោង ..... 3

ii. អក្សរកាត់ ..... 7

1.1 ការវិភាគស្ថានភាព និងបរិបទ ..... 9

1.1.1 សាវតា និងបរិបទ ..... 9

1.1.2 ការវិភាគបញ្ហា និងភ័ស្តុតាង ..... 10

1.1.3 ការវិភាគស្ថានភាពសមធម៌ ..... 12

1.1.4 ការវិភាគភាគីពាក់ព័ន្ធ ..... 14

1.1.5 គុណតម្លៃរួមចំណែកបន្ថែមពីមូលនិធិហ្វ្រេដហូឡូ ..... 17

2. អំពីគម្រោង ..... 19

2.1 គោលបំណង និងសមិទ្ធផលរំពឹងទុក ..... 19

2.2 សមិទ្ធផល និងលទ្ធផលរំពឹងទុក ..... 20

2.3 សេចក្តីសន្ទត់ និងយុទ្ធសាស្ត្រ ..... 23

2.4 សមធម៌ និងបរិយាបន្ន ..... 28

2.5 អ្នកទទួលផល ..... 30

2.6 ភាពស៊ីសង្វាក់គ្នាផ្នែកយុទ្ធសាស្ត្រ ..... 32

3. ការអនុវត្តគម្រោង ..... 35

3.1 ការគ្រប់គ្រងគម្រោង ..... 35

3.2 និរន្តរភាព ..... 38

3.3 ក្របខ័ណ្ឌផែនការសកម្មភាព និងថិរវេលានៃគម្រោង ..... 41

3.4 ថវិកាសរុបសម្រាប់រយៈពេលអនុវត្តគម្រោង ..... 49

4. Monitoring, Evaluation, Research and Learning ..... 51

4.1 M&E Plan ..... 51

4.2 Planned Evaluations Table ..... 54

4.3 Key Evaluation Questions ..... 56

4.4 ការសិក្សាស្រាវជ្រាវ ..... 57

# i. សង្ខេបគម្រោង

| | | | |
|---|---|---|---|
| ឈ្មោះគម្រោង | អភិបាលកិច្ចសុខភាពភ្នែក | | |
| កូដគម្រោង | KH26-01 | | |
| រយៈពេល | កាលបរិច្ឆេទចាប់ផ្តើម<br>កក្កដា ២០២៦ | កាលបរិច្ឆេទបញ្ចប់<br>មិថុនា ២០៣១ | រយៈពេល៖ ប្រាំឆ្នាំ |
| គ្រោងថវិកា | ដុល្លាអាមេរិក (USD) | ៥.៦៥២.៦២៧ | |
| | ដុល្លាអូស្ត្រាលី (*AUD*) | ៨.១៩២.២១៣ | |
| គ្រោងថវិកាបាន អនុម័ត | ប្រភពថវិកា: រដ្ឋាភិបាលអូស្ត្រាលី | ចំនួន: ៤.០០០.០០០ ដុល្លាអាមេរិក | |
| | ប្រភពថវិកា:<br>ជាវិភាគទានពី មូលនិធិហ្វ្រេដហូឡូ | ចំនួន: ១.៦៥២.៦២៧ ដុល្លាអាមេរិក | |
| ពណ៌នាគម្រោង | កម្ពុជា នៅមានប្រជាជនជាច្រើនដែលមិនទាន់ទទួលបានសេវាថែទាំសុខភាពភ្នែកបានទាន់ពេលវេលា និងមានគុណភាពនៅឡើយ ដែលបញ្ហានេះមិនមែនបណ្តាលមកពីកង្វះដំណោះស្រាយនោះទេ ប៉ុន្តែដោយសារប្រព័ន្ធគាំទ្រក្នុងការរៀបចំផែនការ ការសម្របសម្រួល គុណភាព និងគណនេយ្យភាព មិនទាន់មានភាពរឹងមាំ នៅឡើយ។ ទោះបីជាសេវាថែទាំសុខភាពភ្នែកកំពុងមានការរីកចម្រើនក៏ដោយ ប៉ុន្តែគម្លាតនៃគុណភាពសេវា ធនធានមនុស្សផ្នែកសុខភាពភ្នែក និងការសម្របសម្រួលពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៅមានកម្រិត បានធ្វើឱ្យលទ្ធភាពទទួលបានសេវា និងលទ្ធផលទទួលបានមានភាពខុសៗគ្នាទៅតាមតំបន់នីមួយៗ។ គម្រោងអភិបាលកិច្ចសុខភាពភ្នែក (Eye Health Governance Project) ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ តាមរយៈការពង្រឹងការរៀបចំផែនការ ការដឹកនាំនិងការគ្រប់គ្រងសុខភាពភ្នែក ធានាដល់ការវិនិយោគនាពេលបច្ចុប្បន្ន និងពេលអនាគត អាចផ្តល់នូវសមិទ្ធផលកាន់តែប្រសើរ និងមានភាពប្រាកដប្រជាសម្រាប់ប្រជាជនកម្ពុជាទាំងអស់។<br><br>គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់លើប្រជាពលរដ្ឋដែលពឹងផ្អែកលើសេវាសុខាភិបាលសាធារណៈ រួមទាំងអ្នករស់នៅតំបន់ជនបទ និងតំបន់ដែលមិនទាន់ទទួលបានសេវាថែទាំសុខភាពភ្នែកគ្រប់គ្រាន់។ តាមរយៈការកែលម្អ អភិបាលកិច្ច ការចាត់ចែង និងការរៀបចំសេវាថែទាំសុខភាពភ្នែក គម្រោងនេះនឹងជួយដល់គ្រូពេទ្យ គិលានុបដ្ឋាក-យិកា និងបុគ្គលិកថែទាំសុខភាពភ្នែក អាចផ្តល់នូវសេវាថែទាំ ប្រកបដោយសុវត្ថិភាព និងគុណភាពខ្ពស់ ជូនដល់ប្រជាពលរដ្ឋនៅជិតទីលំនៅរបស់ពួកគាត់។ បើទោះបីជា គម្រោងនេះមិនបានផ្តល់សេវាព្យាបាលផ្ទាល់ក៏ដោយ ប៉ុន្តែគម្រោងនឹងពង្រឹងប្រព័ន្ធគាំទ្រដល់ការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាពនៅគ្រប់ខេត្ត-ក្រុង និងគ្រប់កម្រិតនៃការថែទាំ។<br><br>គម្រោងមានគោលបំណងសម្រេចឱ្យបាននូវ ប្រព័ន្ធសុខភាពភ្នែកដែលដឹកនាំដោយរាជរដ្ឋាភិបាល មានភាពធន់ និងមន្ត្រីសុខភាពភ្នែកមានសមត្ថភាពកាន់តែប្រសើរ ក្នុងការរៀបចំផែនការផ្តល់សេវា ការគ្រប់គ្រងធនធានមនុស្ស ការធានាគុណភាព និងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនក្នុងរយៈពេលវែង។ | | | |

<table>
<tr>
<td></td>
<td>សមិទ្ធផលរំពឹងទុក រួមមាន៖<br>1. ពង្រឹងអភិបាលកិច្ច ការសម្របសម្រួល និងការគ្រប់គ្រងវិស័យសុខភាពភ្នែក ដើម្បីធ្វើឱ្យប្រសើរឡើង នូវការរៀបចំផែនការ ការចងក្រងបទប្បញ្ញត្តិ គុណភាពសេវា និងប្រកបដោយការទទួលខុសត្រូវ។<br>2. រៀបចំឱ្យមាន ការអភិវឌ្ឍធនធានមនុស្សសុខភាពភ្នែកជាប្រព័ន្ធ ដែលមានសមត្ថភាព ចីរភាព និងការបែងចែកធនធានមនុស្សផ្នែកសុខភាពភ្នែកប្រកបដោយសមធម៌។<br>3. ពង្រឹងប្រព័ន្ធគាំទ្រ នវានុវត្តន៍(បច្ចេកវិទ្យាច្នៃប្រឌិត) និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រដល់ ការងារអភិបាលកិច្ចរបស់ថ្នាក់ដឹកនាំ ប្រសិទ្ធភាពការងាររបស់មន្ត្រីផ្នែកសុខភាពភ្នែក និងគុណភាពផ្តល់សេវា។<br><br>ការធ្វើឱ្យប្រសើរឡើងនូវកិច្ចការទាំងអស់នេះ នឹងរួមចំណែកដល់ការទទួលបានសេវាថែទាំសុខភាពភ្នែកដែលមានគុណភាព ដោយសមធម៌ និងកាត់បន្ថយការបាត់បង់គំហើញ(ការមើលឃើញ) ដែលអាចជៀសវាងបាន នៅទូទាំងប្រទេសកម្ពុជា។<br><br>គម្រោងនេះនឹងត្រូវអនុវត្ត ដោយមានការសហការភាពជាដៃគូជាមួយស្ថាប័នរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានានៅក្នុងស្រុក ដោយផ្តោតលើការផ្លាស់ប្តូរជាក់ស្តែង និងប្រកបដោយចីរភាព។ តាមរយៈយន្តការអនុវត្តដែលស្របតាមរចនាសម្ព័ន្ធដែលមានស្រាប់ និងអាទិភាពដែលបានកំណត់ដោយរាជរដ្ឋាភិបាល គម្រោងអភិបាលកិច្ចសុខភាពភ្នែកនេះ នឹងគាំទ្រដល់វឌ្ឍនភាព និងភាពជាម្ចាស់ថ្នាក់ជាតិក្នុងវិស័យសុខភាពភ្នែកប្រកបដោយចីរភាព។</td>
</tr>
<tr>
<td>ការផ្តោតលើប្រភេទជំងឺ</td>
<td>
<table>
<tr><th>ជ្រើសរើស</th><th>ប្រភេទជំងឺ ជំងឺដែលត្រូវផ្តោត</th><th>តើគម្រោងផ្តោតលើប្រភេទជំងឺនីមួយៗ ដែលបានជ្រើសរើសក្នុងកម្រិតណា? (សូមបែងចែកជាភាគរយ % ប្រហាក់ប្រហែល និងឱ្យសរុបត្រឹមស្មើ 100%)</th></tr>
<tr><td>☒</td><td>ជំងឺបាយភ្នែក</td><td>10 %</td></tr>
<tr><td>☒</td><td>កំហុសកំណុំរូបភាព</td><td>10 %</td></tr>
<tr><td>☐</td><td>ជំងឺត្រាក់កូម</td><td></td></tr>
<tr><td>☒</td><td>ជំងឺសរសៃរ៉ែទីនបណ្តាលពីជំងឺទឹកនោមផ្អែម និងជំងឺភ្នែកផ្សេងទៀត</td><td>10 %</td></tr>
<tr><td>☒</td><td>ការងារទូទៅមិនផ្ទាល់នឹងជំងឺ (ឧ. គោលនយោបាយ, ធនធានមនុស្ស, បរិយាកាសអំណោយផល)</td><td>70 %</td></tr>
</table>
</td>
</tr>
<tr>
<td>សសរស្តម្ភប្រព័ន្ធសុខាភិបាល៖<br>*(សូមគូសធីករាល់ចំណុចដែលពាក់ព័ន្ធ)*</td>
<td>☒ *ការផ្តល់សេវា* ☒ *ធនធានមនុស្សសុខាភិបាល*<br>☒ *ហិរញ្ញប្បទានសុខាភិបាល* ☒ *ការគ្រប់គ្រងព័ត៌មាន*<br>☒ *ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច* ☒ *ផលិតផលវេជ្ជសាស្ត្រ និងបច្ចេកវិទ្យា*</td>
</tr>
<tr>
<td>ផ្នែកផ្តោតតាមប្រធានបទ៖</td>
<td>☒ *ការពង្រឹងប្រព័ន្ធសុខាភិបាល* ☐ *ការចូលរួមរបស់សហគមន៍*<br>☐ *សុខភាពភ្នែកកុមារ* ☐ *បរិយាកាសប្រតិបត្តិការ*</td>
</tr>
</table>

<table>
<tr><td>(សូមគូសធីករាល់ចំណុចដែលពាក់ព័ន្ធ)</td><td colspan="2">☒ ការអភិវឌ្ឍធនធានមនុស្ស<br>☐ វ័យចាស់ប្រកបដោយសុខភាពល្អ<br>☐ ផ្សេងៗ (សូមបញ្ជាក់ ឧទាហរណ៍៖ ការលើកកម្ពស់គុណភាព)<br>______________________________</td></tr>
<tr><td rowspan="4">សមធម៌ និងបរិយាបន្ន<br>(GAPSED+)៖</td><td colspan="2">សមធម៌យេនឌ័រ - សូមគូសធីកវិធីសាស្ត្រសមធម៌យេនឌ័រ ដែលគម្រោងកំពុងអនុវត្ត៖<br><br>☐ ចម្បង - សមធម៌យេនឌ័រ គឺជាគោលបំណងចម្បងរបស់គម្រោង និងជាមូលដ្ឋានស្នូលក្នុងការរៀបចំ និងសមិទ្ធផលរំពឹងទុករបស់គម្រោង។<br><br>☒ សំខាន់ - សមធម៌យេនឌ័រ គឺជាគោលបំណងសំខាន់ និងមានការគិតគូរយ៉ាងច្បាស់លាស់ ប៉ុន្តែមិនមែនជាមូលហេតុចម្បងនៃការអនុវត្តគម្រោងនេះទេ។<br><br>☐ បញ្ជ្រាបជាទូទៅ - ទោះបីគម្រោងមិនមានគោលបំណងសមធម៌យេនឌ័រដែលបានកំណត់ជាក់លាក់ក៏ដោយ ក៏គម្រោងបានកំណត់ និងដោះស្រាយគម្លាតយេនឌ័រនៅក្នុងការចូលរួម និងការទទួលបានអត្ថប្រយោជន៍។ ការវិភាគយេនឌ័រត្រូវបានអនុវត្ត ហានិភ័យពាក់ព័ន្ធនឹងយេនឌ័រត្រូវបានកាត់បន្ថយ ហើយប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រមូលទិន្នន័យបែងចែកតាមភេទ និងប្រើសូចនាករយេនឌ័រតាមភាពសមស្រប។ ការបញ្ជ្រាបយេនឌ័រមិនមែនជាគោលដៅចុងក្រោយដោយខ្លួនឯងទេ ប៉ុន្តែជាមធ្យោបាយដើម្បីឈានទៅរកសមធម៌យេនឌ័រ។<br><br>☐ មិនបានកំណត់ជាគោលដៅ - សកម្មភាពនេះ មិនបានកំណត់គោលដៅផ្ទាល់ក្នុងការជំរុញសមធម៌យេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីទេ។ ទោះជាយ៉ាងនេះក្តី សមធម៌យេនឌ័រអាចត្រូវបានគិតគូរ តាមរយៈការធានាឱ្យមានការចូលរួមរបស់ស្ត្រី និងក្មេងស្រី ហើយការវិភាគយេនឌ័រ នឹងត្រូវបាន ឬត្រូវបានអនុវត្តជាផ្នែកមួយនៃការរៀបចំសកម្មភាព។</td></tr>
<tr><td>ក្រុមអាយុគោលដៅ<br>☒ កុមារ (០-១៤ ឆ្នាំ)<br>☒ មនុស្សពេញវ័យ (១៥-៤៩ ឆ្នាំ)<br>☒ មនុស្សវ័យចាស់ (៥០ ឆ្នាំឡើងទៅ)</td><td>ទីកន្លែងរស់នៅ ឬទីកន្លែងទទួលសេវា<br>☒ មានការទទួលបានសេវាសុខភាពភ្នែកទាប ឬមិនមានការទទួលបានសេវាសុខភាពភ្នែក និង/ឬ<br>☐ មានការប្រើប្រាស់សេវាសុខភាពភ្នែកទាប ឬមិនមានការប្រើប្រាស់សេវាសុខភាពភ្នែក</td></tr>
<tr><td>ស្ថានភាពសេដ្ឋកិច្ច-សង្គម<br><br>☒ គម្រោងផ្តោតលើសហគមន៍ដែលមានលទ្ធភាពទទួលបានធនធានសង្គម និងសេដ្ឋកិច្ចនៅកម្រិតទាប ដោយផ្អែកលើស្តង់ដារជាតិ។</td><td>ជាតិសាសន៍/ជនជាតិដើមភាគតិច/ពូជសាសន៍<br><br>☒ គម្រោងផ្តោតលើសហគមន៍មូលដ្ឋានដែលត្រូវបានបាត់បង់ឱកាស ឬរងការរើសអើង។</td></tr>
<tr><td colspan="2">☐ បរិយាបន្នសម្រាប់ជនមានពិការភាព<br>(សូមគូសធីកប្រអប់នេះតែប៉ុណ្ណោះ ប្រសិនបើគម្រោងរបស់លោក/លោកស្រី ត្រូវបានកំណត់ថា កំពុងអនុវត្តវិធីសាស្ត្របញ្ជ្រាបបរិយាបន្នសម្រាប់ជនមានពិការភាព។)<br>ប្រសិនបើលោក/លោកស្រីបានគូសធីកប្រអប់ពិការភាពខាងលើ សូមបញ្ជាក់អំពីចំណុចផ្តោតនៃសកម្មភាពខាងក្រោម៖</td></tr>
</table>

| | |
|---|---|
| | ☒ *គម្រោងមានការចូលរួមយ៉ាងសកម្មពីជនមានពិការភាព និងអង្គការតំណាងរបស់ពួកគេ (ដូចជា អង្គការតំណាងជនមានពិការភាព) ក្នុងការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យ និងវាយតម្លៃ។*<br>*និង/ឬ៖*<br>☒ *សកម្មភាពគម្រោង កំណត់ និងដោះស្រាយឧបសគ្គចំពោះបរិយាបន្ន និងឱកាសចូលរួមរបស់ជនមានពិការភាព ដើម្បីឱ្យពួកគាត់អាចទទួលបានអត្ថប្រយោជន៍ពីគម្រោងដោយស្មើភាព។* |
| | ☐ **PLUS** (កត្តាផ្សេងៗទៀតនៃការបាត់បង់ឱកាស ឬការផាត់ចេញពីសង្គម ដូចជា ស្ថានភាពជាជនចំណាកស្រុក សាសនា និងការផ្លាស់ទីលំនៅដោយបង្ខំ) |
| **ការវាយតម្លៃគម្រោង** | ការវាយតម្លៃខាងក្រោមនឹងត្រូវបានអនុវត្តសម្រាប់គម្រោងនេះ៖<br>☒ *ការវាយតម្លៃពាក់កណ្តាលវគ្គ* កាលបរិច្ឆេទរំពឹងទុក៖ មករា ២០២៩<br>☒ *ការវាយតម្លៃបញ្ចប់គម្រោង* កាលបរិច្ឆេទរំពឹងទុក៖ មីនា ២០៣១ |
| **ក្រុមការងាររៀបចំគម្រោង៖** | - អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល<br>- កម្មវិធីជាតិសុខភាពភ្នែក<br>- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល<br>- មន្ទីរពេទ្យព្រះអង្គឌួង<br>- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត<br>- មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី/ខេត្ត (ភ្នំពេញ សៀមរាប កណ្ដាល កំពង់ចាម កំពង់ធំ កំពង់ស្ពឺ កំពង់ឆ្នាំង ព្រះសីហនុ ត្បូងឃ្មុំ ព្រះវិហារ ឧត្តរមានជ័យ កំពត តាកែវ រតនគិរី)<br>- សមាគមគ្រូពេទ្យភ្នែកកម្ពុជា<br>- សមាគមចក្ខុមាត្រការីកម្ពុជា<br>- មូលនិធិហ្វ្រេដហូឡូ |

# ii. អក្សរកាត់

| | |
|---|---|
| AI | បញ្ញាសប្បនិម្មិត |
| ANCP | កម្មវិធីសហប្រតិបត្តិការអង្គការក្រៅរដ្ឋាភិបាលអូស្ត្រាលី |
| AUD | រូបិយបណ្ណ ដុល្លាអូស្ត្រាលី |
| CDHS | ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា |
| COS | សមាគមគ្រូពេទ្យភ្នែកកម្ពុជា |
| CPA | សំណុំសកម្មភាពបង្គ្រប់ |
| CPD | ការបន្តអភិវឌ្ឍវិជ្ជាជីវៈ |
| CQI | ការបន្តលើកកម្ពស់គុណភាព |
| CSN | ក្រុមការងារគាំទ្របច្ចេកទេស (របស់មូលនិធិហ្វ្រេដហូឡូ) |
| CSOM | ការត្រួតពិនិត្យតាមដានលទ្ធផលនៃការបកបាយភ្នែក |
| DFAT | ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (រដ្ឋាភិបាលអូស្ត្រាលី) |
| DHIS2 | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល |
| DPO | អង្គការតំណាងជនពិការ |
| DR | ជំងឺរលាកសរសៃបាតភ្នែកបណ្តាលមកពីជំងឺទឹកនោមផ្អែម |
| EHG | អភិបាលកិច្ចសុខភាពភ្នែក |
| FHF | មូលនិធិហ្វ្រេដហូឡូ |
| GAPSED+ | ការវិភាគស្ថានភាព យេនឌ័រ វ័យ ទីកន្លែង ស្ថានភាពសេដ្ឋកិច្ច-សង្គម កុលសម្ព័ន្ធ ពិការភាព និងកត្តាផ្សេងៗទៀតដែលបង្កឱ្យមានការបាត់បង់ឱកាសក្នុងសង្គម |
| HEF | មូលនិធិសមធម៌សុខភាព (ក្រសួងសុខាភិបាល) |
| HMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល |
| HSP4 | ផែនការយុទ្ធសាស្ត្រសុខាភិបាល (ទី៤) |
| HRH | ធនធានមនុស្សសម្រាប់វិស័យសុខាភិបាល |
| IEC | ព័ត៌មាន អប់រំ និងទំនាក់ទំនង (សម្ភារអប់រំ) |
| IPEC | ការថែទាំសុខភាពភ្នែកដោយផ្តោតលើប្រជាជន |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MERL | ការត្រួតពិនិត្យ តាមដាន ការវាយតម្លៃ ការស្រាវជ្រាវ និងការរៀនសូត្រ |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | ក្រសួងកិច្ចការនារី |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MSAT | ឧបករណ៍វាយតម្លៃស្តង់ដារអប្បបរមា |
| NPEH | កម្មវិធីជាតិសុខភាពភ្នែកនៃក្រសួងសុខាភិបាល |
| NSPBPC | ផែនការយុទ្ធសាស្ត្រជាតិស្តីពី ការគ្រប់គ្រង និងបង្ការភាពពិការភ្នែក |
| OD | ការិយាល័យស្រុកប្រតិបត្តិ |
| OELF | មូលនិធិវែនសាយ អេសស៊ីឡូ ឡាក់សូទីកា (OneSight EssilorLuxottica Foundation) |
| OSC | សមាគមចក្ខុមាត្រការីកម្ពុជា |

| | |
|---|---|
| PDD | ឯកសារចងក្រងគម្រោង |
| PHD | មន្ទីរសុខាភិបាលនៃរដ្ឋបាល រាជធានី-ខេត្ត |
| PSC | គណៈកម្មការដឹកនាំគម្រោង |
| QA | ការធានាគុណភាព |
| QI | ការលើកកម្ពស់គុណភាព |
| RAAB | ការអង្កេតរហ័សថ្នាក់ជាតិស្តីពីភាពពិការភ្នែកដែលអាចជៀសវាងបាន |
| SOP | នីតិវិធីប្រតិបត្តិស្តង់ដារ |
| SURES | គម្រោង ពង្រឹកវិសាលសេវាកំហុសកំណុំរូបភាពនៅកម្ពុជា |
| TWG | ក្រុមការងារបច្ចេកទេស |
| UHC | ការគ្របដណ្តប់សុខភាពជាសកល |
| UHS | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| WHO | អង្គការសុខភាពពិភពលោក |

# 1.1 ការវិភាគស្ថានភាព និងបរិបទ

## 1.1.1 សាវតា និងបរិបទ

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ អង្គការ មូលនិធិហ្វ្រេដហូឡូ (The Fred Hollows Foundation) បានធ្វើការយ៉ាងជិតស្និទ្ធភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេវាសុខភាពភ្នែក ដោយចាប់ផ្ដើមពីការផ្ដល់សេវា និងការបណ្ដុះបណ្ដាលធនធានមនុស្ស រហូតឈានទៅរកការបន្តពង្រឹងប្រព័ន្ធសុខាភិបាលជាជំហានៗ។ វឌ្ឍនភាពនេះ ឆ្លុះបញ្ចាំងទាំង ការកើនឡើងនូវសមត្ថភាពរបស់ស្ថាប័នជាតិ និងការដឹកនាំដោយរដ្ឋាភិបាល ប្រកបដោយនិរន្តរភាព។ គម្រោងអភិបាលកិច្ចសុខភាពភ្នែក ត្រូវបានរៀបចំឡើងដោយផ្អែកលើកិច្ចសហប្រតិបត្តិការដែលមានស្រាប់ជាយូរមកហើយនេះ និងមេរៀនជាពិសោធន៍ដែលទទួលបានពីគំនិតផ្ដួចផ្ដើមមុនៗ និងបច្ចុប្បន្ន ដែលផ្ដោតលើការសម្របសម្រួលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការអភិវឌ្ឍធនធានមនុស្ស ការធានាគុណភាព និងកិច្ចសហប្រតិបត្តិការឆ្លងអន្តរវិស័យ។ គម្រោងនេះត្រូវបានផ្ដួចផ្ដើមរៀបចំឡើង តាមរយៈការពិគ្រោះយោបល់ ដែលដឹកនាំដោយក្រសួងសុខាភិបាល ដោយមានការចូលរួមពីកម្មវិធីជាតិសុខភាពភ្នែក សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មន្ទីរពេទ្យថ្នាក់ជាតិ និងដៃគូក្នុងវិស័យសុខភាពភ្នែក ហើយឆ្លើយតបដោយផ្ទាល់ទៅនឹងតម្រូវការអាទិភាពនានា ដែលបានកំណត់ក្នុងផែនការជាតិ និងការវិភាគស្ថានភាព។

គម្រោងនេះមានវិសាលភាពគ្របដណ្ដប់នៅទូទាំងប្រទេសក្នុងរាជធានី-ខេត្តទាំង ២៥ នៃព្រះរាជាណាចក្រកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការចុះកិច្ចព្រមព្រៀងភាពជាដៃគូអនុវត្តគម្រោងផ្ទាល់ ជាមួយរដ្ឋបាលរាជធានី-ខេត្តដែលបានជ្រើសរើសចំនួន ១៤។ រាជធានី-ខេត្តទាំងនោះរួមមាន៖ រាជធានីភ្នំពេញ កណ្ដាល កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ ព្រះសីហនុ កំពត ត្បូងឃ្មុំ សៀមរាប រតនគិរី ព្រះវិហារ ឧត្តរមានជ័យ និងតាកែវ។ ការកំណត់ទីតាំងភូមិសាស្ត្រនេះ ធ្វើឡើងដោយមានគោលដៅច្បាស់លាស់។ ទោះបីជាសេវាសុខភាពភ្នែកមានការរីកចម្រើន និងបានពង្រីកក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ ការទទួលបានសេវា គុណភាពសេវា និងចំនួនធនធានអ្នកផ្ដល់សេវាសុខភាពភ្នែក នៅតែមានគម្លាតខុសគ្នាច្រើន រវាងខេត្ត និងខេត្ត និងរវាងតំបន់ទីប្រជុំជន និងទីជនបទ។ ការអនុវត្តបែបយន្តការថ្នាក់ជាតិ អាចឱ្យយើងត្រៀម ផែនការ ការងារអភិបាលកិច្ច ស្តង់ដារ គោលនយោបាយ និងប្រព័ន្ធនានា ដើម្បីពង្រឹងប្រកបដោយសុក្រិតភាព និងភាពស៊ីសង្វាក់គ្នា នៅទូទាំងប្រទេស លើកកម្ពស់សមធម៌ ប្រសិទ្ធភាព និងនិរន្តរភាព។ ភាពសកម្មនៅកម្រិតថ្នាក់ជាតិក៏ជាកត្តាចាំបាច់ផងដែរ ដើម្បីបន្សុីគ្នាវិស័យសុខភាពភ្នែកទៅនឹងការកែទម្រង់វិស័យសុខាភិបាលឱ្យកាន់តែទូលំទូលាយ យន្តការហិរញ្ញប្បទាន និងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស។

គម្រោងនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើការវិនិយោគ កិច្ចសហប្រតិបត្តិការភាពជាដៃគូល្អ និងកិច្ចខិតខំប្រឹងប្រែងពង្រឹងប្រព័ន្ធសុខាភិបាលប្រកបដោយនិរន្តរភាព នាពេលកន្លងមក និងបច្ចុប្បន្ន តាមរយៈគំនិតផ្ដួចផ្ដើមសុខភាពភ្នែកនានានៅកម្ពុជា។ ដូច្នេះ បទអន្តរាគមន៍ ដែលបានរៀបចំនិងស្នើឡើង ភាគច្រើនមិនមែនជាសកម្មភាពដាច់ដោយឡែកថ្មីស្រឡាងនោះទេ ប៉ុន្តែជាការបន្តការគាំទ្រការពង្រីកវិសាលភាព ឬការអនុវត្តតាមស្ថាប័នរដ្ឋដែលមានស្រាប់ និងជាមួយដៃគូក្នុងវិស័យនេះ។ សកម្មភាពទាំងនេះរួមមាន ការបន្តយន្តការសម្របសម្រួល ការអភិវឌ្ឍធនធានមនុស្ស ការធានាគុណភាព ប្រព័ន្ធកត់ត្រានិងរក្សាទិន្នន័យ និងការបញ្ចូលការងារសុខភាពភ្នែកទៅក្នុងប្រព័ន្ធសុខាភិបាលទូទៅ។ គម្រោងនេះត្រូវត្រូវបានរៀបចំឡើង ផ្អែកលើទំនាក់ទំនងដ៏រឹងមាំដែលមានស្រាប់ ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងមេរៀនជាពិសោធន៍ដែលទទួលបានពីការអនុវត្តគម្រោងកន្លងមក ព្រមទាំងជំរុញ គាំទ្រ ដល់ការបន្តពង្រីកវិសាលភាពការងារ ការពង្រឹង និងនិរន្តរភាពនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះនៅក្នុងប្រព័ន្ធគ្រឹះស្ថានសុខាភិបាលសាធារណៈ។

ប្រទេសកម្ពុជាបន្តមានស្ថេរភាពនៃកំណើនសេដ្ឋកិច្ច និងសុខមាលភាពទូទៅ រួមទាំងកំណែទម្រង់ប្រព័ន្ធសុខាភិបាលជាបន្តបន្ទាប់ ដើម្បីឈានទៅសម្រេចបាននូវ ការគ្របដណ្ដប់សុខភាពជាសកល (Universal Health Coverage)។ ក្នុងបរិបទនេះ សុខភាពភ្នែកត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើង ថាមានសារៈសំខាន់ និងជាភាគទានដ៏ចម្បង គាំទ្រដល់សុខុមាលភាពទូទៅ ផលិតភាព និងការរស់នៅប្រកបដោយសុខភាពល្អក្នុងវ័យជរា។ ជាមួយគ្នានេះដែរ សេវាសុខភាពភ្នែកស្ថិតនៅចំណុចប្រសព្វនៃវិស័យជាច្រើន រួមមាន វិស័យសុខាភិបាល អប់រំ កិច្ចគាំពារសង្គម យេនឌ័រ និងពិការភាព ដែលទាមទារឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងការ

ដឹកនាំ គ្រប់គ្រងច្បាស់លាស់។ កាលានុវត្តភាពផ្នែកបច្ចេកវិទ្យា អាចជួយធ្វើឱ្យប្រសើរឡើង នូវការបណ្តុះបណ្តាល ការផ្តល់សេវា ការចុះអភិបាលកិច្ច និងការប្រើប្រាស់ទិន្នន័យ ប៉ុន្តែកាលានុវត្តភាពទាំងនេះ អាចដំណើរការទៅបាន អាស្រ័យលើ ការមានអភិបាលកិច្ចរឹងមាំ និងការត្រៀមលក្ខណៈពេញលេញនៃប្រព័ន្ធសុខាភិបាល ដើម្បីទទួលបានប្រសិទ្ធភាព និងប្រសិទ្ធិផលខ្ពស់។ គម្រោង អភិបាលកិច្ចសុខភាពភ្នែក ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងបរិបទនេះ ដោយពង្រឹងភាពជាអ្នកដឹកនាំ ការសម្របសម្រួល និងដំណើរការមុខងារប្រព័ន្ធ ដែលជួយឱ្យការផ្តល់សេវាសុខភាពភ្នែកមានប្រសិទ្ធភាព និងប្រកបដោយសមធម៌។

## 1.1.2 ការវិភាគបញ្ហា និងឥស្សុតាង

ប្រទេសកម្ពុជា នៅតែបន្តជួបឧបសគ្គរាំង ក្នុងការផ្តល់សេវាថែទាំភ្នែក ប្រកបដោយគុណភាព ភាពប្រទាក់ក្រឡាគ្នានិងភាពជាប់លាប់ និងប្រកបដោយសមធម៌ បើទោះបីជាមានការរីកចម្រើនក្នុងការពង្រីកវិសាលភាពសេវាសុខភាពភ្នែក និងភាពប្រសើរឡើងនៃប្រព័ន្ធយ៉ាងណាក៏ដោយ។ តាមរយៈ **ដំណើរការរៀបចំផែនការជាតិ របាយការណ៍វឌ្ឍនភាពជាប្រចាំ ការវាយតម្លៃសេវា** និង**ឧបករណ៍វង្វាយតម្លៃស្តង់ដាអប្បបរមា** (MSAT) ជាភ័ស្តុតាងបង្ហាញថា ការរៀបចំផែនការសុខភាពភ្នែក ការសម្របសម្រួល លិខិតបទដ្ឋានគតិយុត្តនានា គោលការណ៍គ្លីនិក ការបណ្តុះបណ្តាលនិងការគ្រប់គ្រងធនធានមនុស្សផ្នែកសុខភាពភ្នែក ព្រមទាំងយន្តការធានាគុណភាព នៅមិនទាន់មានភាពរឹងមាំ ឬស៊ីសង្វាក់គ្នានៅគ្រប់កម្រិតនៃប្រព័ន្ធសុខាភិបាល ក្នុងការធានាបាននូវការទទួលបានសេវាប្រកបដោយសមធម៌ និងគុណភាពខ្ពស់នៅទូទាំងប្រទេសនៅឡើយ។ បញ្ហាប្រឈមទាំងនេះ មិនមែនបណ្តាលមកពីកង្វះដំណោះស្រាយបច្ចេកទេសជាចម្បងនោះទេ ប៉ុន្តែវាបណ្តាលមកពី **គម្លាតនៃកិច្ចការអភិបាលកិច្ច ការធ្វើសមាហរណកម្មក្នុងប្រព័ន្ធ ការពង្រឹងស្ថាប័ន** និង**ការអនុវត្តជាផ្លូវការតាមស្ថាប័នរដ្ឋ**។

បញ្ហាស្នូលដ៏សំខាន់មួយ គឺភាពខុសគ្នា នៃអភិបាលកិច្ច និងការសម្របសម្រួល រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះបីជាមានយន្តការក្នុងការសម្របសម្រួល (ដូចជាក្រុមការងារបច្ចេកទេសសុខភាពភ្នែក និងវេទិការៀបចំផែនការ) កំពុងអនុវត្តរួចហើយក៏ដោយ តែការបំពេញតាមមុខងារ ភាពច្បាស់លាស់នៃតួនាទី និងទំនួលខុសត្រូវ គឺនៅមានលក្ខណៈខុសៗគ្នាទៅតាមខេត្តនីមួយៗ។ ក្រោមគម្រោង កិច្ចសហការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីសុខភាពភ្នែក (NSEE) កន្លងមក ខេត្តចំនួនប្រាំមួយបានបង្កើត ឬបញ្ចូលក្រុមការងារបច្ចេកទេសអនុវិស័យសុខភាពភ្នែក (Eye Health Sub-TWGs) ទៅក្នុងប្រព័ន្ធសុខាភិបាល ប៉ុន្តែក្រុមការងារទាំងនេះមិនមានភាពសកម្ម ឬមិនទាន់មាននៅឡើយ សម្រាប់ខេត្តផ្សេងៗទៀត។ ផ្អែកលើចេនាសម្ព័ន្ធដែលមានស្រាប់ទាំងនេះ គម្រោង អភិបាលកិច្ចសុខភាពភ្នែក នឹងអនុវត្តតាមលំនាំនេះ នូវវិធីសាស្ត្រតាមដំណាក់កាល ដើម្បីពង្រឹងអភិបាលកិច្ចសុខភាពភ្នែកថ្នាក់ខេត្ត។ ខេត្តដែលមានយន្តការសម្របសម្រួលរឹងមាំជាង នឹងដើរតួជាទីតាំងរៀនសូត្រសម្រាប់ខេត្តផ្សេងៗ និងបង្ហាញគំរូ ដើម្បីគាំទ្រដល់ប្រតិបត្តិការក្រុមការងារបច្ចេកទេសអនុវិស័យសុខភាពភ្នែក (Eye Health Sub-TWGs) ក្នុងខេត្តគោលដៅផ្សេងបន្ថែមទៀត។ វិធីសាស្ត្រនេះមានគោលបំណងពង្រឹងលទ្ធភាពអាចអនុវត្តបាន លើកកម្ពស់ការរៀនសូត្រពីការអនុវត្តជាក់ស្តែង និងគាំទ្រដល់ការអនុវត្តជាផ្លូវការ នៅក្នុងប្រព័ន្ធសុខាភិបាលខេត្តជាបន្តបន្ទាប់ទៀត។

ការពិភាក្សា និងពិនិត្យឡើងវិញជាមួយដៃគូអនុវត្តគម្រោង បានគូសបញ្ជាក់ពីភាពខុសគ្នា នៃការផ្តល់អាទិភាពលើសុខភាពភ្នែកនៅក្នុងផែនការការងារសុខាភិបាលខេត្ត របៀបនៃការចុះអភិបាលកិច្ច និងរបៀបប្រើប្រាស់ព័ត៌មាន/ទិន្នន័យសម្រាប់ធ្វើការសម្រេចចិត្ត។ ភាពខុសគ្នានេះ បានជះឥទ្ធិពលដល់ ការរៀបចំផែនការ ការត្រួតពិនិត្យតាមដានលើចន្លោះខ្វះខាតដែលបានរកឃើញ និងលទ្ធភាពក្នុងការដោះស្រាយបញ្ហាជាប្រព័ន្ធ ដើម្បីឆ្លើយតបក្តីកង្វល់លើសេវាគ្របដណ្តប់ និងគុណភាពផ្តល់សេវា។ ការធ្វើសមាហរណកម្មសុខភាពភ្នែកទៅក្នុងប្រព័ន្ធសុខាភិបាលទូទៅឱ្យកាន់តែទូលំទូលាយ ចាប់ពីដំណាក់កាលនៃការរៀបចំផែនការ ការត្រួតពិនិត្យតាមដាន និងដំណើរការ កែលម្អគុណភាព កំពុងតែមានដំណើរការ និងរីកចម្រើនក្តី ប៉ុន្តែកិច្ចការនេះនៅតែមិនទាន់ស្មើភាពគ្នានៅតាមទីតាំងនានានៅឡើយ។

បញ្ហាប្រឈមចម្បងទីពីរ គឺពាក់ព័ន្ធនឹងធនធានមនុស្សផ្នែកសុខភាពភ្នែក។ ប្រទេសកម្ពុជាបានបង្កើនចំនួន និងប្រភេទ នៃអ្នកផ្តល់សេវាថែទាំភ្នែក តាមរយៈការវិនិយោគលើការបណ្តុះបណ្តាលមន្ត្រី និងការពង្រីកវិសាលភាពសេវា។ ទោះជាយ៉ាងនេះក្តី ការប៉ាន់ប្រមាណ និងការរៀបចំផែនទីបង្ហាញផ្លូវសម្រាប់អភិវឌ្ឍធនធានមនុស្ស (Workforce mapping) បង្ហាញថា ធនធានមនុស្សផ្នែកសុខភាពភ្នែក នៅតែមានអសមតុល្យភាពមន្ត្រីជំនាញតាមតម្រូវការ សមាសភាពជំនាញ (Skills mix) ការចុះអភិបាលកិច្ច និងការបែងចែកធនធានអ្នកឯកទេសភ្នែក ជាពិសេសរវាងទីប្រជុំជន និងតំបន់ជនបទ ឬតំបន់ដាច់ស្រយាល។ ការរៀបចំផែនការសម្រាប់អភិវឌ្ឍធនធានមនុស្ស ការពង្រាយមន្ត្រីឯកទេស(distribution) ការអភិវឌ្ឍវិជ្ជាជីវៈបន្ត(CPD) និងការគ្រប់គ្រងសមត្ថកិច្ចអនុវត្តការងារ មិនទាន់ត្រូវបានបញ្ជ្រាប និងអនុវត្តឱ្យបានពេញលេញទៅក្នុងប្រព័ន្ធសុខាភិបាលជាតិនៅឡើយ។ ជាលទ្ធផល នៅតាមតំបន់មួយចំនួន ប្រឈមនឹងគម្លាតនៃការផ្តល់សេវា ឬពឹងផ្អែកខ្លាំងលើ កម្មវិធីចុះតាមសហគមន៍ ឬការផ្តល់សេវាចល័ត ខណៈដែលតំបន់ផ្សេងទៀតមានស្ថេរភាព និងមានភាពរឹងមាំជាង ក្នុងការផ្តល់សេវា។ ភាពខុសគ្នាទាំងនេះ អាចប៉ះពាល់ទាំងការទទួលបានសេវា និងគុណភាពផ្តល់សេវា រួមទាំងសុវត្ថិភាពអ្នកជំងឺផងដែរ។

ប្រព័ន្ធធានាគុណភាព និងអភិបាលកិច្ចគ្លីនិក កំពុងតែត្រូវបានអភិវឌ្ឍ ប៉ុន្តែមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ឬត្រូវបានអនុវត្ត ដូចៗគ្នាជាទូទៅនៅឡើយ ថែមទាំងមិនទាន់បានធ្វើសមាហរណកម្មទៅក្នុង រចនាសម្ព័ន្ធកែលម្អគុណភាព របស់ក្រសួងសុខាភិបាលទាំងស្រុងនោះដែរ។ នាពេលបច្ចុប្បន្ន គុណភាពសេវាត្រូវបានត្រួតពិនិត្យ តាមដាន តាមរយៈការដាក់បញ្ចូលនៅក្នុងរបាយការណ៍វឌ្ឍនភាពជាប្រចាំ ពេលចុះអភិបាលកិច្ចនៅតាមទីតាំងផ្ទាល់ និងសូចនាករលទ្ធផលដែលបានជ្រើសរើសមួយចំនួន ដូចជា ការត្រួតពិនិត្យតាមដានលទ្ធផលក្រោយបកបាយភ្នែក(CSOM) ឬនៅកន្លែងដែលមានទិន្នន័យអាចរកបានប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី ឆ្លងតាមបទពិសោធន៍អនុវត្តគម្រោងជាមួយដៃគូ បង្ហាញថា ប្រព័ន្ធការងារ នៃការធ្វើសវនកម្មគ្លីនិកជាទៀងទាត់ ការផ្តល់ព័ត៌មានត្រឡប់ (Feedback) ការប្រៀបធៀបស្តង់ដាររួម (Benchmarking) និងបន្តការលើកកម្ពស់គុណភាពជាប្រចាំ(CQI) គឺនៅមានភាពខុសគ្នារវាងមូលដ្ឋានសុខាភិបាលមួយ ទៅមូលដ្ឋានសុខាភិបាលមួយទៀត ហើយមិនទាន់ត្រូវបានធ្វើស្តង់ដាររូបនីយកម្ម ឬដាក់ឱ្យអនុវត្តជាផ្លូវការតាមស្ថាប័នរដ្ឋទាំងនោះនៅឡើយ។ ទិន្នន័យដូចជា ការត្រួតពិនិត្យតាមដានលទ្ធផលក្រោយបកបាយភ្នែក(CSOM) ត្រូវបានប្រមូលនៅតាមគ្រឹះស្ថានសុខាភិបាលមួយចំនួន និងប្រើប្រាស់សម្រាប់ការរៀនសូត្រ ប៉ុន្តែវិសាលភាពគ្របដណ្តប់ និងការប្រើប្រាស់ទិន្នន័យនេះ ជាប្រព័ន្ធសម្រាប់ការលើកកម្ពស់គុណភាពនៅមានកម្រិតខុសៗគ្នា។ កត្តាទាំងនេះ បានកម្រិតនូវលទ្ធភាព ក្នុងការវាស់វែងសមត្ថអនុវត្តការងារ (performance) ឱ្យបានទៀងទាត់ ការប្រៀបធៀបលទ្ធផលរវាងមូលដ្ឋានសុខាភិបាល និងការគាំទ្រដល់ការបន្តការលើកកម្ពស់គុណភាព ប្រកបដោយចីរភាព។

កិច្ចខិតខំប្រឹងប្រែងនាពេលកន្លងមករបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ បានដោះស្រាយលើទិដ្ឋភាពមួយចំនួន នៃបញ្ហាប្រឈមដែលបានលើកឡើងទាំងនេះ។ សកម្មភាពទាំងនោះរួមមាន ការបង្កើតឱ្យមានយន្តការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការរៀបចំឱ្យមានគោលនយោបាយ គោលការណ៍ណែនាំគ្លីនិក ការវិនិយោគលើការអប់រំនិងបណ្តុះបណ្តាល និងអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវា ការរៀបចំផែនការ និងការចុះអភិបាលកិច្ច។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃ និងការរៀនសូត្រពីការអនុវត្តកម្មវិធី បញ្ជាក់ថា បទអន្តរាគមន៍ទាំងនេះមានប្រសិទ្ធភាពនៅកន្លែងណាដែលមានភាពជាអ្នកដឹកនាំរឹងមាំ តួនាទីនិងភារកិច្ចច្បាស់លាស់ និងមានការគាំទ្រប្រព័ន្ធជាបន្តបន្ទាប់។ ទោះជាយ៉ាងនេះក្តី គំនិតផ្តួចផ្តើមភាគច្រើនមានលក្ខណៈជាគម្រោងខ្លីៗ ឬជាសកម្មភាពតាមទីតាំងជាក់លាក់ណាមួយ ដោយមិនមានលទ្ធភាព ពង្រីកវិសាលភាព ឬការដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈបាន។

គម្រោងអភិបាលកិច្ចសុខភាពភ្នែក ឆ្លើយតបដោយផ្ទាល់ទៅនឹងឧបសគ្គ និងមេរៀនពិសោធន៍ទាំងនេះ។ ជំនួសឱ្យការផ្តោតលើសេវានីមួយៗតែមួយមុខ ឬដំណោះស្រាយរយៈពេលខ្លី គម្រោងនេះដោះស្រាយលើ ដំណើរការកិច្ចការអភិបាលកិច្ច ការដឹកនាំនិងគ្រប់គ្រង (Stewardship) និងមុខងារប្រព័ន្ធគ្រឹះស្ថានសុខាភិបាល ដែលអនុញ្ញាតឱ្យមានភាពប្រសើរឡើងប្រកបដោយនិរន្តរភាពនៅទូទាំងប្រទេស។ តាមរយៈការពង្រឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ការសម្របសម្រួល ប្រព័ន្ធធនធានមនុស្សក្នុងវិស័យសុខាភិបាល ការ

ធានាគុណភាព និងការប្រើប្រាស់ទិន្នន័យនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលដែលមានស្រាប់ គម្រោងនឹងបង្កើតលក្ខខណ្ឌអំណោយផល សម្រាប់ការថែទាំភ្នែកដែលមានភាពទៀងទាត់ ប្រទាក់ក្រឡាគ្នា សមធម៌ និងគុណភាពខ្ពស់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## 1.1.3 ការវិភាគស្ថានភាពសមធម៌

គម្រោង «**អភិបាលកិច្ចសុខភាពភ្នែក**» ត្រូវបានរៀបចំឡើងដោយផ្អែកលើការប្តេជ្ញាចិត្ត ក្នុងការជំរុញ លើកកម្ពស់ សមធម៌សុខភាព ដោយទទួលស្គាល់ថា ប្រជាពលរដ្ឋគ្រប់រូប ត្រូវតែទទួលបានឱកាសប្រកបដោយសមធម៌ក្នុងការទទួលបានសុខភាពភ្នែកល្អ។ ភស្តុតាងទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ សបញ្ជាក់ថា វិសមធម៌នៃសុខភាពភ្នែកនៅកម្ពុជា គឺកើតចេញពីកត្តាភូមិសាស្ត្រ យេនឌ័រ វ័យ ពិការភាព និងស្ថានភាពសេដ្ឋកិច្ច-សង្គម ដែលកត្តាទាំងនេះតែងតែជះឥទ្ធិពលរួមគ្នា។ ស្ថានភាពវិសមធម៌ទាំងនេះ គឺស្របគ្នា ទៅនឹងក្រុមប្រជាជនអាទិភាព ដែលបានកំណត់នៅក្នុង ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រង និងបង្ការភាពពិការភ្នែក (NSP-BPC 2021–2030) និង ផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០២៥–២០៣៤ (HSP4) ដែលផែនការទាំងពីរសុទ្ធតែបានរំលេចលើ ស្ថានភាព ទទួលបានសេវាដែលមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងការទទួលបានសេវាជាសកល។

### វិសមធម៌ ផ្នែកភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គម

របាយការណ៍ស្តីពីការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា (CDHS 2021–2022) បានគូសបញ្ជាក់ពីគម្លាត ក្នុងការទទួលបានសេវាសុខាភិបាល រវាងប្រជាជននៅទីប្រជុំជន និងទីជនបទ ដោយលើកឡើងថា គ្រួសារនៅទីជនបទប្រឈមនឹងឧបសគ្គ ពាក់ព័ន្ធនឹងចម្ងាយផ្លូវ មធ្យោបាយធ្វើដំណើរទៅទទួលសេវា ហេដ្ឋារចនាសម្ព័ន្ធ និងកង្វះខាតមន្ត្រីសុខាភិបាលជំនាញ ខ្លាំងជាងអ្នកនៅទីប្រជុំជន។ វិសមធម៌ក្នុងប្រព័ន្ធសុខាភិបាលទាំងនេះ ត្រូវបាន សបញ្ជាក់អោយឃើញតាមរយៈ ការពិនិត្យមើលលើការទទួលបានសេវាថែទាំសុខភាពភ្នែក។ របាយការណ៍ពី ការអង្កេតរហ័សស្តីពីភាពពិការភ្នែកនៅកម្ពុជាឆ្នាំ២០១៩ (RAAB 2019) និងការវាយតម្លៃសេវាថែទាំថ្នាក់ជាតិ បានបង្ហាញថា សេវាថែទាំចក្ខុរោគឯកទេស និងមន្ត្រីសុខភាពភ្នែកដែលបានបណ្តុះបណ្តាល គឺប្រមូលផ្តុំតែនៅទីប្រជុំជន និងទីរួមខេត្តតែប៉ុណ្ណោះ ផ្ទុយគ្នាស្រឡះបើធៀបទៅនឹងប្រជាជនរស់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ដែលនៅតែពឹងផ្អែកខ្លាំងលើសេវាចុះពិនិត្យតាមសហគមន៍ (outreach services) យុទ្ធនាការបោះជុំរុំពិនិត្យនិងព្យាបាលភ្នែក (eye camps) ឬប្រព័ន្ធបញ្ជូនអ្នកជំងឺដែលមានភាពយឺតយ៉ាវ។

ស្ថានភាពសេដ្ឋកិច្ច-សង្គម ក៏ជាបន្ទុកបន្ថែមទៀតជាមួយកត្តាភូមិសាស្ត្រ។ របាយការណ៍ពីការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា CDHS 2021–2022 បានលើកឡើងថា គ្រួសារស្ថិតក្នុងកម្រិតជីវភាពក្រីក្រ ប្រឈមនឹងការលំបាកកាន់តែខ្លាំងក្នុងការទទួលបានការថែទាំ ដោយសារថ្លៃសេវា មធ្យោបាយធ្វើដំណើរ និងការបាត់បង់ឱកាសរកប្រាក់ចំណូល(opportunity costs)។ ទោះបីជា មូលនិធិសមធម៌សុខាភិបាល (HEFs) និងយន្តការគាំពារសង្គម ត្រូវបានពង្រីកការគ្របដណ្តប់យ៉ាងណាក៏ដោយ ក៏ការយល់ដឹង ការប្រើប្រាស់ប័ណ្ណ និងការអនុវត្តយន្តការទាំងនេះ សម្រាប់សេវាសុខភាពភ្នែកប្រកបដោយប្រសិទ្ធភាព នៅតែមានកម្រិតមិនស្មើគ្នានៅឡើយ ជាពិសេស ចំពោះមនុស្សវ័យចាស់ និងប្រជាជនរស់នៅតំបន់ដាច់ស្រយាល ដូចដែលបានលើកឡើងនៅក្នុងឯកសារនៃការរៀបចំផែនការថ្នាក់ជាតិ និងការពិភាក្សានិងពិនិត្យឡើងវិញជាមួយដៃគូកន្លងមក។

### វិសមធម៌ យេនឌ័រ និងវ័យ

នៅកម្ពុជា គម្លាតយេនឌ័រក្នុងសុខភាពភ្នែក ត្រូវបានកំណត់យ៉ាងច្បាស់តាមរយៈភស្តុតាងនៃការស្រាវជ្រាវ។ ផ្អែកលើរបាយការណ៍ពីការអង្កេតរហ័សស្តីពីភាពពិការភ្នែកនៅកម្ពុជាឆ្នាំ២០១៩ (RAAB 2019) បង្ហាញថា អត្រាប្រេវ៉ាឡង់នៃពិការភាពភ្នែក (blindness) ដែលបានព្យាបាល និងកែតម្រូវរួច ក្នុងចំណោមប្រជាជនអាយុចាប់ពី ៥០ឆ្នាំឡើងទៅ គឺ ស្ត្រី (៣,២%) មានកម្រិតខ្ពស់ជាងធៀបនឹងបុរស (១,៦%)។ ក្នុងស្ថានភាពប្រហាក់ប្រហែលគ្នានេះដែរ ស្ត្រីក៏មានអត្រាភាគរយកើតមាន ជំងឺបាយភ្នែក(cataract) និងបញ្ហាគំហើញថយចុះ (vision impairment) ច្រើនជាងបុរសផងដែរ។ ខណៈលទ្ធភាពគ្របដណ្តប់នៃការព្យាបាលជំងឺបាយភ្នែកសរុបមានការកើនឡើងចាប់តាំងពីឆ្នាំ២០០៧ រហូតមកក៏ដោយ ក៏ទិន្នន័យ ពីការអង្កេតរហ័ស RAAB 2019 បង្ហាញថា ការគ្របដណ្តប់ព្យាបាល

និងវះកាត់លើស្ត្រី នៅតែមានកម្រិតទាបជាងបុរស ដែលកត្តានេះឆ្លុះបញ្ចាំងពីឧបសគ្គពាក់ព័ន្ធនឹងយេនឌ័រ ក្នុងការទទួលបានការព្យាបាលវះកាត់ទាន់ពេលវេលា។

របាយការណ៍ពីការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា CDHS 2021–2022 និងការវិភាគស្ថានភាព យេនឌ័រ វ័យ ទីកន្លែង ស្ថានភាពសេដ្ឋកិច្ច-សង្គម កុលសម្ព័ន្ធ ពិការភាព និងកត្តាផ្សេងៗទៀតដែលបង្កឱ្យមានការបាត់បង់ឱកាសក្នុងសង្គម(GAPSED+) ក៏បានគូសបញ្ជាក់បន្ថែមថា ស្ត្រី ជាពិសេសស្ត្រីវ័យចាស់ ប្រឈមមុខនឹងឧបសគ្គស្មុគស្មាញជាច្រើន គឺបន្ទុកមើលថែទាំគ្រួសារ ធនធានហិរញ្ញវត្ថុមានកម្រិត កង្វះមធ្យោបាយធ្វើដំណើរ (mobility constraints) និងតម្រូវការនៃការគាំទ្រពីគ្រួសារ ក្នុងអំឡុងពេល និងក្រោយពេលនៃការព្យាបាល និងវះកាត់ជំងឺភ្នែក។ ចំណែកឯបុរស ពិសេសបុរសវ័យចាស់នៅទីជនបទ ក៏អាចពន្យារពេលក្នុងការទទួលសេវាផងដែរ ដោយសារអាទិភាពការងារ ជំនឿសង្គមជុំវិញបញ្ហាជំងឺ ឬការយល់ឃើញមានកម្រិត អំពីតម្រូវការព្យាបាលដំណាក់កាលដំបូង ដែលកត្តាទាំងនេះនាំឱ្យការមកទទួលសេវាយឺតជ្រុលទៅហើយ។

វ័យ គឺជាកត្តាសមធម៌ដ៏សំខាន់មួយ។ ទិន្នន័យពីការអង្កេតរហ័ស RAAB 2019 បង្ហាញពីការកើនឡើងយ៉ាងគំហុក នៃពិការភាពភ្នែក និងបញ្ហាគំហើញថយចុះ នៅអាយុ ពី៥០ឆ្នាំឡើង បង្ករឡើងជាចម្បងដោយសារ ភ្នែកឡើងបាយ និងភ្នែកមានបញ្ហាកំហុសកំណុំរូបភាព(refractive error) ដោយសមាមាត្រនៃប្រជាជនអាយុ ៥០ ឆ្នាំឡើងទៅ ត្រូវបានព្យាករណ៍ថានឹងបន្តកើនឡើង។ ការផ្លាស់ប្តូរប្រជាសាស្ត្រនេះ មានកត្តាប៉ះពាល់យ៉ាងខ្លាំងដល់តម្រូវការសេវា និងសមធម៌ ជាពិសេសសម្រាប់មនុស្សវ័យចាស់ដែលរស់នៅម្នាក់ឯង ស្ថិតក្នុងភាពក្រីក្រ ឬរស់នៅតំបន់ដាច់ស្រយាល។

## ពិការភាព និងបរិយាបន្នសង្គម

វិសមធម៌ទាក់ទងទៅនឹងភាពមានពិការភាព ត្រូវបានលើកឡើង ទាំងនៅក្នុងឯកសារថ្នាក់ជាតិ និងដៃគូ។ របាយការណ៍ CDHS 2021–2022 បានបញ្ជាក់ពី អត្រាប្រេវ៉ាឡង់នៃពិការភាពមានការកើនឡើងតាមអាយុ និងស្ត្រីមានកម្រិតខ្ពស់ជាងបុរស ដោយការលំបាកពីផលប៉ះពាល់នៃគំហើញ ត្រូវបានរាយការណ៍ញឹកញាប់ជាងគេ។ ការវិភាគស្ថានភាព យេនឌ័រ វ័យ ទីកន្លែង ស្ថានភាពសេដ្ឋកិច្ច-សង្គម កុលសម្ព័ន្ធ ពិការភាព និងកត្តាផ្សេងៗទៀតដែលបង្កឱ្យមានការបាត់បង់ឱកាសក្នុងសង្គម(GAPSED+) និងរបាយការណ៍ពីការវិភាគស្ថានភាពថ្នាក់ជាតិ បានគូសបញ្ជាក់ផងដែរថា ជនមានពិការភាពតែងតែប្រឈមមុខនឹងឧបសគ្គ ផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការប្រាស្រ័យទាក់ទង និងឥរិយាបថនៅតាមគ្រឹះស្ថានសុខាភិបាល រួមមានៈ ភាពងាយស្រួលរចនាសម្ព័ន្ធរូបវន្តក្នុងការទៅទទួលសេវានៅមានកម្រិត កង្វះខាតព័ត៌មានតាមតម្រូវការ និងការរើសអើង (stigma)។

របាយការណ៍ពីការអង្កេតរហ័សថ្នាក់ជាតិស្តីពីភាពពិការភ្នែក RAAB 2019 បង្ហាញថា ភាគរយនៃប្រជាជនអាយុ ៥០ ឆ្នាំឡើងទៅ បានជួបប្រទះបញ្ហាខ្សោយគំហើញធ្ងន់ធ្ងរ (low vision) ដែលទាមទាឱ្យមានការ កែតម្រូវស្ថានភាពគំហើញខ្សោយនេះ ឬការស្តារលទ្ធភាពពលកម្ម ក៏ប៉ុន្តែ ប្រព័ន្ធបញ្ជូនអ្នកជំងឺ រវាងសេវាសុខភាពភ្នែក និងប្រព័ន្ធគាំពារពិការភាព និងសង្គមកិច្ច មិនទាន់ត្រូវបានរៀបចំឡើងជាប្រព័ន្ធថ្នាក់ជាតិនៅឡើយទេ។ ឧបសគ្គពាក់ព័ន្ធនឹងពិការភាព តែងតែមានបន្ទុកបន្ថែមដោយភាពក្រីក្រ រើសអើងយេនឌ័រ និងការរស់នៅតាមទីជនបទ គឺរឹតតែលំបាកក្នុងការទទួលបានសេវាថែទាំភ្នែក និងសេវាតាមដានសុខភាពបានទាន់ពេលវេលា។

## មេរៀនជាបទពិសោធន៍ ដើម្បីរៀបចំចងក្រងគម្រោង (Implications for project design)

គម្រោងអភិបាលកិច្ចសុខភាពភ្នែក ធ្វើការបញ្ជ្រាប ទស្សនវិស័យសមធម៌នៅគ្រប់សមាសភាគទាំងអស់ ស្របតាមក្របខណ្ឌ នៃ ការវិភាគស្ថានភាព យេនឌ័រ វ័យ ទីកន្លែង ស្ថានភាពសេដ្ឋកិច្ច-សង្គម កុលសម្ព័ន្ធ ពិការភាព និងកត្តាផ្សេងៗទៀតដែលបង្កឱ្យមានការបាត់បង់ឱកាសក្នុងសង្គម(GAPSED+) របស់អង្គការ មូលនិធិហ្វ្រេដហូឡូ និងគោលនយោបាយអាទិភាពថ្នាក់ជាតិ។ សមធម៌ ត្រូវបានដោះស្រាយតាមរយៈ៖

- ការពង្រឹងការប្រមូល និងប្រើប្រាស់ទិន្នន័យ (បែងចែកតាមភេទ អាយុ ពិការភាព និងទីតាំងភូមិសាស្ត្រ) សម្រាប់ការរៀបចំផែនការ និងការត្រួតពិនិត្យ តាមដាន។

- ការលើកកម្ពស់យន្តការអភិបាលកិច្ច និងការសម្របសម្រួល ប្រកបដោយបរិយាបន្ន ។
- ការបញ្ជ្រាបការគិតគូរលើ យេនឌ័រ វ័យ និងស្ថានភាពពិការភាព ទៅក្នុងផែនការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងការចុះអភិបាលកិច្ចគាំទ្រ (supervision) និងប្រព័ន្ធធានាគុណភាព។ និង
- ការពង្រឹងកិច្ចសហការ សម្របសម្រួល រវាងសុខភាពភ្នែក យន្តការគាំពារសង្គម និងភាគីពាក់ព័ន្ធវិស័យពិការភាព។

ជំនួសឱ្យការចាត់ទុកសមធម៌ ជាប្រធានបទដាច់ដោយឡែក គម្រោងនេះបានបញ្ជ្រាបសមធម៌ទៅក្នុងដំណើរការពង្រឹងអភិបាលកិច្ច ការធ្វើសមាហរណកម្មក្នុងប្រព័ន្ធ (system integration) និងដំណើរការរៀនសូត្រតាមស្ថាប័ន ដើម្បីជំរុញការគាំទ្រដល់សេវាសុខភាពភ្នែកនៅកម្ពុជា ឱ្យកាន់តែមានបរិយាបន្ន ឆ្លើយតបរហ័ស និងមាននិរន្តរភាព។

## 1.1.4 ការវិភាគភាគីពាក់ព័ន្ធ

គម្រោង អភិបាលកិច្ចសុខភាពភ្នែក (Eye Health Governance – EHG) អនុវត្តតាមវិធីសាស្រ្ត គ្របដណ្តប់ទូទាំងវិស័យ (whole-of-sector approach) ដោយទទួលស្គាល់ថា ការកែលម្អប្រកបដោយចីរភាពលើ សមធម៌ គុណភាព និងការគ្របដណ្តប់នៃសេវាសុខភាពភ្នែក ពឹងផ្អែកយ៉ាងសំខាន់លើ កិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងរាជរដ្ឋាភិបាល ស្ថាប័នវិជ្ជាជីវៈ ស្ថាប័នបណ្តុះបណ្តាល អ្នកផ្តល់សេវាសុខាភិបាល និងដៃគូអភិវឌ្ឍន៍។ គម្រោងនេះមានវិសាលភាព និងអាណត្តិអនុវត្តកម្រិតថ្នាក់ជាតិ ដោយផ្តល់អាទិភាពដល់ការចូលរួមកាន់តែស៊ីជម្រៅ និងការគាំទ្រដល់ការពង្រឹងប្រព័ន្ធ នៅក្នុងរដ្ឋបាលរាជធានី-ខេត្ត ចំនួន ១៤ រួមមាន៖ រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ ព្រះសីហនុ កំពត ត្បូងឃ្មុំ សៀមរាប រតនគិរី ព្រះវិហារ ឧត្តរមានជ័យ និងតាកែវ។ តំបន់គោលដៅអាទិភាពទាំងនេះ ត្រូវបានជ្រើសរើសដោយផ្អែកលើ ស្ថានភាពភូមិសាស្រ្ត តម្រូវការរបស់ប្រជាជន និងឱកាសសម្រាប់ការពង្រឹងប្រព័ន្ធសុខាភិបាល។

**ភាគីរដ្ឋាភិបាល** (Government stakeholders)

**ក្រសួងសុខាភិបាល** (Ministry of Health – MoH): ជាស្ថាប័នដឹកនាំ និងគ្រប់គ្រងប្រព័ន្ធសុខាភិបាលជាចម្បង និងមានការទទួលខុសត្រូវរួម លើការរៀបចំតាក់តែងគោលនយោបាយ ការកំណត់បទប្បញ្ញត្តិ ការធ្វើផែនការ និងការត្រួតពិនិត្យ តាមដានប្រព័ន្ធសុខាភិបាល។ ក្រសួងសុខាភិបាលមានឆន្ទៈខ្ពស់ក្នុងការជំរុញ និងការធានាឱ្យសុខភាពភ្នែក ត្រូវបានបញ្ជ្រាប និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាព ទៅក្នុងកំណែទម្រង់វិស័យសុខាភិបាលដ៏ទូលំទូលាយ រួមមាន ការគ្របដណ្តប់សេវាសុខភាពជាសកល ការធ្វើវិមជ្ឈការ ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យសុខាភិបាល ការកែលម្អគុណភាព និងប្រព័ន្ធព័ត៌មានសុខាភិបាល។ ក្នុងក្របខណ្ឌគម្រោងអភិបាលកិច្ចសុខភាពភ្នែកនេះ ក្រសួងសុខាភិបាលនឹងចូលរួមក្នុងកម្រិតយុទ្ធសាស្រ្ត ក្នុងការតម្រង់ទិសគោលនយោបាយ អនុម័តលើយន្តការអភិបាលកិច្ច និងការសម្របសម្រួល គាំទ្រនិងធានាឱ្យសកម្មភាពគម្រោងស្របតាមយុទ្ធសាស្រ្តជាតិ ព្រមទាំងសម្របសម្រួល និងពង្រឹងទំនាក់ទំនង រវាងភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គម្រោងនេះគាំទ្រដល់ការអនុវត្តអាណត្តិរបស់ក្រសួងសុខាភិបាល តាមរយៈ ការពង្រឹងមុខងារអភិបាលកិច្ចរបស់ស្ថាប័ន ជាជាងការជំនួសតួនាទី និងមុខងាររបស់ក្រសួង។

**កម្មវិធីជាតិសុខភាពភ្នែក** (National Program for Eye Health – NPEH)

កម្មវិធីជាតិសុខភាពភ្នែក ស្ថិតក្រោមក្រសួងសុខាភិបាល និងជាស្ថាប័នដឹកនាំ ផ្នែកបច្ចេកទេស និងសម្របសម្រួល សម្រាប់វិស័យសុខភាពភ្នែកទាំងមូល។ កម្មវិធីជាតិ មានតួនាទីស្នូលក្នុងការដឹកនាំវិស័យសុខភាពភ្នែក ការសម្របសម្រួលជាមួយដៃគូ ការរៀបចំផែនការយុទ្ធសាស្រ្ត ការរៀបចំកំណត់ស្តង់ដារ និងការតាមដានការអនុវត្ត ផែនការយុទ្ធសាស្រ្តជាតិ ស្តីពី ការគ្រប់គ្រង និងបង្ការភាពពិការភ្នែក។ កម្មវិធីជាតិ មានការប្តេជ្ញាចិត្តដោយផ្ទាល់ក្នុងការ លើកកម្ពស់ការសម្របសម្រួល ការកំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ការប្រមូលនិងប្រើប្រាស់ទិន្នន័យសម្រាប់ធ្វើការសម្រេចចិត្ត និងការធានាគុណភាពនៅគ្រប់កម្រិតនៃប្រព័ន្ធ។

ក្នុងគម្រោង អភិបាលកិច្ចសុខភាពភ្នែកនេះ កម្មវិធីជាតិ គឺជាដៃគូរដ្ឋាភិបាលចម្បង ក្នុងការដឹកនាំផ្នែកបច្ចេកទេស កោះប្រជុំ និងសម្របសម្រួលភាគីពាក់ព័ន្ធ ដឹកនាំការចូលរួមនៅថ្នាក់ក្រោមជាតិ និងគាំទ្រដល់ការដាក់បញ្ចូលជាប្រព័ន្ធនូវយន្តការអភិបាលកិច្ច ការធ្វើផែនការ និងការធានាគុណភាពលើវិស័យសុខភាពភ្នែក នៅទូទាំងប្រទេស។

### អាជ្ញាធរសុខាភិបាលថ្នាក់ក្រោមជាតិ ( រដ្ឋបាលរាជធានី-ខេត្ត និងមន្ទីរសុខាភិបាល – PHDs )

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្ត មានតួនាទីកាន់តែសំខាន់ក្នុងការធ្វើផែនការ ការត្រួតពិនិត្យ តាមដាន និងការសម្របសម្រួលសេវាសុខាភិបាល ក្រោមដំណើរការកំណែទម្រង់វិមជ្ឈការ។ ការចូលរួមរបស់ភាគីទាំងនេះ ក្នុងការ កែលម្អការសម្របសម្រួល លើកកម្ពស់សេវា ការគ្រប់គ្រងធនធានមន្ត្រីសុខាភិបាល ការចុះអភិបាលកិច្ច និងការប្រមូលនិងប្រើប្រាស់ទិន្នន័យនៅកម្រិតមូលដ្ឋាន។ គម្រោងអភិបាលកិច្ចសុខភាពភ្នែកនេះ នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ នៅក្នុងខេត្តគោលដៅអាទិភាពទាំង ១៤ ក្នុងការពង្រឹងដំណើរការរៀបចំផែនការ កំណត់ភាពច្បាស់លាស់នូវយន្តការសម្របសម្រួល និងជំរុញ លើកកម្ពស់ ការទំនាក់ទំនង រវាងសេវាសុខភាពភ្នែកនៅថ្នាក់រាជធានី-ខេត្ត ថ្នាក់ស្រុក និងកម្រិតមូលដ្ឋានផ្តល់សេវាផ្ទាល់។ ទន្ទឹមនឹងនេះ មេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្ត នឹងត្រូវបានពិនិត្យលទ្ធភាពពង្រីក និងអនុវត្តបន្ថែមទៅខេត្តផ្សេងទៀត។

### សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ( University of Health Sciences – UHS )

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល គឺជាស្ថាប័នសិក្សាអប់រំ និងបណ្តុះបណ្តាលរបស់ក្រសួងសុខាភិបាល ដែលទទួលខុសត្រូវលើការបណ្តុះបណ្តាលមុនចូលបម្រើការងារសម្រាប់មន្ត្រីវិជ្ជាជីវៈសុខាភិបាល រួមមាន វេជ្ជបណ្ឌិតឯកទេសជំងឺភ្នែក( ចក្ខុបណ្ឌិត ophthalmologists ) ចក្ខុគិលានុបដ្ឋាក-យិកា និងមុខជំនាញវិជ្ជាជីវៈថ្មីៗដែលកំពុងអភិវឌ្ឍ។ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មានជំនាញយ៉ាងខ្លាំងក្នុងការពង្រឹងខ្សែសង្វាក់អប់រំ បណ្តុះបណ្តាល និងអភិវឌ្ឍធនធានមន្ត្រីសុខាភិបាល កែលម្អគុណភាព និងរៀបចំកម្មវិធីបណ្តុះបណ្តាល ឆ្លើយតប ទៅនឹងតម្រូវការរបស់ប្រព័ន្ធសុខាភិបាល។ ក្នុងក្របខណ្ឌគម្រោងអភិបាលកិច្ចសុខភាពភ្នែក UHS គឺជាដៃគូសំខាន់ សម្រាប់ការអភិវឌ្ឍធនធានមន្ត្រីសុខាភិបាល រួមមាន ការអប់រំមុនចូលបម្រើការងារ ការបណ្តុះបណ្តាលបន្តក្នុងពេលបំពេញការងារតាមជំនាញដែលបានកំណត់ ការសិក្សាស្រាវជ្រាវគ្លីនិក( ផ្នែកព្យាបាល ) និងការបង្កើតកម្មវិធីសិក្សាថ្មីៗ ដូចជា ថ្នាក់បរិញ្ញាបត្រចក្ខុមាត្រសាស្ត្រ ( Bachelor of Optometry Degree )ជាដើម។ ជាងនេះទៅទៀត ដំណើរការទទួលស្គាល់គុណភាព និងការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ នឹងត្រូវដឹកនាំតាមប្រព័ន្ធរបស់ក្រសួងសុខាភិបាល និងតាមរយៈស្ថាប័នវិជ្ជាជីវៈ និងស្ថាប័នសិក្សាអប់រំដែលពាក់ព័ន្ធ។ ការចូលរួមរបស់ សាកលវិទ្យាល័យUHS នឹងជួយធានានិរន្តរភាពរយៈពេលវែង និងភាពជាម្ចាស់របស់ជាតិក្នុងការអភិវឌ្ឍធនធានមន្ត្រីសុខាភិបាល។

### អង្គការ និងសមាគម វិជ្ជាជីវៈ: Professional associations

#### សមាគមគ្រូពេទ្យភ្នែកកម្ពុជា ( Cambodian Ophthalmological Society – COS )

សមាគមគ្រូពេទ្យភ្នែកកម្ពុជា តំណាងឱ្យវេជ្ជបណ្ឌិតឯកទេសជំងឺភ្នែក( ចក្ខុបណ្ឌិត ) នៅទូទាំងប្រទេស និងមានតួនាទីសំខាន់ក្នុងការដឹកនាំផ្នែកឯកទេសវិជ្ជាជីវៈ ការបន្តអភិវឌ្ឍវិជ្ជាជីវៈឯកទេស( Continuing Professional Development – CPD ) ក្រមសីលធម៌វិជ្ជាជីវៈ និងអនុវត្តស្តង់ដារគ្លីនិក។ COS ដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សា និងលើកកម្ពស់គុណភាពសេវាថែទាំសុខភាពភ្នែក សមត្ថភាពវិជ្ជាជីវៈ និងការគៀរគរការចូលរួមរបស់អ្នកឯកទេស ក្នុងការអនុវត្តផែនការអាទិភាពជាតិ។ គម្រោងអភិបាលកិច្ចសុខភាពភ្នែក នឹងចូលរួមសហការភាពជាដៃគូជាមួយ COS ដើម្បីគាំទ្រការបន្តអភិវឌ្ឍវិជ្ជាជីវៈ ពង្រឹងការចូលរួមរបស់អ្នកឯកទេសវិជ្ជាជីវៈ ក្នុងការរៀបចំគោលការណ៍ណែនាំ និងដំណើរការធានាគុណភាព ព្រមទាំងលើកកម្ពស់ភាពប្រទាក់ក្រឡាគ្នា រវាងការអនុវត្តវិជ្ជាជីវៈ និងស្តង់ដារជាតិ។

### សមាគមចក្ខុមាត្រការីកម្ពុជា (Optometry Society of Cambodia – OSC)

សមាគមចក្ខុមាត្រការីកម្ពុជា តំណាងឱ្យអ្នកជំនាញផ្នែក កែតម្រូវបញ្ហាកំហុសកំណុំរូបភាព(វាស់និងកាត់វ៉ែនតា) ហើយមានបំណងពង្រីកតួនាទី ដើម្បីតំណាងឱ្យអ្នកប្រកបវិជ្ជាជីវៈ ផ្នែកចក្ខុមាត្រសាស្ត្រ នៅពេលអនាគត។ OSC មានតួនាទីសំខាន់ក្នុងការអភិវឌ្ឍវិជ្ជាជីវៈ ការកំណត់ស្តង់ដារអនុវត្ត និងស្វែងរកការគាំទ្រ សម្រាប់សេវាកែតម្រូវបញ្ហាកំហុសកំណុំរូបភាព(refractive error correction)។ សមាគម មានចំណាប់អារម្មណ៍កាន់តែខ្លាំង លើការបន្តអភិវឌ្ឍវិជ្ជាជីវៈ ការទទួលស្គាល់វិជ្ជាជីវៈ និងការធ្វើសមាហរណកម្មសេវាកែតម្រូវបញ្ហាកំហុសកំណុំរូបភាពទៅក្នុងប្រព័ន្ធសុខភាពភ្នែក។ ក្នុងក្របខណ្ឌនៃគម្រោងនេះ សមាគម នឹងចូលរួមគាំទ្រ ដល់ការអភិវឌ្ឍធនធានមនុស្សផ្នែកសុខភាពភ្នែក ការបន្តអភិវឌ្ឍវិជ្ជាជីវៈ និងការធ្វើសមាហរណកម្មសេវាកែតម្រូវបញ្ហាកំហុសកំណុំរូបភាព(វាស់និងកាត់វ៉ែនតា)ឱ្យកាន់តែប្រសើរឡើងទៅក្នុងប្រព័ន្ធសុខភាពភ្នែកឱ្យកាន់តែទូលំទូលាយ ស្របតាមអាទិភាពផែនការជាតិ។

### ដៃគូពាក់ព័ន្ធផ្សេងទៀត Other Partners:

### មូលនិធិវ៉ែនសាយ អេសស៊ីឡ ឡាក់សូទីកា (OneSight EssilorLuxottica Foundation – OELF)

មូលនិធិវ៉ែនសាយ OELF គឺជាដៃគូសំខាន់ក្នុងប្រព័ន្ធអេកូឡូស៊ីនៃការកែតម្រូវបញ្ហាកំហុសកំណុំរូបភាព ដោយមានជំនាញពិសេស លើការផ្គត់ផ្គង់ ផ្តល់វ៉ែនតា ខ្សែសង្វាក់ផ្គត់ផ្គង់ផលិតផលអុបទិក(កញ្ចក់ និងដងវ៉ែនតា) និងការអភិវឌ្ឍក្នុងវិស័យសុខភាពភ្នែក។ OELF មានឯកទេសខ្ពស់ក្នុងការបង្កើតប្រព័ន្ធប្រកបដោយចីរភាពសម្រាប់សេវាកែតម្រូវបញ្ហាកំហុសកំណុំរូបភាព ការផ្គត់ផ្គង់និងផ្តល់កញ្ចក់និងដងវ៉ែនតាប្រកបដោយគុណភាព និងការពង្រឹងសមត្ថភាពដល់មន្ត្រីសុខភាពភ្នែក។ សម្រាប់គម្រោងអភិបាលកិច្ចសុខភាពភ្នែកនេះ OELF នឹងចូលរួមចំណែកផ្តល់ជំនាញបច្ចេកទេស ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេវាកែតម្រូវកំហុសកំណុំរូបភាព ពង្រឹងទំនាក់ទំនងរវាងសេវាវាស់ និងកាត់វ៉ែនតា និងយន្តការផ្គត់ផ្គង់ផលិតផលអុបទិក(កញ្ចក់ និងដងវ៉ែនតា) ព្រមទាំងធានាឱ្យយន្តការផ្គត់ផ្គង់មានភាពស្របគ្នាជាមួយស្តង់ដារជាតិ និងដំណើរការរៀបចំផែនការនានា។

### ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត Other development partners and NGOs

អង្គការមិនមែនរដ្ឋាភិបាល ជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ជាច្រើន កំពុងចូលរួមក្នុងការផ្តល់សេវាសុខភាពភ្នែក ការបណ្តុះបណ្តាល សកម្មភាពផ្តល់សេវាដល់ប្រជាជននៅតាមសហគមន៍ ការសិក្សាស្រាវជ្រាវ និងការស្វែងរកកិច្ចគាំទ្រ។ ភាគីទាំងនេះមានគោលដៅរួមគ្នា ក្នុងការធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព យន្តការអភិបាលកិច្ចច្បាស់លាស់ អាចព្យាករណ៍បាន និងការធានាឱ្យសកម្មភាពស្របតាមប្រព័ន្ធសុខាភិបាលជាតិ។ គម្រោងអភិបាលកិច្ចសុខភាពភ្នែកនេះ នឹងផ្តល់ជាវេទិកាសម្រាប់ពង្រឹងកិច្ចសហប្រត្តិបត្តិការ កាត់បន្ថយការអនុវត្តដែលបែកខ្ញែកឬភាពដាច់ដោយឡែក និងគាំទ្រដល់ការផ្លាស់ប្តូរ ពី វិធីសាស្ត្រដែលផ្អែកលើគម្រោងដាច់ដោយឡែក ទៅរកក្របខណ្ឌរួមនៃប្រព័ន្ធជាតិ និងដឹកនាំដោយរាជរដ្ឋាភិបាលផ្ទាល់។

### អង្គការតំណាងឱ្យក្រុមប្រជាជនដែលងាយរងគ្រោះ ឬមិនទាន់ទទួលបានសេវាគ្រប់គ្រាន់

**អង្គការដែលផ្តោតលើ សមភាពយេនឌ័រ ភាពសមធម៌ និងបរិយាបន្ន** (Gender Equality, Disability and Social Inclusion – GEDSI) រួមមានអង្គការតំណាងឱ្យជនមានពិការភាព និងក្រុមផ្សេងៗទៀត ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់ នឹងត្រូវបានចូលរួមជាដៃគូយុទ្ធសាស្ត្រក្នុងដំណើរការអនុវត្តគម្រោង ការសម្របសម្រួល និងការរៀនសូត្រពីបទពិសោធន៍អនុវត្តការងារកន្លងមក។

ការចូលរួមរបស់អង្គការទាំងនេះ នឹងជួយគាំទ្រដល់ការធ្វើផែនការដែលមានបរិយាបន្នកាន់តែប្រសើរ ពង្រឹងការយល់ដឹងអំពីឧបសគ្គនានា ដែលប៉ះពាល់ដល់ក្រុមប្រជាជនដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់ និងធានាឱ្យការពិចារណាអំពីសមធម៌ ត្រូវបានបញ្ចូល

ទៅក្នុងវិធីសាស្ត្រអភិបាលកិច្ច ការអភិវឌ្ឍធនធានមន្ត្រីសុខាភិបាល ការធានាគុណភាព និងការផ្ដល់សេវា។ អង្គការទាំងនេះក៏នឹងត្រូវបានអញ្ជើញឱ្យចូលរួមក្នុងយន្តការសម្របសម្រួល និងការពិគ្រោះយោបល់ ដើម្បីគាំទ្រ ការសម្រេចចិត្ត ដំណើរការផ្ដល់មតិយោបល់ និងការពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងផងដែរ។

**សហគមន៍ និងអ្នកប្រើប្រាស់សេវា** Communities and service users:

សហគមន៍ មនុស្សវ័យចាស់ ជនមានពិការភាព ស្ត្រី ប្រជាជនដែលរស់នៅតាមតំបន់ជនបទ និងតំបន់ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់ ព្រមទាំងអង្គការសហគមន៍ពាក់ព័ន្ធរបស់ពួកគេ គឺជា អ្នកទទួលផលចុងក្រោយ ពីការលើកកម្ពស់ការងារអភិបាលកិច្ច និងប្រសិទ្ធភាពនៃដំណើរការប្រព័ន្ធសុខភាពភ្នែក។ ទោះបីពួកគេមិនមែនជាអ្នកអនុវត្តគម្រោងដោយផ្ទាល់ក៏ដោយ បទពិសោធន៍ តម្រូវការ និងទស្សនៈទានរបស់ពួកគេ នឹងត្រូវបានយកមកពិចារណាក្នុងការធ្វើផែនការ ការធានាគុណភាព និងការលើកកម្ពស់សមធម៌ក្នុងការទទួលបានសេវា។ ការចូលរួមជាមួយអង្គការសង្គមស៊ីវិល និងយន្តការកម្រិតសហគមន៍ នឹងត្រូវបានជំរុញ គាំទ្រ ដល់ការពង្រឹងយន្តការសម្របសម្រួល ការប្រមូល និងការប្រើប្រាស់ទិន្នន័យ ដើម្បីធានាថាសេវាសុខភាពភ្នែកអាចឆ្លើយតបបានប្រកបដោយប្រសិទ្ធភាព បំពេញបានតម្រូវការជាក់ស្ដែង របស់ប្រជាជន។

## 1.1.5 គុណតម្លៃរួមចំណែកបន្ថែមពីមូលនិធិហ្វ្រេដហូឡូ

ហេតុផលដែលមូលនិធិហ្វ្រេដហូឡូ (The Foundation) វិនិយោគក្នុងគម្រោង អភិបាលកិច្ចសុខភាពភ្នែក (Eye Health Governance – EHG)នេះ មិនត្រឹមតែផ្ដោតលើការរួមចំណែកគាំទ្រផ្នែកហិរញ្ញវត្ថុតែមួយមុខប៉ុណ្ណោះទេ។ មូលនិធិហ្វ្រេដហូឡូ នាំមកនូវការរួមបញ្ចូលគ្នានៃ បទពិសោធន៍យូរអង្វែងដែលបានប្រត្តិបត្តិការក្នុងប្រទេស ជំនាញ និងភាពខ្លាំងក្នុងការដឹកនាំផ្នែកបច្ចេកទេសលើការពង្រឹងប្រព័ន្ធសុខភាពភ្នែក និងភាពជាដៃគូដែលមានទំនុកចិត្តខ្ពស់ពីរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្នុងវិស័យ។ កត្តាទាំងនេះបានធ្វើឱ្យ មូលនិធិហ្វ្រេដហូឡូ មានតួនាទីជាដៃគូដែលមានឥទ្ធិពលជួយជំរុញការផ្លាស់ប្ដូរ និងកំណែទម្រង់ក្នុងវិស័យសុខភាពភ្នែក។

**មូលនិធិហ្វ្រេដហូឡូ** (The Foundation) បានធ្វើការនៅកម្ពុជាតាំងពីឆ្នាំ ១៩៩៨ ដោយបានវិវត្តពីការផ្ដោតលើការផ្ដល់សេវាផ្ទាល់ទៅជា ការពង្រឹងប្រព័ន្ធ កំណែទម្រង់គោលនយោបាយ ការអភិវឌ្ឍធនធានមន្ត្រីសុខាភិបាល និងការធានាគុណភាព។ វត្តមាន និងបទពិសោធន៍រយៈពេលវែងនេះ នាំអោយមូលនិធិហ្វ្រេដហូឡូ អាចយល់ដឹងយ៉ាងស៊ីជម្រៅអំពីបរិបទប្រព័ន្ធសុខាភិបាល នៅកម្ពុជា ដំណើរការកំណែទម្រង់វិមជ្ឈការ បរិយាកាសនយោបាយ និងសេដ្ឋកិច្ច ពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តគោលនយោបាយ ព្រមទាំងស្ថានភាពជាក់ស្ដែងនៃការអនុវត្តការងារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដោយផ្អែកលើបទពិសោធន៍នេះ The Foundation មានសមត្ថភាពល្អក្នុងការគាំទ្រកិច្ចពិភាក្សាគោលនយោបាយដោយប្រុងប្រយ័ត្ន និងការសម្របសម្រួលខ្ពស់ ធានាឱ្យកំណែទម្រង់បន្សុីគ្នាជាមួយអាទិភាពរបស់រាជរដ្ឋាភិបាល និងបម្លែងយុទ្ធសាស្ត្រទៅជាសកម្មភាពជាក់ស្ដែងដែលអាចអនុវត្តបាន។

គុណតម្លៃបន្ថែមដ៏សំខាន់មួយរបស់ មូលនិធិហ្វ្រេដហូឡូ គឺ ជំនាញបច្ចេកទេស លើប្រព័ន្ធសុខភាពភ្នែកទាំងមូល រួមមាន អភិបាលកិច្ច ការរៀបចំផែនការអភិវឌ្ឍធនធានមន្ត្រីសុខភាពភ្នែក ការធ្វើសមាហរណកម្មសេវា ការលើកកម្ពស់គុណភាព ការប្រមូលនិងការប្រើប្រាស់ទិន្នន័យសម្រាប់ការសម្រេចចិត្ត។ ផ្អែកលើមេរៀន និងបទពិសោធន៍ពីការវិនិយោគ និងការអនុវត្តគម្រោងកន្លងមក ដូចជាគម្រោងNSEE, SEE IPEC និងគម្រោងSURES មូលនិធិហ្វ្រេដហូឡូ បានបង្ហាញពីសមត្ថភាពក្នុងការគាំទ្រដល់ការរៀបចំ និងការអនុវត្ត ស្តង់ដារគុណភាព ក្របខណ្ឌត្រួតពិនិត្យតាមដាន និងសូចនាករវាស់វែងលទ្ធផល រួមមាន ការត្រួតពិនិត្យតាមដានលទ្ធផលនៃព្យាបាលជំងឺបាយភ្នែក ការធានាគុណភាពសេវាកែតម្រូវកំហុសកំណុំរូបភាព និងសូចនាករគ្រប់ដណ្ដប់ជំងឺភ្នែកប្រកបដោយប្រសិទ្ធភាព។ សមត្ថភាព និងជំនាញរបស់ស្ថាប័ន មូលនិធិហ្វ្រេដហូឡូនេះ អាចឱ្យដៃគូរដ្ឋាភិបាល មិនត្រឹមតែអាចពង្រីកវិសាលភាពនៃការផ្ដល់សេវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាច លើកកម្ពស់សុវត្ថិភាព គុណភាព ការទទួលខុសត្រូវ និងនិរន្តរភាពនៃសេវាសុខភាពភ្នែក ផងដែរ។

**មូលនិធិហ្វ្រេដហូឡូ** (The Foundation) ក៏ផ្តល់តម្លៃបន្ថែមផងដែរតាមរយៈ តួនាទីជាអ្នកសម្របសម្រួល ការគៀរគរ និងការកោះប្រជុំភាគីពាក់ព័ន្ធ។ មូលនិធិហ្វ្រេដហូឡូ មានបទពិសោធន៍ និងសមត្ថភាព ក្នុងការគៀរគរ សម្របសម្រួលក្រសួងពាក់ព័ន្ធ សមាគមវិជ្ជាជីវៈ អាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ មកធ្វើការរួមគ្នា ជុំវិញអាទិភាពរួម។ តាមរយៈតួនាទីនេះ The Foundation បន្តគាំទ្រ ការពង្រឹងការសម្របសម្រួលក្នុងវិស័យសុខភាពភ្នែក កាត់បន្ថយការអនុវត្តដាច់ដោយឡែក លើកកម្ពស់ការរៀនសូត្រពីបទពិសោធន៍រវាងស្ថាប័ននិងស្ថាប័ន និងពង្រឹងយន្តការអភិបាលកិច្ចនៅថ្នាក់ជាតិ និងថ្នាក់រាជធានី/ខេត្ត ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល។

ការរួមចំណែកសំខាន់មួយទៀតរបស់ មូលនិធិហ្វ្រេដហូឡូ គឺ សមត្ថភាពក្នុងការច្នៃតម្រូវពីភស្តុតាងជាសកល និងការអនុវត្តល្អៗ ឱ្យសមស្របនឹងបរិបទនៅកម្ពុជា។ តាមរយៈបណ្តាញជំនាញបច្ចេកទេសជាសកលរបស់ខ្លួន The Foundation អាចនាំមកនូវវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងវិស័យ ដូចជា ការថែទាំសុខភាពភ្នែកដែលផ្តោតលើប្រជាជនជាមូលដ្ឋាន (integrated people-centred eye care) ការលើកកម្ពស់គុណភាពជាបន្តបន្ទាប់ ក្របខណ្ឌសមត្ថភាពវិជ្ជាជីវៈរបស់មន្ត្រីសុខភាពភ្នែក និងការផ្តល់សេវាប្រកបដោយបរិយាបន្ន។ វិធីសាស្ត្រទាំងនេះ នឹងត្រូវបានកែសម្រួល ឱ្យសមស្របទៅនឹងបរិបទមូលដ្ឋាន បន្សុីគ្នាជាមួយគោលនយោបាយជាតិ និងអាចបញ្ចូលជាផ្នែកមួយនៃប្រព័ន្ធ និងស្ថាប័នជាតិបាន។

ជាចុងក្រោយ មូលនិធិហ្វ្រេដហូឡូ អាចផ្តល់ ឥទ្ធិពលជំរុញលើសពីធនធានផ្ទាល់របស់ខ្លួន។ ភាពគួរឱ្យទុកចិត្តរបស់ មូលនិធិហ្វ្រេដហូឡូ ជាមួយរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ ការចូលរួមចំណែកក្នុងបណ្តាញសុខភាពភ្នែក ទាំងថ្នាក់តំបន់ និងថ្នាក់សកល ព្រមទាំងបទពិសោធន៍ក្នុងការកៀរគរធនធាន និងអភិវឌ្ឍភាពជាដៃគូ អាចជួយទាក់ទាញ ថវិកាបន្ថែម ការគាំទ្រជាធនធាន ឬសម្ភារៈ ជំនួយមនុស្សធម៌ និងកិច្ចសហការផ្នែកបច្ចេកទេស ពីដៃគូផ្សេងៗជាច្រើន។ កត្តានេះអាចជួយបង្កើនផលជះវិជ្ជមាន នៃការវិនិយោគ និងគាំទ្រដល់ការផ្លាស់ប្តូរឆ្ពោះទៅរក ភាពជាម្ចាស់កាន់តែខ្លាំងរបស់រាជរដ្ឋាភិបាល និងនិរន្តរភាពរបស់ប្រព័ន្ធជាតិ។

តាមរយៈការរួមចំណែកទាំងអស់ខាងលើ **មូលនិធិហ្វ្រេដហូឡូ** មានតួនាទីសំខាន់ជាអ្នក បង្កើតលក្ខខណ្ឌអំណោយផល និងគាំទ្រការអនុវត្ត សម្រាប់គម្រោង អភិបាលកិច្ចសុខភាពភ្នែក — សំដៅលើការអនុវត្តដោយគាំទ្រការដឹកនាំរបស់រាជរដ្ឋាភិបាល ពង្រឹងប្រព័ន្ធជាតិ និងធានាថាកំណែទម្រង់ដែលបានអនុវត្តនឹងនាំទៅរកការកែលម្អប្រកបដោយនិរន្តរភាព លើ គុណភាព សមធម៌ និងប្រសិទ្ធភាពនៃប្រព័ន្ធ និងសេវាសុខភាពភ្នែកនៅកម្ពុជា។

# 2. អំពីគម្រោង

## 2.1 គោលបំណង និងសមិទ្ធផលរំពឹងទុក

### គោលបំណង

គោលបំណងនៃគម្រោង អភិបាលកិច្ចសុខភាពភ្នែក (Eye Health Governance – EHG) គឺរួមចំណែកដល់ការពង្រឹងប្រព័ន្ធសុខភាពភ្នែករបស់កម្ពុជាប្រកបដោយនិរន្តរភាព លើផ្នែកអភិបាលកិច្ច ការដឹកនាំ និងគ្រប់គ្រងវិស័យសុខភាពភ្នែក និងការសម្របសម្រួលប្រព័ន្ធ ឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការគាំទ្រដល់ការអភិវឌ្ឍ ធនធានមន្ត្រីសុខភាពភ្នែក ពេញដោយសមត្ថភាព ប្រត្តិបត្តការងារតាមក្រមវិជ្ជាជីវៈត្រឹមត្រូវ មានការគ្រប់គ្រង និងបែងចែកធនធានមន្ត្រីប្រកបដោយសមធម៌។

ផ្អែកតាមវិធីសាស្ត្រដែលដឹកនាំដោយរាជរដ្ឋាភិបាល គម្រោងមានគោលបំណងឆ្លើយតបចំពោះឧបសគ្គនៃប្រព័ន្ធ ដែលនាំអោយ មានកម្រិត លើគុណភាព សមធម៌ និងនិរន្តរភាពនៃសេវាសុខភាពភ្នែក ជាពិសេស ភាពខ្សោយនៃក្របខណ្ឌនិយ័តកម្ម (ប្រត្តិបត្តការងារតាមក្រមវិជ្ជាជីវៈត្រឹមត្រូវ) ការសម្របសម្រួលមិនរឹងមាំ ភាពមិនស្មើគ្នានៃសមត្ថភាពនិងការបែងចែកធនធានមន្ត្រី និងភាពខុសគ្នានៃគុណភាពផ្តល់សេវានៅតាមមូលដ្ឋានសុខាភិបាលនៅតាមបណ្តាខេត្ត។ លើសពីនេះ ការពង្រឹង រចនាសម្ព័ន្ធអភិបាលកិច្ច សមត្ថភាពស្ថាប័ន និងយន្តការគណនេយ្យភាព គម្រោងនឹងរួមចំណែកជានាឱ្យការអនុវត្តគោលនយោបាយ និងស្តង់ដារជាតិស្តីពីសុខភាពភ្នែកមានភាពដូចៗគ្នា និងមានប្រសិទ្ធភាពកាន់តែប្រសើរឡើង នៅក្នុងប្រព័ន្ធសុខាភិបាលដែល ធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាមជ្ឈមណ្ឌល។

គម្រោងអភិបាលកិច្ចសុខភាពភ្នែក នឹងគាំទ្រដល់ការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការកាត់បន្ថយភាពពិការភ្នែក និងគំឃើញថយចុះ ដែលអាចបង្ការ ឬជៀសវាងបាន ដោយធានាថា សុខភាពភ្នែកត្រូវបានបញ្ចូលយ៉ាងមានប្រសិទ្ធភាពទៅក្នុងប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ហើយសេវាសុខភាពភ្នែកត្រូវបានផ្តល់ជូនប្រជាជនប្រកបដោយ សមធម៌ គុណភាពខ្ពស់ និងមាននិរន្តរភាព។

### សមិទ្ធផលរំពឹងទុក (End of Project Outcome)

គម្រោងមានគោលបំណងសម្រេចឱ្យបាននូវ ប្រព័ន្ធសុខភាពភ្នែកដែលដឹកនាំដោយរាជរដ្ឋាភិបាល មានភាពធន់ អភិបាលកិច្ចល្អ មន្ត្រីផ្នែកសុខភាពភ្នែកមានសមត្ថភាព និងការគ្រប់គ្រងនិងបែងចែកមន្ត្រីសុខភាពភ្នែកមានសមភាព នាំឱ្យការផ្តល់សេវាសុខភាពភ្នែក មានលក្ខខណៈរួមបញ្ចូល មានគុណភាពខ្ពស់ និងមានសមធម៌ នៅទូទាំងប្រទេស។

### គម្រោងជោគជ័យល្អីកណា៖

- ការដឹកនាំនិងគ្រប់គ្រង ការសម្របសម្រួល និងការទទួលខុសត្រូវ ក្នុងវិស័យសុខភាពភ្នែក មានភាពធន់ និងគត់មុត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- គុណភាពសេវា និយ័តកម្ម(ការប្រត្តិបត្តិក្រមវិជ្ជាជីវៈ) និងការត្រួតពិនិត្យតាមដាន សេវាសុខភាពភ្នែកទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន មានភាពប្រសើរឡើង។
- ការងារសុខភាពភ្នែក ត្រូវបានបញ្ចូលទៅក្នុង ក្របខណ្ឌស្តង់ដារនៃការទទួលស្គាល់គុណភាពរបស់ក្រសួងសុខាភិបាល។
- មន្ត្រីផ្នែកសុខភាពភ្នែកមានសមត្ថភាពកាន់តែប្រសើរ និងការគ្រប់គ្រងនិងបែងចែកមន្ត្រីសុខភាពភ្នែកសមស្រប និងប្រកបដោយសមធម៌នៅតាមបណ្តាខេត្ត។
- សុខភាពភ្នែកត្រូវបានយកចិត្តទុកដាក់និងដាក់បញ្ចូល ទៅក្នុង ប្រព័ន្ធហិរញ្ញប្បទានសុខាភិបាល ប្រព័ន្ធព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល (HMIS/DHIS2) និងប្រព័ន្ធគាំពារសង្គមនានា និងអនុវត្តកាន់តែប្រសើរឡើង។

- មានវឌ្ឍនភាពជាក់ស្តែង ឆ្ពោះទៅរកការកាត់បន្ថយភាពពិការភ្នែក និងទប់ស្កាត់បញ្ហាគំហើញថយចុះ ដែលអាចបង្ការ ឬជៀសវាងបាន ជាពិសេស ក្នុងចំណោមប្រជាជននៅតាមតំបន់ជនបទ តំបន់ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់ និងក្រុមប្រជាជនងាយរងគ្រោះ។

## 2.2 សមិទ្ធផល និងលទ្ធផលរំពឹងទុក

**<u>សមិទ្ធផលទី១</u>៖ អភិបាលកិច្ច ការសម្របសម្រួល និងការដឹកនាំ-គ្រប់គ្រង ត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ការរៀបចំផែនការ ការកំណត់បទប្បញ្ញត្តិ(ក្រមប្រត្តិបត្តិវិជ្ជាជីវៈ) គុណភាព និងការទទួលខុសត្រូវខ្ពស់ក្នុងវិស័យសុខភាពភ្នែក។**

**លទ្ធផលរំពឹងទុក** (Expected outputs):

1. យន្តការសម្របសម្រួល និងការដឹកនាំ-គ្រប់គ្រងវិស័យសុខភាពភ្នែកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹងក្រោមការដឹកនាំរបស់ក្រសួងសុខាភិបាល។
2. អាទិភាពសុខភាពភ្នែក ត្រូវបានដាក់បញ្ចូលទៅក្នុង គោលនយោបាយ ផែនការ និងក្របខណ្ឌហិរញ្ញប្បទាន របស់រាជរដ្ឋាភិបាល (ក្នុងវិស័យពាក់ព័ន្ធ រួមមាន សុខាភិបាល អប់រំ កិច្ចគាំពារសង្គម យេនឌ័រ និងពិការភាព)។
3. ការធ្វើផែនការ ការចុះអភិបាលកិច្ច និងការត្រួតពិនិត្យ តាមដានលទ្ធផលការងារ ផ្នែកសុខភាពភ្នែក ត្រូវបានរៀបចំឱ្យមានស្តង់ដាររួម និងបានបញ្ចូលទៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាល។
4. ប្រព័ន្ធធានាគុណភាពថ្នាក់ជាតិ ការគ្រប់គ្រងផ្នែកគ្លីនិក និងបទប្បញ្ញត្តិ(ក្រមប្រត្តិបត្តិវិជ្ជាជីវៈ) / ការត្រួតពិនិត្យ សេវាសុខភាពភ្នែកក្នុងវិស័យសាធារណៈ និងឯកជន ត្រូវបានពង្រឹង។

**<u>លទ្ធផលទី២</u>៖ មន្ត្រីផ្នែកសុខភាពភ្នែកមានសមត្ថភាព ការគ្រប់គ្រងនិងបែងចែកមន្ត្រីប្រកបដោយសមធម៌ ត្រូវបានអភិវឌ្ឍ និងដាក់បញ្ចូល ជាផ្នែកមួយនៃប្រព័ន្ធរបស់ជាតិប្រកបដោយនិរន្តរភាព។**

**លទ្ធផលរំពឹងទុក** (Expected outputs)៖

1. ការអប់រំ និងការបណ្តុះបណ្តាលធនធានមនុស្សផ្នែកសុខភាពភ្នែកមុនចូលបម្រើការងារ ត្រូវបានពង្រឹង និងដាក់បញ្ចូលជាប្រព័ន្ធ រួមទាំងការទទួលស្គាល់គុណភាពជាផ្លូវការ។
2. ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្ត ការបង្វឹក ការចុះអភិបាលកិច្ច ការផ្លាស់ប្តូរចំណេះដឹង និងការរៀនសូត្រពីបទពិសោធន៍ ត្រូវបានបង្កើត និងដំណើរការប្រកបដោយប្រសិទ្ធភាព។
3. ធនធានមន្ត្រីសុខភាពភ្នែក ត្រូវបានបង្កើនឱ្យមានចំនួនគ្រប់គ្រាន់ និងបែងចែកប្រកបដោយសមធម៌ តាមរយៈ ការធ្វើការវាយតម្លៃ និងធ្វើផែនទីបង្ហាញផ្លូវលើការបណ្តុះបណ្តាលជាក់លាក់។

**<u>លទ្ធផលទី៣</u>៖ ប្រព័ន្ធគាំទ្រ នវានុវត្តន៍បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធ ដែលអំណោយផល ត្រូវបានពង្រឹង ដើម្បីគាំទ្រដល់ការងារអភិបាលកិច្ច ប្រសិទ្ធភាពការងាររបស់មន្ត្រី និងគុណភាពសេវាសុខភាពភ្នែកប្រកបដោយប្រសិទ្ធិភាព។**

**លទ្ធផលរំពឹងទុក** (Expected outputs):

1. ប្រព័ន្ធសុខាភិបាលឌីជីថល សេវាពិគ្រោះ និងពិនិត្យជំងឺភ្នែកពីចម្ងាយ (Tele-ophthalmology) និងប្រព័ន្ធប្រមូល និងកត់ត្រាទិន្នន័យ ត្រូវបានដាក់បញ្ចូលទៅក្នុងការផ្តល់សេវាប្រចាំថ្ងៃ ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពសេវាសុខភាពភ្នែក។

2. មុខងារ និងសមត្ថភាពប្រើប្រាស់ឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗសម្រាប់សុខភាពភ្នែក ត្រូវបានពង្រឹងតាមរយៈ ការធ្វើសវនកម្មជាប្រព័ន្ធ ការថែទាំជាប្រចាំ និងការគ្រប់គ្រង ឧបករណ៍និងសម្ភារបច្ចេកទេស។

## គម្រោងអភិបាលកិច្ចសុខភាពភ្នែក — ទិដ្ឋភាពសង្ខេបគម្រោង ត្រឹមមួយទំព័រ

**គោលដៅ**

ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្ដប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្ដោតលើប្រជាជនជាចម្បង។

**សមិទ្ធផល សម្រេចបាន**

នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្ដល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។

| | | | |
|---|---|---|---|
| **សមិទ្ធផលរំពឹងទុក** | អភិបាលកិច្ច ការសម្របសម្រួល និងការដឹកនាំ-គ្រប់គ្រង ត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ការរៀបចំផែនការ ការកំណត់បទប្បញ្ញត្តិ(ក្រមប្រតិបត្តិវិជ្ជាជីវៈ) គុណភាព និងការទទួលខុសត្រូវខ្ពស់ក្នុងវិស័យសុខភាពភ្នែក។ | មន្ត្រីផ្នែកសុខភាពភ្នែកមានសមត្ថភាព ការគ្រប់គ្រងនិងបែងចែកមន្ត្រីប្រកបដោយសមធម៌ ត្រូវបានអភិវឌ្ឍ និងដាក់បញ្ចូល ជាផ្នែកមួយនៃប្រព័ន្ធរបស់ជាតិប្រកបដោយនិរន្តរភាព។ | ប្រព័ន្ធគាំទ្រ នវានុវត្តន៍បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធ ដែលអំណោយផល ត្រូវបានពង្រឹង ដើម្បីគាំទ្រដល់ការងារអភិបាលកិច្ច ប្រសិទ្ធភាពការងាររបស់មន្ត្រី និងគុណភាពសេវាសុខភាពភ្នែកប្រកបដោយប្រសិទ្ធិភាព។ |
| **លទ្ធផលរំពឹងទុក** | 1. យន្តការសម្របសម្រួល និងការដឹកនាំ-គ្រប់គ្រងវិស័យសុខភាពភ្នែកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង ក្រោមការដឹកនាំរបស់ក្រសួងសុខាភិបាល។<br><br>2. អាទិភាពសុខភាពភ្នែក ត្រូវបានដាក់បញ្ចូលទៅក្នុង គោលនយោបាយ ផែនការ និងក្របខណ្ឌហិរញ្ញប្បទាន របស់រាជរដ្ឋាភិបាល (ក្នុងវិស័យពាក់ព័ន្ធ រួមមាន សុខាភិបាល អប់រំ កិច្ចគាំពារសង្គម យេនឌ័រ និងពិការភាព)។<br><br>3. ការធ្វើផែនការ ការចុះអភិបាលកិច្ច និងការត្រួតពិនិត្យ តាមដានលទ្ធផលការងារ ផ្នែកសុខភាពភ្នែក ត្រូវបានរៀបចំឱ្យមានស្តង់ដារួម និងបានបញ្ចូលទៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាល។<br><br>4. ប្រព័ន្ធធានាគុណភាពថ្នាក់ជាតិ ការគ្រប់គ្រងផ្នែកគ្លីនិក និងបទប្បញ្ញត្តិ(ក្រមប្រតិបត្តិវិជ្ជាជីវៈ) / ការត្រួតពិនិត្យ សេវាសុខភាពភ្នែកក្នុងវិស័យសាធារណៈ និងឯកជន ត្រូវបានពង្រឹង។ | 1. ការអប់រំ និងការបណ្ដុះបណ្ដាលធនធានមនុស្សផ្នែកសុខភាពភ្នែកមុនចូលបម្រើការងារ ត្រូវបានពង្រឹង និងដាក់បញ្ចូលជាប្រព័ន្ធ រួមទាំងការទទួលស្គាល់គុណភាពជាផ្លូវការ។<br><br>2. ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្ត ការបង្វឹក ការចុះអភិបាលកិច្ច ការផ្លាស់ប្ដូរចំណេះដឹង និងការរៀនសូត្រពីបទពិសោធន៍ ត្រូវបានបង្កើត និងដំណើរការប្រកបដោយប្រសិទ្ធភាព។<br><br>3. ធនធានមន្ត្រីសុខភាពភ្នែក ត្រូវបានបង្កើនឱ្យមានចំនួនគ្រប់គ្រាន់ និងបែងចែកប្រកបដោយសមធម៌ តាមរយៈ ការធ្វើការវាយតម្លៃ និងធ្វើផែនទីបង្ហាញផ្លូវលើការបណ្ដុះបណ្ដាលជាក់លាក់។ | 1. ប្រព័ន្ធសុខាភិបាលឌីជីថល សេវាពិគ្រោះ និងពិនិត្យជំងឺភ្នែកពីចម្ងាយ (Tele-ophthalmology) និងប្រព័ន្ធប្រមូលនិងកត់ត្រាទិន្នន័យ ត្រូវបានដាក់បញ្ចូលទៅក្នុងការផ្ដល់សេវាប្រចាំថ្ងៃ ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពសេវាសុខភាពភ្នែក។<br><br>2. មុខងារ និងសមត្ថភាពប្រើប្រាស់ឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗសម្រាប់សុខភាពភ្នែក ត្រូវបានពង្រឹង តាមរយៈ ការធ្វើសវនកម្មជាប្រព័ន្ធ ការថែទាំជាប្រចាំ និងការគ្រប់គ្រង ឧបករណ៍និងសម្ភារបច្ចេកទេស។ |

## 2.3 សេចក្តីសន្និដ្ឋាន និងយុទ្ធសាស្ត្រ

គម្រោងអភិបាលកិច្ចសុខភាពភ្នែក ត្រូវបានគាំទ្រដោយទ្រឹស្តីនៃការផ្លាស់ប្តូរដែលផ្តោតលើការពង្រឹងប្រព័ន្ធ ដែលទទួលស្គាល់ថា ការលើកកម្ពស់សុខភាពភ្នែកប្រកបដោយនិរន្តរភាពនៅកម្ពុជា ពឹងផ្អែកលើរបៀបដែលប្រព័ន្ធត្រូវបានគ្រប់គ្រង មានធនធានមនុស្សគ្រប់គ្រាន់ កំណត់បទប្បញ្ញត្តិច្បាស់លាស់ ផ្តល់ហិរញ្ញប្បទាន និងការគាំទ្រ ជាជាងផ្អែកលើការផ្តល់សេវា ឬការបណ្តុះបណ្តាលដាច់ដោយឡែកតែមួយមុខ។

គម្រោងសន្និដ្ឋានថា ប្រសិនបើសុខភាពភ្នែកត្រូវបានបញ្ជ្រាបយ៉ាងមានប្រសិទ្ធភាពទៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាល រួមមាន គោលនយោបាយ ការរៀបចំផែនការ ហិរញ្ញប្បទាន ការធានាគុណភាព ការអភិវឌ្ឍធនធានមនុស្ស និងប្រព័ន្ធព័ត៌មាន នោះការកែលម្អគុណភាពសេវា សមធម៌ និងនិរន្តរភាព អាចសម្រេចបានក្នុងទ្រង់ទ្រាយធំ និងរក្សាបានក្រោយពេលបញ្ចប់គម្រោង។

បទអន្តរាគមន៍ជាច្រើនដែលបានស្នើឡើងក្រោមគម្រោង អភិបាលកិច្ចសុខភាពភ្នែក ត្រូវបានរៀបចំដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែងពង្រឹងប្រព័ន្ធ ភាពជាដៃគូ និងបទពិសោធន៍អនុវត្តដែលមានស្រាប់ ពីគំនិតផ្តួចផ្តើមសុខភាពភ្នែកមុនៗ និងកំពុងបន្តនៅកម្ពុជា។ ដូច្នេះ សកម្មភាពមួយចំនួន គឺជាការបន្ត ការពង្រីកវិសាលភាព ឬការដាក់បញ្ចូលជាផ្លូវការតាមស្ថាប័ន នូវការងារដែលកំពុងអនុវត្តជាមួយរាជរដ្ឋាភិបាល និងដៃគូក្នុងវិស័យរួចមកហើយ មិនមែនជាបទអន្តរាគមន៍ថ្មីទាំងស្រុងនោះទេ។

ដោយហេតុនេះ គម្រោងធ្វើការវិនិយោគជាប្រព័ន្ធក្នុងផ្នែកសំខាន់ៗចំនួនបី គឺ៖ ១) ការដឹកនាំ-គ្រប់គ្រង និងការសម្របសម្រួលរបស់រាជរដ្ឋាភិបាល; ២) ការអភិវឌ្ឍធនធានមនុស្សដែលត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃស្ថាប័ន; និង ៣) ប្រព័ន្ធគាំទ្រ នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធដែលអំណោយផល។

ខណៈដែលអភិបាលកិច្ច ធនធានមនុស្ស និងប្រព័ន្ធគាំទ្រ មានលក្ខណៈគាំទ្រគ្នាទៅវិញទៅមក គម្រោងទទួលស្គាល់ថា មុខងារអភិបាលកិច្ច និងការដឹកនាំ-គ្រប់គ្រងដែលត្រូវបានពង្រឹង គឺជាលក្ខខណ្ឌអំណោយផលដ៏សំខាន់សម្រាប់ការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព ការកែលម្អគុណភាព និងការធ្វើសមាហរណកម្មប្រព័ន្ធរយៈពេលវែង។

ផ្លូវប្តូរទាំងនេះ ត្រូវបានរៀបចំឱ្យមានលក្ខណៈពឹងផ្អែកគ្នា និងអភិវឌ្ឍជាបន្តបន្ទាប់ ជាជាងដំណើរការតាមលំដាប់ត្រង់។

### ដំណើរការដើម្បីសម្រេចបានលទ្ធផលទី១៖ ពង្រឹងអភិបាលកិច្ច ការសម្របសម្រួល និងការដឹកនាំ-គ្រប់គ្រងវិស័យសុខភាពភ្នែក

គម្រោងទទួលស្គាល់ថា ការសម្របសម្រួលដែលនៅបែកខ្ញែក ការត្រួតពិនិត្យ និយ័តកម្ម នៅមានកម្រិតខ្សោយ ការអនុវត្តការធានាគុណភាពមិនទៀងទាត់ និងការធ្វើសមាហរណកម្មសុខភាពភ្នែកទៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាលទូទៅនៅមានកម្រិត គឺជាឧបសគ្គស្នូលដែលរារាំងដល់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា។

#### ទស្សនៈនៃការផ្លាស់ប្តូរ៖

ប្រសិនបើយន្តការសម្របសម្រួលសុខភាពភ្នែកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឱ្យមានលក្ខណៈផ្លូវការ និងដំណើរការក្រោមការដឹកនាំរបស់ក្រសួងសុខាភិបាល ហើយប្រសិនបើតួនាទី អាណត្តិ និងរចនាសម្ព័ន្ធទទួលខុសត្រូវត្រូវបានកំណត់យ៉ាងច្បាស់ តាមរយៈក្រុមការងារបច្ចេកទេស ក្រុមគ្រប់គ្រង និងដំណើរការសម្របសម្រួលជាប្រចាំ នោះភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើវិស័យសុខភាពភ្នែកនឹងត្រូវបានពង្រឹង។

នៅពេលអាទិភាពសុខភាពភ្នែកត្រូវបានដាក់បញ្ចូលជាប្រព័ន្ធទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ ក្របខណ្ឌហិរញ្ញប្បទាន និងកញ្ចប់សេវា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា CPA/MPA យន្តការគាំពារសុខភាពសង្គម និងថវិកាវិមជ្ឈការ នោះសុខភាពភ្នែកនឹងក្លាយជាផ្នែកមួយនៃការផ្តល់សេវាសាធារណៈជាប្រចាំ និងមានប្រភពហិរញ្ញប្បទានគាំទ្ររឹងមាំ។

ដំបូង គម្រោងនឹងគាំទ្រដល់ការបង្កើត ឬការដាក់បញ្ចូលក្រុមការងារបច្ចេកទេសអនុវិស័យសុខភាពភ្នែកនៅកម្រិតមន្ទីរសុខាភិបាលរាជធានី-ខេត្ត ដើម្បីលើកកម្ពស់ការសម្របសម្រួល ការត្រួតពិនិត្យតាមដាន និងការតាមដានការអនុវត្តសុខភាពភ្នែក ព្រមទាំងពង្រឹងការចូលរួម និងភាពជាម្ចាស់របស់ភាគីពាក់ព័ន្ធ។ តាមពេលវេលា និងនៅពេលប្រព័ន្ធថ្នាក់ខេត្តមានភាពរឹងមាំ គម្រោងនឹងគាំទ្រដល់ការធ្វើសមាហរណកម្មមុខងារសម្របសម្រួលសុខភាពភ្នែកជាបន្តបន្ទាប់ទៅក្នុងយន្តការសម្របសម្រួលសុខាភិបាលថ្នាក់ខេត្តទូលំទូលាយ ដើម្បីពង្រឹងការដាក់បញ្ចូលជាប្រព័ន្ធ និងនិរន្តរភាពរយៈពេលវែងនៅក្នុងប្រព័ន្ធសុខាភិបាល។ ការផ្លាស់ប្តូរនេះនឹងត្រូវបានពង្រឹងបន្ថែមនៅពេល៖

- ការរៀបចំផែនការ និងការចុះអភិបាលកិច្ចគាំទ្រផ្នែកសុខភាពភ្នែក ត្រូវបានរៀបចំឱ្យមានស្តង់ដាររួម តាមរយៈផែនការយុទ្ធសាស្ត្រជាតិសុខភាពភ្នែក ផែនទីបង្ហាញផ្លូវថ្នាក់ក្រោមជាតិ ការអង្កេតរហ័សថ្នាក់ជាតិ (RAAB) និងការវាយតម្លៃសុខភាពភ្នែក។
- ការត្រួតពិនិត្យតាមដានលទ្ធផលការងារ និងការប្រមូលទិន្នន័យ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ HMIS/DHIS-2 របស់ក្រសួងសុខាភិបាល និងយន្តការចុះអភិបាលកិច្ចគាំទ្រជាប្រចាំ។
- ការផ្លាស់ប្តូរទាំងនេះ នឹងផ្លាស់ប្តូរវិស័យសុខភាពភ្នែក ពីការអនុវត្តដែលដាច់ដោយឡែក ទៅរកការអនុវត្តជាប្រព័ន្ធដែលមានភាពប្រទាក់ក្រឡាគ្នា មានការទទួលខុសត្រូវ និងមាននិយ័តកម្មច្បាស់លាស់។

### ភស្តុតាង និងមេរៀនជាបទពិសោធន៍

- បទពិសោធន៍របស់កម្ពុជា ក្រោមគម្រោង NSEE និង SEE-IPEC បានបង្ហាញថា ការគាំទ្រដល់ការពង្រឹង ឬការធ្វើសមាហរណកម្មក្រុមការងារបច្ចេកទេសអនុវិស័យ ដំណើរការរៀបចំផែនការជាតិ និងការធ្វើសមាហរណកម្ម CPA/MPA បាននាំឱ្យមានភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកាន់តែរឹងមាំ និងការផ្តល់សេវាកាន់តែមានភាពទៀងទាត់។
- មេរៀនពីគំនិតផ្តួចផ្តើមលើកកម្ពស់គុណភាពគ្លីនិក ដូចជា ការត្រួតពិនិត្យតាមដានលទ្ធផលក្រោយបកបាយភ្នែក (CSOM) ការធ្វើសវនកម្មគុណភាព និងការពិនិត្យពិភាក្សារវាងក្រុមវិជ្ជាជីវៈ បង្ហាញថា លទ្ធផលមានភាពប្រសើរឡើងនៅពេលស្តង់ដារ និងការចុះអភិបាលកិច្ចគាំទ្រ ត្រូវបានដាក់បញ្ចូលជាប្រព័ន្ធទៅក្នុងប្រព័ន្ធរបស់ក្រសួងសុខាភិបាល។
- ភស្តុតាងពីប្រព័ន្ធសុខាភិបាលរបស់អង្គការសុខភាពពិភពលោក និងគោលការណ៍ IPEC បញ្ជាក់ថា ការធ្វើសមាហរណកម្មសុខភាពភ្នែកប្រកបដោយប្រសិទ្ធភាពទៅក្នុងការផ្តល់សេវាសុខាភិបាល គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ពង្រីកសេវាថែទាំភ្នែកដែលមានគុណភាព។

## ដំណើរការដើម្បីសម្រេចបានលទ្ធផលទី២៖ ធនធានមនុស្សប្រកបដោយសមត្ថភាព នឹងត្រូវបាន ដាក់បញ្ចូលនិងការបែងចែកជាប្រព័ន្ធ

គម្រោងទទួលស្គាល់ថា បញ្ហាប្រឈមផ្នែកធនធានមនុស្សនៅកម្ពុជា រួមមាន កង្វះខាតមន្ត្រីជំនាញសុខភាពភ្នែក គុណភាពអប់រំនៅមិនទាន់ស្មើគ្នា ឱកាសអភិវឌ្ឍវិជ្ជាជីវៈបន្តនៅមានកម្រិត ការរៀបចំផែនការពង្រាយមន្ត្រីនៅមានកម្រិត និងការរក្សាមន្ត្រីនៅតំបន់ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់ ដែលបណ្តាលឱ្យមន្ត្រីសុខភាពភ្នែកភាគច្រើនប្រមូលផ្តុំនៅតាមទីប្រជុំជន។

### ទស្សនៈនៃការផ្លាស់ប្តូរ

ប្រសិនបើកម្មវិធីអប់រំ និងបណ្តុះបណ្តាលមុនចូលបម្រើការងារ ត្រូវបានពង្រឹង រៀបចំឱ្យមានស្តង់ដាររួម និងទទួលស្គាល់គុណភាពជាផ្លូវការនៅក្នុងស្ថាប័នជាតិ រួមមាន សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងមន្ទីរពេទ្យបណ្តុះបណ្តាលពាក់ព័ន្ធ នោះវានឹងជួយបង្កើនក្រុមមន្ត្រីសុខភាពភ្នែកដែលបានបញ្ចប់ការសិក្សា និងមាននិរន្តរភាពកាន់តែប្រសើរ នៅទូទាំងក្របខណ្ឌមុខជំនាញសំខាន់ៗ។

នៅពេលប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្ត រួមមាន ការចុះអភិបាលកិច្ចគាំទ្រ ការបង្វឹក ការរៀនសូត្ររវាងក្រុមអ្នកវិជ្ជាជីវៈ និងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលដឹកនាំដោយសមាគមវិជ្ជាជីវៈ ត្រូវបានដំណើរការ និងដាក់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល និងសមាគមវិជ្ជាជីវៈ នោះសមត្ថភាពធនធានមនុស្សនឹងត្រូវបានរក្សា និងលើកកម្ពស់ជាបន្តបន្ទាប់។

គម្រោងទទួលស្គាល់ថា ការបង្កើតកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រចក្ខុមាត្រសាស្ត្រ (Bachelor of Optometry) គឺជាដំណើរការអភិវឌ្ឍស្ថាប័នជាដំណាក់កាល ដែលតម្រូវឱ្យមានការអភិវឌ្ឍកម្មវិធីសិក្សា ការទទួលស្គាល់គុណភាព និងការអនុម័តតាមស្តង់ដារសិក្សា ការពង្រឹងសមត្ថភាពគ្រូបង្រៀន និងការត្រៀមលក្ខណៈសម្រាប់ការបណ្តុះបណ្តាលផ្នែកព្យាបាល និងអនុវត្តន៍គ្លីនិក។ ដូច្នេះ ក្នុងដំណាក់កាលអនុវត្តដំបូង គម្រោងនឹងផ្តោតលើ ការរៀបចំមូលដ្ឋានគ្រឹះនៃប្រព័ន្ធ និងលក្ខខណ្ឌចាំបាច់សម្រាប់ស្ថាប័ន ក្រោមការដឹកនាំរបស់ក្រសួងសុខាភិបាល (MOH) និង សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS)។

ផែនការការងារ និងថវិកាលម្អិតបន្ថែម សម្រាប់កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រចក្ខុមាត្រសាស្ត្រ នឹងត្រូវបានរៀបចំឡើងក្នុងអំឡុងពេលអនុវត្តគម្រោង តាមរយៈ ក្រុមការងារបច្ចេកទេសដែលដឹកនាំដោយ UHS ។ តួនាទីរបស់ The Foundation នឹងផ្តោតជាចម្បងលើការសម្របសម្រួល និងការគាំទ្រផ្នែកបច្ចេកទេស ព្រមទាំងការគាំទ្រជាយុទ្ធសាស្ត្រ ខណៈពេលដែលជានាថា ក្រសួងសុខាភិបាល និង UHS នៅតែជាអ្នកដឹកនាំ និងជាម្ចាស់កម្មវិធី។

បន្ថែមពីនេះ នៅពេលដែល ការវិភាគ និងរៀបចំផែនទីអភិវឌ្ឍធនធានមនុស្សសុខភាពភ្នែក (workforce mapping) ការរៀបចំផែនការបែងចែក និងដាក់ពង្រាយមន្ត្រី កម្មវិធីអាហារូបករណ៍ និងគំរូនៃការបែងចែកភារកិច្ច (task sharing) ត្រូវបានអនុវត្តប្រកបដោយសមស្រប និងមានការសម្របសម្រួលគ្នា នោះ ចំនួនមន្ត្រីសុខភាពភ្នែក និងការបែងចែកមន្ត្រី ប្រកបដោយសមធម៌ នឹងមានភាពប្រសើរឡើង ជាពិសេសនៅតំបន់ជនបទ និងតំបន់ដែលប្រជាជននៅតែទទួលបានសេវាសុខាភិបាលមិនគ្រប់គ្រាន់។

ការរួមបញ្ចូលគ្នានៃវិធានការទាំងនេះ នឹងជួយផ្លាស់ប្តូរ ការអភិវឌ្ឍធនធានមនុស្សសុខភាពភ្នែក ពីការបណ្តុះបណ្តាលរយៈពេលខ្លីដែលផ្តោតលើតម្រូវការភ្លាមៗ ទៅរក គន្លងអាជីពនៃការអភិវឌ្ឍវិជ្ជាជីវៈរយៈពេលវែង ដែលមានប្រព័ន្ធគាំទ្រជាបន្តបន្ទាប់ និងមានភាពស្របគ្នាជាមួយតម្រូវការនៃការផ្តល់សេវាសុខាភិបាលជាតិ។

## ភស្តុតាង និងការរៀនសូត្រ (Evidence and Learning)

ការវាយតម្លៃលើគម្រោង SEE-IPEC និង SURES បានបង្ហាញថា ការវិនិយោគលើការបណ្តុះបណ្តាលមានប្រសិទ្ធភាពខ្ពស់បំផុត នៅពេលដែលការបណ្តុះបណ្តាលទាំងនោះត្រូវបានភ្ជាប់ជាមួយ ស្ថាប័នបណ្តុះបណ្តាលដែលមានការទទួលស្គាល់ ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់ (CPD) និងប្រព័ន្ធណែនាំ និងគាំទ្រពីអ្នកមានបទពិសោធន៍ (Mentoring)។

បទពិសោធន៍នៅកម្ពុជាបានបង្ហាញថា ការបណ្តុះបណ្តាលតែមួយលើក ដោយមិនមានការរៀបចំការដាក់ពង្រាយបុគ្គលិក ការត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងារ និងគន្លងអភិវឌ្ឍវិជ្ជាជីវៈ មិនអាចកែលម្អគុណភាពនៃការផ្តល់សេវាសុខាភិបាលបានប្រកបដោយប្រសិទ្ធភាពនោះទេ។

ភស្តុតាងជាសកលបានបញ្ជាក់ពីសារៈសំខាន់នៃ ការអភិវឌ្ឍវិជ្ជាជីវៈបន្ត(CPD)ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ការទទួលស្គាល់គុណភាព ការអនុម័តនិងការគ្រប់គ្រងវិជ្ជាជីវៈតាមបទប្បញ្ញត្តិ ក្នុងការរក្សាបុគ្គលិកឱ្យបន្តបម្រើការងារ ព្រមទាំងពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការងាររបស់ធនធានមនុស្សសុខាភិបាល។

## ដំណើរការដើម្បីសម្រេចបានលទ្ធផលទី៣៖ ប្រព័ន្ធគាំទ្រ នវានុវត្តន៍បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធដែលអំណោយផល

គម្រោងទទួលស្គាល់ថា កំណែទម្រង់អភិបាលកិច្ច និងការអភិវឌ្ឍធនធានមនុស្ស មិនអាចកែលម្អសេវាសុខាភិបាលបានទេ ប្រសិនបើគ្មាន ប្រព័ន្ធគាំទ្រដែលអាចដំណើរការបានប្រកបដោយប្រសិទ្ធភាព ជាពិសេស នៅក្នុងបរិបទដែលមានភាពចម្រុះផ្នែកភូមិសាស្ត្រ និងមានការធ្វើវិមជ្ឈការនៃការផ្តល់សេវាសុខាភិបាល។

ប្រសិនបើ ដំណោះស្រាយសុខាភិបាលឌីជីថល ដូចជា សេវាពិគ្រោះនិងវាយតម្លៃជំងឺភ្នែកពីចម្ងាយ (Tele-ophthalmology) ការពិនិត្យស្រាវជ្រាវរកជំងឺ និងជំនួយក្នុងការធ្វើរោគវិនិច្ឆ័យដោយប្រើបញ្ញាសិប្បនិម្មិត (AI-assisted screening and diagnosis) ប្រព័ន្ធបញ្ជូនអ្នកជំងឺតាមប្រព័ន្ធអេឡិចត្រូនិក (e-Referral) និងផ្ទាំងបង្ហាញទិន្នន័យឌីជីថល (Digital Dashboards) ត្រូវបានដាក់បញ្ចូលទៅក្នុងការផ្តល់សេវាជាប្រចាំ តាមករណី និងបរិបទដែលសមស្រប នោះ លទ្ធភាពទទួលបានការពិគ្រោះយោបល់ពីអ្នកជំនាញ ការត្រួតពិនិត្យនិងគាំទ្របច្ចេកទេស ការទទួលបានការព្យាបាល ការផ្តល់បទអន្តរាគមន៍ទាន់ពេលវេលា ព្រមទាំងការត្រួតពិនិត្យគុណភាពសេវា នឹងមានភាពប្រសើរឡើង ជាពិសេសនៅតំបន់ដាច់ស្រយាល។

នៅពេលដែល ប្រព័ន្ធទិន្នន័យសុខភាពភ្នែក ត្រូវបានរួមបញ្ចូលយ៉ាងពេញលេញទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលថ្នាក់ជាតិ ដោយមានការគាំទ្រតាមរយៈ ការធានាគុណភាពទិន្នន័យ និងការកសាងសមត្ថភាព នោះ ការសម្រេចចិត្ត នឹងត្រូវផ្អែកលើភស្តុតាង ធ្វើឡើងបានទាន់ពេលវេលា ព្រមទាំងជួយពង្រឹង ប្រព័ន្ធធានាគុណភាព និងការត្រួតពិនិត្យ តាមដាន។

ដូចគ្នានេះដែរ នៅពេលដែល ការធ្វើសវនកម្មឧបករណ៍ ការគ្រប់គ្រងឧបករណ៍វេជ្ជសាស្ត្រ សមត្ថភាពថែទាំ និងជួសជុល និងការគាំទ្រផ្នែកវិស្វកម្មជីវវេជ្ជសាស្ត្រ ត្រូវបានដាក់ឱ្យដំណើរការក្នុងប្រព័ន្ធ នោះ ការរំខាន ឬការផ្អាកការផ្តល់សេវាដោយសារបញ្ហាឧបករណ៍ នឹងត្រូវបានកាត់បន្ថយ ហើយ ប្រសិទ្ធភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ នឹងត្រូវបានបង្កើនជាអតិបរមា។

វិធានការទាំងនេះក៏នឹងរួមចំណែកដល់ ការពង្រឹងនិរន្តរភាព និងគុណភាពនៃការផ្តល់សេវា និងការលើកកម្ពស់និរន្តរភាពបរិស្ថាន ក្នុងការផ្តល់សេវាសុខាភិបាលផងដែរ។

ប្រព័ន្ធ និងកត្តាគាំទ្រទាំងនេះ នឹងបង្កើត លក្ខខណ្ឌអំណោយផលសម្រាប់ការផ្តល់សេវាឱ្យមានសង្គតភាព ការកែលម្អគុណភាពជាបន្តបន្ទាប់ និងការពង្រឹងភាពធន់របស់ប្រព័ន្ធសុខាភិបាល ដើម្បីអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះតម្រូវការ និងបញ្ហាប្រឈមនាពេលអនាគត។

### ភស្តុតាង និងការរៀនសូត្រ (Evidence and Learning)

ការប្រើប្រាស់ ការណែនាំ និងគាំទ្របច្ចេកទេសពីចម្ងាយតាមប្រព័ន្ធឌីជីថល (Tele-mentoring) និង ការរាយការណ៍ទិន្នន័យតាមប្រព័ន្ធឌីជីថល នៅកម្ពុជា ក្នុងអំឡុងពេលជំងឺកូវីដ-១៩ បានបង្ហាញពី លទ្ធភាពក្នុងការអនុវត្ត និងអត្ថប្រយោជន៍ជាក់ស្តែង សម្រាប់ការត្រួតពិនិត្យ និងផ្តល់ការគាំទ្របច្ចេកទេសពីចម្ងាយ។

មេរៀនដែលទទួលបានពី ការធ្វើសវនកម្មឧបករណ៍បច្ចេកទេស ក្រោមកម្មវិធី SEE IPEC បានបង្ហាញថា ចន្លោះប្រហោងក្នុងការថែទាំ និងការជួសជុលឧបករណ៍ គឺជាកត្តាកំណត់ដ៏សំខាន់មួយដែលមានឥទ្ធិពលដោយផ្ទាល់លើ គុណភាព និងភាពជាប់លាប់នៃការផ្តល់សេវាសុខាភិបាល។

បទពិសោធន៍នៅទូទាំងពិភពលោកបានបង្ហាញថា ការវិនិយោគលើប្រព័ន្ធឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធ មានប្រសិទ្ធភាពពេញលេញ លុះត្រាតែមានការអនុវត្តរួមគ្នាជាមួយ ប្រព័ន្ធអភិបាលកិច្ច ការបណ្តុះបណ្តាល និងការថែទាំជួសជុល ដែលមានភាពច្បាស់លាស់ និងមាននិរន្តរភាព។

## មូលហេតុចម្បងៗដែលយុទ្ធសាស្ត្រនៃការផ្លាស់ប្តូរនេះ ត្រូវបានរំពឹងថានឹងទទួលបានជោគជ័យ

វិធីសាស្ត្រនេះត្រូវបានចាត់ទុកថា មានប្រសិទ្ធភាពខ្ពស់ ដោយសារវិធីសាស្ត្រនេះគឺ៖

- ដាក់បញ្ចូលដំណើរការសម្រេចចិត្ត និងការវិនិយោគ ទៅក្នុងគោលនយោបាយ ប្រព័ន្ធ និងស្ថាប័នរបស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យមានការដឹកនាំ ការសម្របសម្រួល និងនិរន្តរភាពក្នុងរយៈពេលវែង។
- ពង្រឹងគណនេយ្យភាពទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីធានាថាភាគីពាក់ព័ន្ធទាំងអស់មានការទទួលខុសត្រូវច្បាស់លាស់ចំពោះគុណភាព និងលទ្ធផលនៃការផ្តល់សេវាសុខភាពភ្នែក។
- ធ្វើឱ្យការអភិវឌ្ឍធនធានមនុស្សសុខភាពភ្នែកមានភាពស្របគ្នាជាមួយការដាក់ពង្រាយ និងការគ្រប់គ្រងវិជ្ជាជីវៈ ដើម្បីធានាថាបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាល អាចត្រូវបានដាក់ពង្រាយទៅតាមតម្រូវការសេវា និងអនុវត្តការងារស្របតាមស្តង់ដារ និងបទប្បញ្ញត្តិវិជ្ជាជីវៈ។
- ប្រមូលនិងការប្រើប្រាស់ទិន្នន័យ និងប្រព័ន្ធឌីជីថល ដើម្បីពង្រឹងអភិបាលកិច្ច ការតាមដានត្រួតពិនិត្យ ការសម្រេចចិត្តផ្អែកលើភស្តុតាង និងការធានាគុណភាពសេវាសុខភាពភ្នែក។
- បង្កើតយន្តការមតិត្រឡប់ (Feedback Mechanism) ដែលគាំទ្រគ្នាទៅវិញទៅមក រវាងអភិបាលកិច្ច ធនធានមន្ត្រីសុខាភិបាល និងការផ្តល់សេវា ដើម្បីឱ្យការកែលម្អក្នុងផ្នែកមួយ ក្លាយជាកត្តាជំរុញដល់ផ្នែកផ្សេងៗទៀត និងពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធទាំងមូល។

## ការសន្មត់ចម្បងៗនៃការផ្លាស់ប្តូរ (Key Change Assumptions)

### ភាពជោគជ័យនៃទស្សនៈនៃការផ្លាស់ប្តូរនេះ ពឹងផ្អែកលើការសន្មត់សំខាន់ៗដូចខាងក្រោម៖

1. ការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលក្នុងការដឹកនាំគោលនយោបាយ ការរៀបចំផែនការ និងការគ្រប់គ្រងបទប្បញ្ញត្តិសុខភាពភ្នែក។ ដៃគូអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមមាន ក្រសួងសុខាភិបាល (MoH) មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត (PHDs) សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS ស្ថាប័នវិជ្ជាជីវៈ និងភាគីពាក់ព័ន្ធផ្សេងទៀត មានសមត្ថភាព តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ព្រមទាំងមានការចូលរួមជាបន្តបន្ទាប់ ដើម្បីអនុវត្តសកម្មភាព និងកំណែទម្រង់ដែលបានព្រមព្រៀងគ្នា។ យន្តការសម្របសម្រួលសុខភាពភ្នែកដែលមានដំណើរការល្អ នឹងបន្តដំណើរការជាប្រចាំ ទោះបីមានការផ្លាស់ប្តូរតាមអាណត្តិនៃការបោះឆ្នោត ឬការផ្លាស់ប្តូរថ្នាក់ដឹកនាំក៏ដោយ។
2. ស្ថាប័នបណ្តុះបណ្តាល និងស្ថាប័នវិជ្ជាជីវៈ នៅតែមានឆន្ទៈ និងសមត្ថភាពក្នុងការដាក់បញ្ចូល និងធ្វើឱ្យកំណែទម្រង់ក្លាយជាផ្នែកមួយនៃប្រព័ន្ធ និងដំណើរការរបស់ស្ថាប័នជាប្រចាំ។
3. ប្រព័ន្ធឌីជីថល និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ នឹងត្រូវបានថែទាំ និងមានការរៀបចំថវិកាគាំទ្របន្ត បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ ដើម្បីធានានិរន្តរភាព និងការប្រើប្រាស់ប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធទាំងនោះក្នុងរយៈពេលវែង។

4. អ្នកផ្តល់សេវាសុខាភិបាលទាំងវិស័យសាធារណៈ និងវិស័យឯកជន នឹងចូលរួម ព្រមទាំងគោរពតាមដំណើរការធានាគុណភាព និងយន្តការគ្រប់គ្រងតាមបទប្បញ្ញត្តិវិជ្ជាជីវៈ។

ការសន្មត់ទាំងនេះ ត្រូវបានកំណត់ឡើងដោយផ្អែកលើ ទិសដៅគោលនយោបាយសុខាភិបាលថ្មីៗរបស់កម្ពុជា រួមមាន ផែនការយុទ្ធសាស្រ្តជាតិស្តីពីការទប់ស្កាត់ និងគ្រប់គ្រងជំងឺមិនឆ្លង (NSP BPC) ផែនការយុទ្ធសាស្រ្តសុខាភិបាលជាតិទី៤ (HSP4) និងផែនទីបង្ហាញផ្លូវសម្រាប់ការគ្របដណ្តប់សុខភាពជាសកល (UHC Roadmap) ព្រមទាំងបទពិសោធន៍ដែលទទួលបានពីការអនុវត្តគម្រោង និងកម្មវិធីនានាកន្លងមក។

## 2.4 សមធម៌ និងបរិយាបន្ន

សមធម៌ និងបរិយាបន្ន គឺជាចំណុចស្នូលនៃការរៀបចំ និងការអនុវត្តគម្រោងអភិបាលកិច្ចសុខភាពភ្នែក។ គម្រោងនេះទទួលស្គាល់ថាភាពពិការភ្នែក និងបញ្ហាគំហើញថយចុះដែលអាចជៀសវាងបាន នៅកម្ពុជា មានវិសមភាពចំពោះស្ត្រី ជនមានពិការភាព មនុស្សវ័យចាស់ ប្រជាជនរស់នៅតំបន់ជនបទ និងក្រុមប្រជាជនមានស្ថានភាពសេដ្ឋកិច្ច-សង្គមនៅមានកម្រិត ដោយសារឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដូចជា ថ្លៃចំណាយ ទីតាំងភូមិសាស្រ្ត ការបែងចែកធនធានមនុស្ស បទដ្ឋានសង្គម និងសមត្ថភាពឆ្លើយតបរបស់ប្រព័ន្ធនៅមានកម្រិត។

ជំនួសឱ្យការដោះស្រាយសមធម៌តាមរយៈការផ្តល់សេវាតែមួយមុខ គម្រោងនេះអនុវត្តវិធីសាស្រ្តនៅកម្រិតប្រព័ន្ធ ដោយបញ្ជ្រាបការគិតគូរអំពីសមធម៌ទៅក្នុងអភិបាលកិច្ច ការអភិវឌ្ឍធនធានមនុស្ស និងប្រព័ន្ធគាំទ្រនានា ដើម្បីធានាថាសេវាសុខភាពភ្នែកត្រូវបានរៀបចំផែនការ កំណត់បទប្បញ្ញត្តិ ផ្តល់ហិរញ្ញប្បទាន និងផ្តល់ជូនប្រជាជន ដោយផ្តល់អាទិភាពដល់ក្រុមងាយរងគ្រោះ ដែលបាត់បង់ឱកាស។

### a. សមធម៌យេនឌ័រ

ស្ត្រី និងក្មេងស្រី ទទួលរងបន្ទុកខ្ពស់ជាងគេលើបញ្ហាគំហើញថយចុះនៅកម្ពុជា ដែលរងឥទ្ធិពលពីកត្តាមួយចំនួនដូចជា អំណាចក្នុងការសម្រេចចិត្តនៅមានកម្រិត តួនាទីថែទាំគ្រួសារ ការទទួលបានធនធានហិរញ្ញវត្ថុនៅមានកម្រិត និងបទដ្ឋានសង្គម នាំទៅរកការកាត់បន្ថយឥរិយាបថក្នុងការស្វែងរកសេវាសុខភាព។ គម្លាតយេនឌ័រក៏មាននៅក្នុងធនធានមនុស្សផ្នែកសុខភាពភ្នែកផងដែរ ជាពិសេសក្នុងតួនាទីជាអ្នកដឹកនាំ និងតួនាទីឯកទេស។ គម្រោងនឹងដោះស្រាយសមធម៌យេនឌ័រតាមរយៈ៖

**តាមរយៈការពង្រឹងអភិបាលកិច្ច និងការដឹកនាំ-គ្រប់គ្រងវិស័យ (សមិទ្ធផលទី១)៖**

- អាទិភាពសុខភាពភ្នែក ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ ផែនការ និងក្របខណ្ឌហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលដែលឆ្លើយតបនឹងយេនឌ័រ រួមទាំងការបន្សីគ្នាជាមួយយុទ្ធសាស្រ្តរបស់ក្រសួងកិច្ចការនារី។
- ប្រព័ន្ធរៀបចំផែនការ ការត្រួតពិនិត្យតាមដាន និងការធានាគុណភាពដែលមានស្តង់ដា រួមបញ្ចូលតម្រូវការទិន្នន័យត្រូវបែងចែកតាមយេនឌ័រ ដើម្បីជួយឱ្យរាជរដ្ឋាភិបាលអាចកំណត់ និងឆ្លើយតបចំពោះគម្លាតក្នុងការទទួលបានសេវា និងលទ្ធផលរវាងស្ត្រី និងបុរស។
- យន្តការសម្របសម្រួលថ្នាក់ជាតិ និងក្រុមការងារបច្ចេកទេស ជំរុញអោយមានតំណាងប្រកបដោយបរិយាបន្ន និងគាំទ្រការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តនៅក្នុងវិស័យសុខភាពភ្នែក។

**តាមរយៈការអភិវឌ្ឍធនធានមនុស្ស (សមិទ្ធផលទី២)៖**

- ការអប់រំមុនចូលបម្រើការងារ អាហារូបករណ៍ និងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវបានរៀបចំឡើងដើម្បីពង្រីកឱកាសឱ្យស្ត្រីអាចចូលរួម និងរីកចម្រើនក្នុងវិជ្ជាជីវៈសុខភាពភ្នែក រួមមាន ចក្ខុមាត្រសាស្ត្រ ចក្ខុគិលានុបដ្ឋាក-យិកា និងតួនាទីឯកទេសផ្សេងៗ។
- ការចុះអភិបាលកិច្ច ការបង្វឹក និងបណ្តាញវិជ្ជាជីវៈ គាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការអភិវឌ្ឍនសមត្ថភាពក្នុងអាជីព រួមចំណែកដល់ការដោះស្រាយឧបសគ្គចំពោះការរក្សាទុកមន្ត្រី និងការឡើងតំណែង។
- យុទ្ធសាស្ត្របែងចែកនិងការរក្សាទុកមន្ត្រីប្រកបដោយសមធម៌ រួមចំណែកធ្វើឱ្យមានអ្នកផ្តល់សេវាជាស្ត្រីកាន់តែច្រើននៅតំបន់ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់ ដើម្បីបង្កើនការទទួលបានសេវារបស់អ្នកជំងឺជាស្ត្រី។

**តាមរយៈប្រព័ន្ធគាំទ្រ (សមិទ្ធផលទី៣)៖**

- ប្រព័ន្ធសុខាភិបាលឌីជីថល ការពិគ្រោះ និងពិនិត្យជំងឺភ្នែកពីចម្ងាយ និងវិមជ្ឈការសេវា ជួយកាត់បន្ថយពេលវេលាធ្វើដំណើរ និងថ្លៃចំណាយ ដែលជះឥទ្ធិពលខ្លាំងជាងគេលើស្ត្រី ដោយសារតួនាទីថែទាំគ្រួសារ។
- សកម្មភាពផ្តល់ព័ត៌មាន អប់រំ និងទំនាក់ទំនង (សម្ភារអប់រំ) នៅកម្រិតសហគមន៍ និងការលើកកម្ពស់ការយល់ដឹង នឹងជួយដោះស្រាយឧបសគ្គពាក់ព័ន្ធនឹងយេនឌ័រក្នុងការស្វែងរកសេវាថែទាំ និងលើកកម្ពស់ការប្រើប្រាស់សេវាសុខភាពភ្នែកឱ្យបានទាន់ពេលវេលា។
-

## b. បរិយាបន្នសម្រាប់ជនមានពិការភាព

ជនមានពិការភាពនៅកម្ពុជា ប្រឈមមុខនឹងឧបសគ្គស្មុគស្មាញជាច្រើនក្នុងការទទួលបានសេវាសុខភាពភ្នែក រួមមាន ភាពមិនងាយស្រួលផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការរើសអើង(Stigma) ការធ្វើសមាហរណកម្មសេវានៅមានកម្រិត និងការបញ្ចូលជនមានពិការភាពទៅក្នុងប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គមនៅមិនទាន់គ្រប់គ្រាន់។ បញ្ហាគំហើញថយចុះ ក៏ជាកត្តារួមចំណែក និងមានទំនាក់ទំនងជាមួយទម្រង់ពិការភាពផ្សេងៗទៀតផងដែរ។ គម្រោងនឹងដោះស្រាយបរិយាបន្នសម្រាប់ជនមានពិការភាពតាមរយៈ៖

**តាមរយៈការពង្រឹងអភិបាលកិច្ច និងការដឹកនាំ-គ្រប់គ្រងវិស័យសុខភាពភ្នែក (សមិទ្ធផលទី១)៖**

- សុខភាពភ្នែក ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ ផែនការ និងក្របខណ្ឌហិរញ្ញប្បទានប្រកបដោយបរិយាបន្នសម្រាប់ជនមានពិការភាព រួមទាំងកិច្ចសហការជាមួយក្រសួងសង្គមកិច្ច និងភាពបន្សុីគ្នាជាមួយយន្តការគាំពារសង្គម។
- ស្តង់ដាជាតិ ប្រព័ន្ធធានាគុណភាព និងយន្តការនិយ័តកម្ម លើកកម្ពស់ការផ្តល់សេវាដែលងាយស្រួលទទួលបាន មានសុវត្ថិភាព និងមានបរិយាបន្ន ទាំងវិស័យសាធារណៈ និងវិស័យឯកជន។
- ប្រព័ន្ធទិន្នន័យ ត្រូវបានពង្រឹង ដើម្បីអាចប្រមូលព័ត៌មានបែងចែកតាមស្ថានភាពពិការភាព កាន់តែប្រសើរ ដើម្បីគាំទ្រដល់ការរៀបចំផែនការដែលមានបរិយាបន្ន និងការទទួលខុសត្រូវ។

**តាមរយៈការអភិវឌ្ឍធនធានមនុស្ស (សមិទ្ធផលទី២)៖**

- កម្មវិធីអប់រំមុនចូលបម្រើការងារ និងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត រួមបញ្ចូលសមត្ថភាពពាក់ព័ន្ធនឹងការផ្តល់ការថែទាំប្រកបដោយបរិយាបន្ន ការយល់ដឹងអំពីពិការភាព និងការប្រាស្រ័យទាក់ទងដែលផ្តោតលើអ្នកជំងឺ។
- យុទ្ធសាស្ត្របែងចែកធនធានមនុស្ស ជួយធ្វើឱ្យសេវាអាចរកបាននៅជិតសហគមន៍កាន់តែប្រសើរ ជាទីកន្លែងដែលជនមានពិការភាពតែងប្រឈមនឹងឧបសគ្គផ្នែកបន្លាស់ទី និងមធ្យោបាយធ្វើដំណើរ។
- វិធីសាស្ត្រចែករំលែកភារកិច្ច និងការថែទាំសុខភាពភ្នែកកម្រិតបឋម ជួយពង្រឹងការរកឃើញជំងឺដំបូង និងប្រព័ន្ធបញ្ជូនសម្រាប់ជនដែលមានតម្រូវការច្រើន ឬស្មុគស្មាញ។

**តាមរយៈប្រព័ន្ធគាំទ្រ (សមិទ្ធផលទី៣)៖**

- ការពិគ្រោះ និងពិនិត្យជំងឺភ្នែកពីចម្ងាយ និងប្រព័ន្ធបញ្ជូនឌីជីថល ជួយកាត់បន្ថយឧបសគ្គផ្នែករូបវន្តក្នុងការទទួលបានសេវាសម្រាប់ជនមានពិការភាព។
- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងស្តង់ដារឧបករណ៍ គាំទ្រឱ្យបរិយាកាសពិនិត្យនិងការធ្វើរោគវិនិច្ឆ័យ និងព្យាបាលមានសុវត្ថិភាព មានភាពងាយស្រួលកាន់តែប្រសើរឡើង។

- ប្រព័ន្ធធានាគុណភាព រួមបញ្ចូលយន្តការទទួលមតិយោបល់ពីអ្នកជំងឺ ដើម្បីធានាថាទស្សនៈ និងបទពិសោធន៍របស់ជនមានពិការភាព ត្រូវបានយកមកប្រើប្រាស់សម្រាប់ការកែលម្អសេវា។

### c. វិស័យសមធម៌ផ្សេងៗទៀត

គម្រោងនេះក៏ដោះស្រាយវិសមធម៌ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាផ្សេងៗទៀតផងដែរ រួមមាន ទីតាំងភូមិសាស្ត្រ ភាពក្រីក្រ វ័យ ជាតិសាសន៍ ភាសា និងទីកន្លែងរស់នៅ។ វិធីសាស្ត្រសំខាន់ៗរួមមាន៖

- សមធម៌ផ្នែកភូមិសាស្ត្រ៖ ការផ្ញើផែនទីធនធានមនុស្ស ការបែងចែកមន្ត្រី និងយុទ្ធសាស្ត្ររក្សាទុកមន្ត្រី ផ្តល់អាទិភាពដល់ខេត្តជនបទ និងខេត្តដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់ ខណៈដែលប្រព័ន្ធសុខាភិបាលឌីជីថល និងគំរូផ្តល់សេវាតាមសហគមន៍ ជួយពង្រីកវិសាលភាពនៃការទទួលបានសេវា។
- សមធម៌ផ្នែកសេដ្ឋកិច្ច-សង្គម៖ ការដាក់បញ្ចូលសុខភាពភ្នែកទៅក្នុងយន្តការគាំពារសុខភាពសង្គម និងយន្តការហិរញ្ញប្បទានសុខាភិបាល ជួយកាត់បន្ថយឧបសគ្គផ្នែកហិរញ្ញវត្ថុសម្រាប់ប្រជាជនមានចំណូលទាប។
- សមធម៌ផ្នែកវ័យ៖ គម្រោងពង្រឹងសេវាដែលពាក់ព័ន្ធនឹងក្រុមមានតម្រូវការខ្ពស់ ដូចជា មនុស្សវ័យចាស់ (ឧ. ជំងឺបាយភ្នែក និងជំងឺទឹកដក់ក្នុងភ្នែក) និងកុមារ (ឧ. កំហុសកំណំរូបភាព និងការពិនិត្យភ្នែកសម្រាប់កុមារវ័យសិក្សា)។
- បរិយាបន្នផ្នែកភាសា និងវប្បធម៌៖ សកម្មភាពចូលរួមជាមួយសហគមន៍ និងសកម្មភាពផ្តល់ព័ត៌មាន អប់រំ និងទំនាក់ទំនង ត្រូវបានកែសម្រួលឱ្យសមស្របនឹងបរិបទមូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹង និងការប្រើប្រាស់សេវាក្នុងចំណោមក្រុមប្រជាជនចម្រុះ។

### d. សមិទ្ធផលកម្រិតប្រព័ន្ធតាមរយៈគោលការណ៍សមធម៌ (Equity as a system outcome)

តាមរយៈការបញ្ជ្រាបការគិតគូរអំពីយេនឌ័រ ពិការភាព និងសមធម៌ទូលំទូលាយទៅក្នុងគោលនយោបាយ ប្រព័ន្ធធនធានមនុស្ស ទិន្នន័យ ហិរញ្ញប្បទាន ការធានាគុណភាព និងហេដ្ឋារចនាសម្ព័ន្ធ គម្រោងនេះធានាថា សមធម៌មិនពឹងផ្អែកតែលើការកំណត់គោលដៅរយៈពេលខ្លីប៉ុណ្ណោះទេ ប៉ុន្តែក្លាយជាមុខងារស្នូលមួយនៃប្រព័ន្ធសុខភាពភ្នែករបស់កម្ពុជា។

វិធីសាស្ត្រកម្រិតប្រព័ន្ធនេះ រំពឹងថានឹងនាំឱ្យការទទួលបានសេវា ការប្រើប្រាស់សេវា និងលទ្ធផលសុខភាពភ្នែកប្រកបដោយសមធម៌កាន់តែប្រសើរឡើងតាមពេលវេលា ជាពិសេសសម្រាប់ស្ត្រី ជនមានពិការភាព និងប្រជាជនរស់នៅតំបន់ជនបទ និងតំបន់ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់។

## 2.5 អ្នកទទួលផល

គម្រោងអភិបាលកិច្ចសុខភាពភ្នែក និងសមត្ថភាពធនធានមនុស្ស ផ្តល់អត្ថប្រយោជន៍នៅកម្រិតជាច្រើនក្នុងប្រព័ន្ធសុខភាពភ្នែករបស់កម្ពុជា។ ទោះបីគម្រោងនេះមិនផ្តោតលើការផ្តល់សេវាផ្ទាល់ក្នុងទំហំធំក៏ដោយ វិធីសាស្ត្រពង្រឹងប្រព័ន្ធរបស់គម្រោងត្រូវបានរៀបចំឡើងដើម្បីបង្កើតអត្ថប្រយោជន៍សំខាន់ និងប្រកបដោយនិរន្តរភាពសម្រាប់ប្រជាជនដែលមានហានិភ័យនៃភាពពិការភ្នែក និងបញ្ហាគំហើញថយចុះដែលអាចជៀសវាងបាន ជាពិសេស ស្ត្រី ជនមានពិការភាព និងប្រជាជនរស់នៅតំបន់ជនបទ និងតំបន់ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់។

ដូច្នេះ អ្នកទទួលផលត្រូវបានចាត់ជាពីរក្រុម គឺ អ្នកទទួលផលផ្ទាល់ (អ្នកដែលចូលរួមដោយផ្ទាល់ជាមួយបទអន្តរាគមន៍របស់គម្រោង) និងអ្នកទទួលផលដោយប្រយោល (អ្នកដែលទទួលបានអត្ថប្រយោជន៍តាមរយៈប្រព័ន្ធ សេវា និងសមត្ថភាពធនធានមនុស្សដែលត្រូវបានកែលម្អ)។

### a. អ្នកទទួលផលចម្បង (ដោយប្រយោល – កម្រិតប្រជាជន)

ប្រជាជនដែលមានហានិភ័យនៃភាពពិការភ្នែក និងបញ្ហាគំហើញថយចុះដែលអាចជៀសវាងបាននៅកម្ពុជា ជាពិសេស៖

- ស្ត្រី និងក្មេងស្រី

- ជនមានពិការភាព រួមទាំងអ្នកដែលមានពិការភាពចម្រុះ ឬពិការភាពប្រទាក់ក្រឡាគ្នា
- មនុស្សវ័យចាស់
- កុមារដែលត្រូវការសេវាកែតម្រូវកំហុសកំណុំរូបភាព និងសេវាថែទាំភ្នែកដំបូង
- ប្រជាជនរស់នៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់
- គ្រួសារមានចំណូលទាប និងក្រុមប្រជាជនដែលជួបការបាត់បង់ឱកាសក្នុងសង្គម

ក្រុមប្រជាជនទាំងនេះទទួលបានអត្ថប្រយោជន៍ដោយប្រយោលតាមរយៈ៖

- លទ្ធភាពមានសេវា គុណភាព និងការបន្តផ្តល់សេវាសុខភាពភ្នែកត្រូវបានកែលម្អ
- ឧបសគ្គផ្នែកភូមិសាស្ត្រ និងហិរញ្ញវត្ថុ ក្នុងការទទួលបានការថែទាំ ត្រូវបានកាត់បន្ថយ
- ការធ្វើសមាហរណកម្មសុខភាពភ្នែកទៅក្នុងប្រព័ន្ធសុខាភិបាល ប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសហគមន៍ ត្រូវបានពង្រឹងកាន់តែប្រសើរ

ក្នុងរយៈពេលវែង គម្រោងនេះរួមចំណែកផ្តល់ផលប្រយោជន៍ដល់ប្រជាជនទូទាំងប្រទេស ដោយសារផ្នែកអភិបាលកិច្ច សមត្ថភាពធនធានមនុស្ស និងគុណភាពសេវា ត្រូវបានពង្រឹងនិងពង្រីកតាមរយៈប្រព័ន្ធរបស់រាជរដ្ឋាភិបាល។

### b. អ្នកទទួលផលបន្ទាប់បន្សំ (ដោយផ្ទាល់ – កម្រិតប្រព័ន្ធ និងធនធានមនុស្ស)

**ស្ថាប័នរដ្ឋាភិបាល និងភាគីប្រតិបត្តិក្នុងប្រព័ន្ធសុខាភិបាល**

- ក្រសួងសុខាភិបាល រួមទាំងកម្មវិធីជាតិសុខភាពភ្នែក
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត ការិយាល័យស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាលសាធារណៈ
- ក្រសួងពាក់ព័ន្ធដែលមិនមែនជាវិស័យសុខាភិបាល ដែលចូលរួមក្នុងវិស័យអប់រំ កិច្ចគាំពារសង្គម យេនឌ័រ និងពិការភាព

*ភាគីទាំងនេះទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម ៖*

- យន្តការសម្របសម្រួល ការដឹកនាំ-គ្រប់គ្រង និងការទទួលខុសត្រូវ
- ក្របខណ្ឌគោលនយោបាយ ការរៀបចំផែនការ និងហិរញ្ញប្បទាន
- ប្រព័ន្ធទិន្នន័យ ការចុះអភិបាលកិច្ច ការត្រួតពិនិត្យតាមដាន និងប្រព័ន្ធនិយ័តកម្ម

**ធនធានមនុស្សផ្នែកសុខភាពភ្នែក**

- វេជ្ជបណ្ឌិតឯកទេសជំងឺភ្នែក
- ចក្ខុមាត្រការី
- ចក្ខុគិលានុបដ្ឋាក-យិកា គិលានុបដ្ឋាកផ្នែកកែតម្រូវកំហុសកំណុំរូបភាព និងចក្ខុមាត្រការី
- វេជ្ជបណ្ឌិតទូទៅ និងមន្ត្រីថែទាំសុខភាពបឋម ដែលបានទទួលការបណ្តុះបណ្តាលអំពីការថែទាំភ្នែកមូលដ្ឋាន
- មន្ត្រីជីវវេជ្ជសាស្ត្រ (Biomedical) និងមន្ត្រីបច្ចេកទេស ដើរតួនាទីក្នុងការគាំទ្រដល់ឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធ

*ធនធានមនុស្សទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ពី៖*

- ការអប់រំមុនចូលបម្រើការងារ និងការទទួលស្គាល់គុណភាពជាផ្លូវការត្រូវបានកែលម្អ
- ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្ត ការបង្វឹក និងការចុះអភិបាលកិច្ច
- វិធីសាស្ត្រច្បាស់លាស់ សម្រាប់ការបែងចែកមន្ត្រី ការអភិវឌ្ឍក្នុងអាជីព និងការរក្សាទុកមន្ត្រី
- បរិយាកាសការងារដែលមានសុវត្ថិភាព និងមានឧបករណ៍គ្រប់គ្រាន់

អត្ថប្រយោជន៍សម្រាប់ធនធានមនុស្ស នឹងត្រូវបានបែងចែកតាមយេនឌ័រ ក្របខណ្ឌមុខជំនាញ និងទីតាំង ដើម្បីគាំទ្រដល់ការត្រួតពិនិត្យតាមដានដែលផ្តោតលើសមធម៌។

### c. អ្នកទទួលផលកម្រិតទីបី (ដោយផ្ទាល់ និងដោយប្រយោល – កម្រិតវិជ្ជាជីវៈ និងសហគមន៍)

- ស្ថាប័នបណ្តុះបណ្តាល និងស្ថាប័នសិក្សាអប់រំ រួមទាំងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងមន្ទីរពេទ្យបណ្តុះបណ្តាលដែលទទួលស្គាល់គុណភាព ត្រូវបានពង្រឹងតាមរយៈការអភិវឌ្ឍកម្មវិធីសិក្សា ការទទួលស្គាល់គុណភាព និងសមត្ថភាពបង្រៀន។
- សមាគមវិជ្ជាជីវៈ ជាពិសេសសមាគមគ្រូពេទ្យភ្នែកកម្ពុជា ទទួលបានអត្ថប្រយោជន៍ពីអភិបាលកិច្ចដែលកាន់តែរឹងមាំ ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្ត វេទិកាស្រាវជ្រាវ និងនិយ័តកម្មវិជ្ជាជីវៈ។
- អ្នកផ្តល់សេវាសុខភាពភ្នែកទាំងវិស័យសាធារណៈ និងឯកជន ទទួលបានអត្ថប្រយោជន៍ពីស្តង់ដារដែលកាន់តែច្បាស់លាស់ ក្របខណ្ឌធានាគុណភាព និងការណែនាំផ្នែកនិយ័តកម្ម។
- សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ទទួលបានអត្ថប្រយោជន៍ពីការរៀបចំផែនការដែលធ្វើវិមជ្ឈការ សេវាដែលភ្ជាប់ជាមួយការចុះសហគមន៍ ប្រព័ន្ធបញ្ជូន និងប្រព័ន្ធព័ត៌មានដែលត្រូវបានពង្រឹង។

### d. សមធម៌ និងការបែងចែកទិន្នន័យ

គម្រោងនេះត្រូវបានរៀបចំឡើងដើម្បីធានាថា អត្ថប្រយោជន៍អាចចែកចាយប្រកបដោយសមធម៌នៅគ្រប់ក្រុមប្រជាជន។ នៅពេលប្រព័ន្ធទិន្នន័យអនុញ្ញាត អ្នកទទួលផលនឹងត្រូវបានបែងចែកតាមយេនឌ័រ ពិការភាព វ័យ និងទីតាំងភូមិសាស្ត្រ ជាពិសេសតាមរយៈ៖
- ប្រព័ន្ធព័ត៌មានសុខាភិបាលថ្នាក់ជាតិ និងផ្ទាំងតាមដានទិន្នន័យ
- ទិន្នន័យ ផែនទីអភិវឌ្ឍធនធានមនុស្ស និងការបែងចែកមន្ត្រី
- យន្តការចុះអភិបាលកិច្ច ការធានាគុណភាព និងការទទួលមតិយោបល់ពីអ្នកជំងឺ

កត្តានេះធានាថា ការកែលម្អលទ្ធភាពមានសេវា និងគុណភាពសេវា អាចត្រូវបានត្រួតពិនិត្យតាមដាន និងកែសម្រួល ដើម្បីឆ្លើយតបចំពោះវិសមធម៌ដែលបានរកឃើញក្នុងអំឡុងពេលអនុវត្ត។

### e. វិសាលភាពនៃអ្នកទទួលផល និងនិរន្តរភាព

ខណៈដែលវិសាលភាពអ្នកទទួលផលផ្ទាល់របស់គម្រោងផ្តោតលើភាគីប្រតិបត្តិក្នុងប្រព័ន្ធ និងធនធានមនុស្ស វិសាលភាពអ្នកទទួលផលដោយប្រយោលនឹងពង្រីកទៅដល់ប្រជាជនទូទាំងប្រទេសតាមពេលវេលា នៅពេលដែលការកែលម្អត្រូវបានដាក់បញ្ចូលជាប្រព័ន្ធក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាល។ ដោយផ្តោតលើអភិបាលកិច្ច ធនធានមនុស្ស និងប្រព័ន្ធគាំទ្រ ជំនួសឱ្យការផ្តល់សេវាដែលមានកំណត់ពេលវេលា គម្រោងធានាថាអត្ថប្រយោជន៍មានលក្ខណៈ៖
- អាចពង្រីកវិសាលភាពបាន តាមរយៈរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- មាននិរន្តរភាព តាមរយៈការដាក់បញ្ចូលទៅក្នុងគោលនយោបាយ ហិរញ្ញប្បទាន និងប្រព័ន្ធធនធានមនុស្ស
- ប្រកបដោយសមធម៌ តាមរយៈការរៀបចំប្រព័ន្ធ និងការត្រួតពិនិត្យតាមដានដែលមានភាពច្បាស់លាស់

## 2.6 ភាពស៊ីសង្វាក់គ្នាផ្នែកយុទ្ធសាស្ត្រ

គម្រោងអភិបាលកិច្ចសុខភាពភ្នែក (EHG) មានភាពស៊ីសង្វាក់យ៉ាងជិតស្និទ្ធជាមួយផែនការអភិវឌ្ឍន៍ជាតិរបស់កម្ពុជា និងអាទិភាពកំណែទម្រង់វិស័យសុខាភិបាល។ តាមរយៈការពង្រឹងអភិបាលកិច្ច ការដាក់បញ្ចូលការអភិវឌ្ឍធនធានមនុស្សជាផ្នែកមួយនៃប្រព័ន្ធ និងប្រព័ន្ធគាំទ្រនានា គម្រោង EHG គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដែលដឹកនាំដោយរាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់គុណភាពសេវា សមធម៌ និងនិរន្តរភាព ព្រមទាំងជំរុញការសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល។

### a. ភាពស៊ីសង្វាក់ជាមួយយុទ្ធសាស្ត្រ គោលនយោបាយជាតិ និងក្របខណ្ឌកែលម្អគុណភាពរបស់ក្រសួងសុខាភិបាល

គម្រោង EHG គាំទ្រ និងអនុវត្តផ្ទាល់នូវយុទ្ធសាស្ត្រជាតិសំខាន់ៗដូចខាងក្រោម៖

- **ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រង និងការបង្ការភាពពិការភ្នែក** (NSP-BPC)
  គម្រោង អភិបាលកិច្ចសុខភាពភ្នែក នឹងពង្រឹងអភិបាលកិច្ច ការសម្របសម្រួល ការធានាគុណភាព និងប្រព័ន្ធធនធានមនុស្ស ដែលចាំបាច់សម្រាប់ការអនុវត្ត NSP-BPC ឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ព្រមទាំងគាំទ្រដល់ការបង្កើតភស្តុតាង និងការរៀបចំផែនការសម្រាប់ដំណាក់កាលបន្ទាប់។

- **ផែនការយុទ្ធសាស្ត្រសុខាភិបាលទី៤** (HSP4)
  គម្រោងនេះរួមចំណែកដល់អាទិភាពរបស់ HSP4 លើការពង្រឹងប្រព័ន្ធសុខាភិបាល ការធ្វើវិមជ្ឈការ គុណភាពសេវា និងសមធម៌ ដោយបញ្ជ្រាបសុខភាពភ្នែកទៅក្នុងការរៀបចំផែនការ ការចុះអភិបាលកិច្ច ហិរញ្ញប្បទាន និងប្រព័ន្ធព័ត៌មានសុខាភិបាលប្រចាំថ្ងៃ។

- **ផែនទីបង្ហាញផ្លូវស្តីពីការគ្របដណ្តប់សុខភាពជាសកល** (UHC)
  តាមរយៈការពង្រឹងផ្នែកធនធានមនុស្ស គុណភាពសេវា និងការធ្វើសមាហរណកម្មប្រព័ន្ធ ព្រមទាំងការគាំទ្រឱ្យដាក់បញ្ចូលសុខភាពភ្នែកទៅក្នុងយន្តការគាំពារសុខភាពសង្គម គម្រោងអភិបាលកិច្ចសុខភាពភ្នែក ដោះស្រាយឧបសគ្គសំខាន់ៗទាំងផ្នែកផ្គត់ផ្គង់សេវា និងឧបសគ្គផ្សេងៗទៀត (មិនមែនហិរញ្ញវត្ថុ)ចំពោះការគ្របដណ្តប់សុខភាពជាសកល។

- **របៀបវារៈអភិវឌ្ឍធនធានមនុស្សសុខាភិបាល** (HRH)
  គម្រោងអភិបាលកិច្ចសុខភាពភ្នែក មានភាពស៊ីសង្វាក់ជាមួយអាទិភាពជាតិផ្នែកធនធានមនុស្សសុខាភិបាល តាមរយៈការអប់រំមុនចូលបម្រើការងារដែលទទួលស្គាល់គុណភាពជាផ្លូវការ ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ការរៀបចំផែនការធនធានមនុស្ស ការបែងចែកធនធានមនុស្ស និងយុទ្ធសាស្ត្ររក្សាទុកមន្ត្រី ដែលលើកកម្ពស់ការបែងចែកប្រកបដោយសមធម៌។

- **កំណែទម្រង់សុខាភិបាលឌីជីថល និងប្រព័ន្ធព័ត៌មានសុខាភិបាល**
  ការដាក់បញ្ចូលទិន្នន័យសុខភាពភ្នែកទៅក្នុងប្រព័ន្ធព័ត៌មានជាតិ រួមជាមួយដំណោះស្រាយសុខាភិបាលឌីជីថល និងការពិគ្រោះ ពិនិត្យជំងឺភ្នែកពីចម្ងាយ គាំទ្ររបៀបវារៈសុខាភិបាលឌីជីថលរបស់កម្ពុជា និងពង្រឹងការសម្រេចចិត្តផ្អែកលើទិន្នន័យ។

- **ក្របខណ្ឌយេនឌ័រ ពិការភាព និងកិច្ចគាំពារសង្គម**
  គម្រោងអភិបាលកិច្ចសុខភាពភ្នែក គាំទ្រការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលអន្តរក្រសួងចំពោះសមធម៌ និងបរិយាបន្ន តាមរយៈការដាក់បញ្ចូលសុខភាពភ្នែកទៅក្នុងគោលនយោបាយ និងផែនការដែលឆ្លើយតបនឹងយេនឌ័រ មានបរិយាបន្នសម្រាប់ជនមានពិការភាព និងភ្ជាប់ជាមួយកិច្ចគាំពារសង្គម។

### b. ភាពស៊ីសង្វាក់ជាមួយការអនុវត្តល្អ

គម្រោងអភិបាលកិច្ចសុខភាពភ្នែក ឆ្លុះបញ្ចាំងពីការអនុវត្តល្អ តាមរយៈ៖

- **ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល៖** អនុវត្តក្រោមការដឹកនាំរបស់ក្រសួងសុខាភិបាល ដោយបញ្ជ្រាបកំណែទម្រង់ទៅក្នុងប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានស្រាប់ ជាជាងបង្កើតរចនាសម្ព័ន្ធឯករាជ្យបន្ថែម។

- **ភាពជាម្ចាស់មូលដ្ឋាន និងការដាក់បញ្ចូលជាប្រព័ន្ធ៖** ការពង្រឹងសមត្ថភាពផ្តោតលើស្ថាប័នជាតិ សមាគមវិជ្ជាជីវៈ និងប្រព័ន្ធនានា ដើម្បីធានានិរន្តរភាពក្រោយពេលបញ្ចប់គម្រោង។

- **ការចូលរួម និងការរៀបចំរួមគ្នា៖** ការរៀបចំ និងការអនុវត្តគម្រោងផ្អែកលើដំណើរការពិគ្រោះយោបល់ និងការសម្របសម្រួលបន្តរវាងរាជរដ្ឋាភិបាល ស្ថាប័នបណ្តុះបណ្តាល សមាគមវិជ្ជាជីវៈ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

- **ការទទួលខុសត្រូវរួម និងតម្លាភាព៖** ការពង្រឹងការត្រួតពិនិត្យតាមដាន ប្រព័ន្ធទិន្នន័យ និងយន្តការធានាគុណភាព គាំទ្រដល់ការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាទាំងវិស័យសាធារណៈ និងវិស័យឯកជន។
- **និរន្តរភាព និងលទ្ធភាពពង្រីកវិសាលភាព៖** ភាពស៊ីសង្វាក់ជាមួយគោលនយោបាយជាតិ ក្របខណ្ឌហិរញ្ញប្បទាន និងប្រព័ន្ធធនធានមនុស្ស អនុញ្ញាតឱ្យកំណែទម្រង់អាចពង្រីកវិសាលភាព និងបន្តបានប្រកបដោយនិរន្តរភាពតាមពេលវេលា។

### c. ការរួមចំណែកផ្នែកយុទ្ធសាស្ត្ររបស់គម្រោងអភិបាលកិច្ចសុខភាពភ្នែក

គម្រោងអភិបាលកិច្ចសុខភាពភ្នែក បំពេញបន្ថែមនូវគំនិតផ្តួចផ្តើមក្នុងការផ្តល់សេវា ដោយដោះស្រាយមូលដ្ឋានប្រព័ន្ធសម្រាប់ការផ្តល់សេវាសុខភាពភ្នែក។ តម្លៃយុទ្ធសាស្ត្ររបស់គម្រោងនេះ ស្ថិតនៅក្នុងការពង្រឹងរបៀបដែលសុខភាពភ្នែកត្រូវបានគ្រប់គ្រង កំណត់បទប្បញ្ញត្តិ រៀបចំធនធានមនុស្ស និងត្រួតពិនិត្យតាមដាន ដោយជួយឱ្យមានសេវាសុខភាពភ្នែកដែលមានលក្ខណៈសមាហរណកម្ម ប្រកបដោយសមធម៌ និងមានភាពធន់កាន់តែប្រសើរ ដើម្បីគាំទ្រដល់គោលដៅសុខភាព និងអភិវឌ្ឍន៍រយៈពេលវែងរបស់កម្ពុជា។

# 3. ការអនុវត្តគម្រោង

## 3.1 ការគ្រប់គ្រងគម្រោង

### a. វិធីសាស្ត្រគ្រប់គ្រងរួម

គម្រោងអភិបាលកិច្ចសុខភាពភ្នែក (EHG) នឹងត្រូវអនុវត្តតាមគំរូគ្រប់គ្រងដែលដឹកនាំដោយរាជរដ្ឋាភិបាល និងផ្អែកលើភាពជាដៃគូ ដើម្បីលើកកម្ពស់ការដឹកនាំ-គ្រប់គ្រងដែលរឹងមាំ ការសម្រេចចិត្តរួមគ្នា និងភាពជាម្ចាស់របស់ស្ថាប័ន។ ការរៀបចំការគ្រប់គ្រងនឹងផ្អែកលើយន្តការសហការដែលមានស្រាប់ពីគំនិតផ្តួចផ្តើមសុខភាពភ្នែកមុនៗដែលមូលនិធិហ្វ្រេដហូឡូបានគាំទ្រនៅកម្ពុជា និងត្រូវបានកែសម្រួលឱ្យសមស្របនឹងការផ្តោតលើអភិបាលកិច្ច និងការពង្រឹងប្រព័ន្ធរបស់គម្រោងអភិបាលកិច្ចសុខភាពភ្នែក។

គម្រោងនេះនឹងត្រូវបានត្រួតពិនិត្យ និងដឹកនាំដោយគណៈកម្មការដឹកនាំគម្រោង ដោយមានការគាំទ្រពីយន្តការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានស្រាប់ ខណៈដែលមូលនិធិហ្វ្រេដហូឡូ កម្ពុជា ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការគ្រប់គ្រងជំនួយឥតសំណង និងមុខងារលេខាធិការដ្ឋាន។

### b. គណៈកម្មការដឹកនាំគម្រោង

គណៈកម្មការដឹកនាំគម្រោង (PSC) នឹងត្រូវបង្កើតឡើង ដើម្បីផ្តល់ទិសដៅយុទ្ធសាស្ត្រ ការត្រួតពិនិត្យ និងការសម្របសម្រួលកម្រិតខ្ពស់ សម្រាប់គម្រោងអភិបាលកិច្ចសុខភាពភ្នែក។
**គណៈគ្រប់គ្រង៖**

- គណៈកម្មការដឹកនាំគម្រោង នឹងដឹកនាំដោយរដ្ឋលេខាធិការមកពីក្រសួងសុខាភិបាល ឬ
- ដឹកនាំរួមដោយ៖
    - សាស្ត្រាចារ្យ សាផុន វឌ្ឍនៈ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) និង
    - សាស្ត្រាចារ្យ ងី ម៉េង ប្រធានកម្មវិធីជាតិសុខភាពភ្នែក (NPEH)

**សមាជិកភាព** សមាជិកភាពរបស់គណៈកម្មការដឹកនាំគម្រោង នឹងរួមមានតំណាងជាន់ខ្ពស់ពី៖

- ក្រសួងសុខាភិបាល (នាយកដ្ឋានពាក់ព័ន្ធ)
- កម្មវិធីជាតិសុខភាពភ្នែក (NPEH)
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS)
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត (តាមភាពសមស្រប)
- សមាគមគ្រូពេទ្យភ្នែកកម្ពុជា (COS)
- សមាគមចក្ខុមាត្រការីកម្ពុជា (OSC)
- ដៃគូរដ្ឋាភិបាល ឬស្ថាប័នសំខាន់ៗផ្សេងទៀត ដែលពាក់ព័ន្ធនឹងអភិបាលកិច្ច ធនធានមនុស្ស ឬការពង្រឹងប្រព័ន្ធ

**មូលនិធិហ្វ្រេដហូឡូ កម្ពុជា** នឹងដើរតួនាទីជាលេខាធិការដ្ឋានរបស់គណៈកម្មការដឹកនាំគម្រោង ដោយទទួលខុសត្រូវលើ៖

- កោះប្រជុំ និងរៀបចំឯកសារពាក់ព័ន្ធ
- សម្របសម្រួលសកម្មភាពតាមដានបន្ត
- គាំទ្រការពិភាក្សា និងការសម្រេចចិត្តផ្អែកលើភស្តុតាង

**តួនាទីរបស់គណៈកម្មការដឹកនាំគម្រោង៖**

- ផ្តល់ការត្រួតពិនិត្យកម្រិតយុទ្ធសាស្ត្រ និងការណែនាំផ្នែកគោលនយោបាយ

- អនុម័តផែនការការងារប្រចាំឆ្នាំ អាទិភាព និងការកែសម្រួលសំខាន់ៗ
- ធានាឱ្យមានភាពស៊ីសង្វាក់ជាមួយយុទ្ធសាស្ត្រជាតិ និងកំណែទម្រង់នានា
- ពង្រឹងការសម្របសម្រួលរវាងស្ថាប័ន និងដៃគូពាក់ព័ន្ធ
- គាំទ្រការទទួលខុសត្រូវចំពោះការសម្រេចបាននូវសមិទ្ធផលគម្រោង

គណៈកម្មការដឹកនាំគម្រោង នឹងប្រជុំតាមកាលវិភាគដែលបានកំណត់ ហើយអាចកោះប្រជុំបន្ថែមតាមការចាំបាច់។

### c. តួនាទីរបស់ដៃគូរដ្ឋាភិបាល និងស្ថាប័នសំខាន់ៗ

**ក្រសួងសុខាភិបាល (MoH)**

ក្រសួងសុខាភិបាល ផ្តល់ការដឹកនាំ និងការដឹកនាំ-គ្រប់គ្រងរួមសម្រាប់គម្រោងអភិបាលកិច្ចសុខភាពភ្នែក។ តាមរយៈនាយកដ្ឋាន និងវេទិកាសម្របសម្រួលរបស់ខ្លួន ក្រសួងសុខាភិបាលនឹង៖

- ដឹកនាំដំណើរការអភិបាលកិច្ច និងគោលនយោបាយសុខភាពភ្នែកថ្នាក់ជាតិ
- អនុម័តស្តង់ដា គោលការណ៍ណែនាំ ផែនការ និងក្របខណ្ឌនិយ័តកម្ម
- ធានាឱ្យសុខភាពភ្នែកត្រូវបានធ្វើសមាហរណកម្មទៅក្នុងកំណែទម្រង់ប្រព័ន្ធសុខាភិបាល យន្តការហិរញ្ញប្បទាន និងប្រព័ន្ធព័ត៌មានសុខាភិបាល

**កម្មវិធីជាតិសុខភាពភ្នែក (NPEH)**

កម្មវិធីជាតិសុខភាពភ្នែក គឺជាអង្គភាពដឹកនាំផ្នែកបច្ចេកទេសសម្រាប់វិស័យសុខភាពភ្នែក និងមានតួនាទីស្នូលក្នុងការ៖

- សម្របសម្រួលផ្នែកបច្ចេកទេសប្រចាំថ្ងៃ និងត្រួតពិនិត្យការអនុវត្តគម្រោង
- កោះប្រជុំ និងដឹកនាំក្រុមការងារបច្ចេកទេសថ្នាក់ជាតិ
- ណែនាំដំណើរការរៀបចំផែនការ ការត្រួតពិនិត្យតាមដាន ការធានាគុណភាព និងគំនិតផ្តួចផ្តើមផ្នែកនិយ័តកម្ម
- សម្របសម្រួលជាមួយមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងអ្នកផ្តល់សេវាសុខភាពភ្នែក

**សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS)**

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដឹកនាំរបៀបវារៈអប់រំ និងការអភិវឌ្ឍធនធានមនុស្ស រួមមាន៖

- ពង្រឹងការអប់រំមុនចូលបម្រើការងារ និងគន្លងទទួលស្គាល់គុណភាពជាផ្លូវការ
- កែលម្អគុណភាពការបង្រៀន កម្មវិធីសិក្សា និងប្រព័ន្ធវាយតម្លៃ
- គាំទ្របណ្តាញបណ្តុះបណ្តាលផ្នែកគ្លីនិក និងទីតាំងបង្រៀនដែលធ្វើវិមជ្ឈការ
- រួមចំណែកផ្តល់ការដឹកនាំផ្នែកសិក្សាអប់រំ ក្នុងកិច្ចពិភាក្សាអំពីកំណែទម្រង់ធនធានមនុស្ស និងប្រព័ន្ធសុខាភិបាល

### d. តួនាទីរបស់មូលនិធិហ្វ្រេដហូឡូ កម្ពុជា

មូលនិធិហ្វ្រេដហូឡូ កម្ពុជា ទទួលខុសត្រូវលើ៖

- ការសម្របសម្រួលគម្រោងទាំងមូល ការគ្រប់គ្រងមូលនិធិ និងការគ្រប់គ្រងហិរញ្ញវត្ថុ
- ផ្តល់ជំនួយបច្ចេកទេសលើផ្នែកអភិបាលកិច្ច ធនធានមនុស្ស គុណភាព និងប្រព័ន្ធនានា
- គាំទ្រភាពជាដៃគូ និងការសម្របសម្រួលរវាងរាជរដ្ឋាភិបាល ស្ថាប័នសិក្សាអប់រំ ស្ថាប័នវិជ្ជាជីវៈ និងអង្គការមិនមែនរដ្ឋាភិបាល
- ការត្រួតពិនិត្យតាមដាន ការរាយការណ៍ ការរៀនសូត្រ និងការគ្រប់គ្រងតាមបែបបត់បែន

មូលនិធិហ្វ្រេដហូឡូ កម្ពុជា នឹងធ្វើការតាមរយៈ និងជាមួយប្រព័ន្ធរបស់រាជរដ្ឋាភិបាល ដោយជៀសវាងការរៀបចំយន្តការអនុវត្តដាច់ដោយឡែក។

### e. តួនាទីរបស់ក្រុមការងារបច្ចេកទេសរបស់មូលនិធិហ្វ្រេដហូឡូ

គម្រោងអភិបាលកិច្ចសុខភាពភ្នែក នឹងផ្តល់អាទិភាពដល់ការប្រើប្រាស់ជំនាញបច្ចេកទេសថ្នាក់ជាតិ និងមូលដ្ឋាន សម្រាប់ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យគម្រោង ស្របតាមការប្តេជ្ញារបស់គម្រោងចំពោះភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងការអភិវឌ្ឍដែលដឹកនាំដោយមូលដ្ឋាន។

ក្រុមការងារបច្ចេកទេស (CSN) និងអ្នកជំនាញបច្ចេកទេសដែលមានមូលដ្ឋាននៅការិយាល័យកណ្តាលរបស់មូលនិធិហ្វ្រេដហូឡូ នឹងត្រូវបានអញ្ជើញឱ្យចូលរួមតាមតម្រូវការ នៅពេលមានជំនាញឯកទេសចាំបាច់ដែលមិនអាចរកបានគ្រប់គ្រាន់នៅកម្រិតប្រទេស។ ការគាំទ្រនេះអាចរួមមានជំនួយគោលដៅលើផ្នែកអភិបាលកិច្ចសុខភាពភ្នែក ការស្វែងរកកិច្ចគាំទ្រ ជំនាញបច្ចេកទេសផ្នែកចក្ខុមាត្រសាស្ត្រ ការទទួលស្គាល់គុណភាពធនធានមនុស្ស ការធានាគុណភាព ប្រព័ន្ធសុខាភិបាលឌីជីថល និងសមធម៌ និងបរិយាបន្ន។

ការគាំទ្រពីការិយាល័យកណ្តាល និងបណ្តាញគាំទ្រប្រទេស នឹងត្រូវបានផ្តល់ជាតួនាទីផ្តល់យោបល់ និងបំពេញបន្ថែម ដោយមានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- បំពេញចន្លោះខ្វះខាតផ្នែកបច្ចេកទេសដែលបានកំណត់
- ផ្តល់ការធានាគុណភាព និងការពិនិត្យពិភាក្សារវាងមិត្តរួមវិជ្ជាជីវៈ នៅដំណាក់កាលសំខាន់ៗ
- ចែករំលែកមេរៀនបទពិសោធន៍ជាសកល និងបទពិសោធន៍ឆ្លងប្រទេសដែលពាក់ព័ន្ធ

មូលនិធិហ្វ្រេដហូឡូ កម្ពុជា នឹងសម្របសម្រួលការចូលរួមណាមួយបែបនេះ ដើម្បីធានាថាធាតុចូលបច្ចេកទេសពីខាងក្រៅនៅតែស៊ីសង្វាក់ជាមួយអាទិភាពរបស់ក្រសួងសុខាភិបាល ពង្រឹងសមត្ថភាពមូលដ្ឋាន និងមិនបង្កើតរចនាសម្ព័ន្ធសម្រេចចិត្ត ឬអនុវត្តដាច់ដោយឡែក។

### f. ស្ថាប័នវិជ្ជាជីវៈ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធផ្សេងទៀត

- សមាគមគ្រូពេទ្យភ្នែកកម្ពុជា (Cambodian Ophthalmological Society – COS) និង សមាគមចក្ខុមាត្រការីកម្ពុជា (Optometry Society of Cambodia – OSC) នឹងចូលរួមគាំទ្រដល់ ការអភិវឌ្ឍវិជ្ជាជីវៈ ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់ (CPD) អភិបាលកិច្ចគ្លីនិក ក្រមសីលធម៌វិជ្ជាជីវៈ និងការរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងចំណោមអ្នកប្រកបវិជ្ជាជីវៈ (Peer Learning)។
- អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងដៃគូអភិវឌ្ឍន៍ នឹងត្រូវបានចូលរួមតាមរយៈ យន្តការសម្របសម្រួល ដើម្បីធានាឱ្យសកម្មភាពរបស់ភាគីពាក់ព័ន្ធមានភាពស្របគ្នា កាត់បន្ថយការធ្វើសកម្មភាពស្ទួនគ្នា និងគាំទ្រដល់ អាទិភាពជាតិ និងទិសដៅអភិវឌ្ឍន៍វិស័យសុខាភិបាលរបស់កម្ពុជា។

### g. ការចូលរួមជាមួយអង្គការដែលផ្អែកលើសិទ្ធិមនុស្ស (Rights-Based Organisations)

គម្រោងនឹងចូលរួម និងសហការជាមួយ អង្គការស្ត្រី និងអង្គការតំណាងជនមានពិការភាព (Disabled People's Organisations – DPOs) តាមរយៈ ការពិគ្រោះយោបល់ និងយន្តការសម្របសម្រួល ជាពិសេសក្នុងគោលបំណង៖

- ផ្តល់ធាតុចូលសម្រាប់កិច្ចសន្ទនាគោលនយោបាយ និងការកែទម្រង់ប្រព័ន្ធ ដើម្បីធានាថាទស្សនៈ និងតម្រូវការរបស់ក្រុមប្រជាជនពាក់ព័ន្ធ ត្រូវបានយកមកពិចារណានៅក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ និងប្រព័ន្ធសុខាភិបាល។
- ពង្រឹងការគិតគូរអំពីបរិយាបន្ន ភាពងាយស្រួលក្នុងការទទួលបានសេវា និងគុណភាពសេវា ដើម្បីធានាថាសេវាសុខភាពភ្នែកអាចទទួលបាន និងប្រើប្រាស់បានដោយមនុស្សគ្រប់រូប រួមទាំងស្ត្រី និងជនមានពិការភាព។

- លើកកម្ពស់ និងពង្រឹងការបង្ហាញទស្សនៈរបស់ស្ត្រី និងជនមានពិការភាព នៅក្នុងដំណើរការអភិបាលកិច្ច និងការសម្រេចចិត្ត ដើម្បីឱ្យសំឡេង បទពិសោធន៍ និងតម្រូវការរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំងក្នុងការរៀបចំ និងអនុវត្តប្រព័ន្ធសុខាភិបាល។

### h. ការសម្រេចចិត្ត ការសម្របសម្រួល និងការគ្រប់គ្រងបែបបត់បែន

ការសម្រេចចិត្តផ្នែកយុទ្ធសាស្ត្រ នឹងត្រូវបានដឹកនាំ និងណែនាំដោយ គណៈកម្មាធិការដឹកនាំគម្រោង (Project Steering Committee) ខណៈដែល ការសម្របសម្រួលផ្នែកបច្ចេកទេស និងប្រតិបត្តិការ នឹងត្រូវអនុវត្តតាមរយៈវេទិកា និងយន្តការដែលមានស្រាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដំណើរការរៀបចំផែនការ ការតាមដានត្រួតពិនិត្យ និងការពិនិត្យឆ្លុះបញ្ចាំងជាប្រចាំ នឹងត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រ ការគ្រប់គ្រងបែបបត់បែន ដែលអនុញ្ញាតឱ្យគម្រោងអាចកែសម្រួលវិធីសាស្ត្រ និងសកម្មភាពឱ្យឆ្លើយតបបានទាន់ពេលវេលាចំពោះតម្រូវការ និងការផ្លាស់ប្តូររបស់ប្រព័ន្ធសុខាភិបាល ខណៈពេលដែលនៅតែរក្សាឱ្យមាន ភាពស្របគ្នាជាមួយគោលបំណង និងលទ្ធផលដែលបានព្រមព្រៀងគ្នារបស់គម្រោង។

## 3.2 និរន្តរភាព

និរន្តរភាព គឺជាគោលការណ៍ស្នូលមួយដែលគាំទ្រដល់ការរៀបចំរចនាសម្ព័ន្ធ និងការអនុវត្តគម្រោង អភិបាលកិច្ចសុខភាពភ្នែក (Eye Health Governance – EHG)។ គម្រោងអនុវត្ត វិធីសាស្ត្រពង្រឹងប្រព័ន្ធសុខាភិបាល ដោយធានាថា ការកែលម្អក្នុងផ្នែក អភិបាលកិច្ច សមត្ថភាពធនធានមនុស្ស និងប្រព័ន្ធគាំទ្រដែលអំណោយផល ត្រូវបានដាក់បញ្ចូលទៅក្នុងស្ថាប័ន និងគោលនយោបាយជាតិ ហើយអាចបន្តដំណើរការបានក្រោយពេលបញ្ចប់ការគាំទ្រថវិកាពីគម្រោង។

គម្រោងអភិបាលកិច្ចសុខភាពភ្នែក កំណត់និយមន័យនៃ និរន្តរភាព មិនមែនផ្តោតតែលើការបន្តសកម្មភាពរបស់គម្រោងប៉ុណ្ណោះទេ ប៉ុន្តែផ្តោតលើ សមត្ថភាពរយៈពេលវែងរបស់ប្រព័ន្ធសុខភាពភ្នែក ក្នុងការដំណើរការប្រកបដោយប្រសិទ្ធភាព សមធម៌ និងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល។

### a. និរន្តរភាពផ្នែកស្ថាប័ន និងប្រព័ន្ធ

យុទ្ធសាស្ត្រសំខាន់បំផុតសម្រាប់ធានានិរន្តរភាពរបស់គម្រោងអភិបាលកិច្ចសុខភាពភ្នែក គឺការដាក់បញ្ចូល និងធ្វើឱ្យការងារក្លាយជាផ្នែកមួយនៃស្ថាប័នរដ្ឋ ផែនការ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងការកសាង ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និង

ឆន្ទៈនយោបាយ ឱ្យកាន់តែរឹងមាំ។

គម្រោងនឹងអនុវត្តការងារតាមរយៈ រចនាសម្ព័ន្ធ និងយន្តការរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ ជាពិសេស ក្រសួងសុខាភិបាល (MoH) កម្មវិធីជាតិសុខភាពភ្នែក (National Program for Eye Health – NPEH) មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) ជំនួសឱ្យការបង្កើតយន្តការអនុវត្តដាច់ដោយឡែក ឬស្របគ្នាជាមួយប្រព័ន្ធរដ្ឋាភិបាលដែលមានស្រាប់។

**និរន្តរភាពនឹងត្រូវបានគាំទ្រតាមរយៈ៖**

- ការពង្រឹងអភិបាលកិច្ច ការសម្របសម្រួល និងមុខងារគ្រប់គ្រងតាមបទប្បញ្ញត្តិ ដែលជាអាណត្តិ និងភារកិច្ចស្នូលរបស់ស្ថាប័នរដ្ឋ។
- ការដាក់បញ្ចូលការរៀបចំផែនការសុខភាពភ្នែក ការត្រួតពិនិត្យ និងគាំទ្រការអនុវត្ត ការធានាគុណភាព និងការតាមដានត្រួតពិនិត្យ ទៅក្នុងប្រព័ន្ធ និងដំណើរការការងារប្រចាំរបស់ស្ថាប័នរដ្ឋ។
- ការគាំទ្រគន្លងអប់រំ និងបណ្តុះបណ្តាលដែលមានការទទួលស្គាល់ ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈ និងយន្តការរៀបចំផែនការធនធានមនុស្ស ដែលអាចបន្តដំណើរការបានដោយខ្លួនឯង ក្រោយពេលបញ្ចប់ការគាំទ្រពីគម្រោង។

តាមរយៈការពង្រឹង ស្ថាប័ន គោលនយោបាយ ស្តង់ដារ និងប្រព័ន្ធ គម្រោងនឹងជួយធានាថា អត្ថប្រយោជន៍ និងសមត្ថភាពដែលបានកសាងឡើងនឹងបន្តមានប្រសិទ្ធភាពក្នុងរយៈពេលវែង ទោះបីជាការគាំទ្រពីខាងក្រៅត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ក៏ដោយ។

### b. និរន្តរភាពផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ( Financial and Economic Sustainability )

គម្រោង អភិបាលកិច្ចសុខភាពភ្នែក (EHG) គាំទ្រដល់ការធានា និរន្តរភាពផ្នែកហិរញ្ញវត្ថុ តាមរយៈការលើកកម្ពស់៖

- ការរួមបញ្ចូលអាទិភាពសុខភាពភ្នែក ទៅក្នុងការរៀបចំផែនការ និងក្របខណ្ឌហិរញ្ញប្បទាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ការធ្វើឱ្យសុខភាពភ្នែកមានភាពស្របគ្នាជាមួយយន្តការការពារសង្គមក្នុងវិស័យសុខាភិបាល និងយន្តការហិរញ្ញប្បទានសុខាភិបាលទូលំទូលាយ ដើម្បីគាំទ្រដល់ការផ្តល់សេវាសុខភាពភ្នែកប្រកបដោយសមធម៌ និងនិរន្តរភាព។
- ការបង្កើនប្រសិទ្ធភាព និងផលចំណេញពីការវិនិយោគ តាមរយៈការពង្រឹងអភិបាលកិច្ច ការដាក់ពង្រាយធនធានមនុស្សឱ្យស្របតាមតម្រូវការសេវា និងការគ្រប់គ្រង ថែទាំ និងជួសជុលឧបករណ៍ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

ជំនួសឱ្យការបង្កើត ចំណាយប្រចាំដែលត្រូវពឹងផ្អែកលើគម្រោងជាបន្តបន្ទាប់ គម្រោងអភិបាលកិច្ចសុខភាពភ្នែក មានគោលបំណងកាត់បន្ថយភាពមិនប្រសើរនៃការប្រើប្រាស់ធនធាន និងការខាតបង់ដែលអាចជៀសវាងបាន ព្រមទាំងការពារ និងបង្កើនតម្លៃនៃការវិនិយោគដែលមានស្រាប់។ វានឹងជួយឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ អាចបន្តផ្តល់សេវាសុខភាពភ្នែកប្រកបដោយ ប្រសិទ្ធភាពខ្ពស់ និងចំណាយសមស្របជាងមុនក្នុងរយៈពេលវែង។

### និរន្តរភាពផ្នែកធនធានមនុស្ស និងសមត្ថភាព ( Workforce and Capacity Sustainability )

លទ្ធផលប្រកបដោយនិរន្តរភាពនឹងត្រូវបានធានាបន្ថែម តាមរយៈ ការដាក់បញ្ចូលការអភិវឌ្ឍធនធានមនុស្សទៅក្នុងប្រព័ន្ធស្ថាប័ន រួមមាន៖

- ការអប់រំមុនចូលបម្រើវិជ្ជាជីវៈ និងគន្លងនៃការទទួលស្គាល់គុណភាព និងការអនុម័តតាមស្តង់ដារវិជ្ជាជីវៈ ដែលមានលក្ខណៈផ្លូវការ និងច្បាស់លាស់។
- ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) ការណែនាំ និងគាំទ្រពីអ្នកមានបទពិសោធន៍ (Mentoring) និងការត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងារ (Supervision) ដើម្បីពង្រឹង និងរក្សាសមត្ថភាពវិជ្ជាជីវៈបន្ត ។
- យន្តការរៀបចំផែនការធនធានមនុស្ស ការដាក់ពង្រាយ និងការរក្សាបុគ្គលិកឱ្យបន្តបម្រើការងារ ដែលមានភាពស្របគ្នាជាមួយតម្រូវការនៃការផ្តល់សេវាសុខាភិបាលជាតិ និងតម្រូវការសុខភាពភ្នែកនៅតំបន់ផ្សេងៗ។

វិធានការទាំងនេះនឹងគាំទ្រដល់ការកសាង ធនធានមន្ត្រីសុខាភិបាលប្រកបដោយសមត្ថភាព និងត្រូវបានបែងចែកប្រកបដោយសមធម៌ ដើម្បីធានា គុណភាពនៃការផ្តល់សេវាសុខភាពភ្នែក បានដោយខ្លួនឯង មិនចាំបាច់ពឹងផ្អែកជំនួយបច្ចេកទេសពីខាងក្រៅ។

### c. យុទ្ធសាស្ត្របញ្ចប់គម្រោង និងការទទួលខុសត្រូវបន្ត ( Exit and Transition Strategy )

គម្រោង អភិបាលកិច្ចសុខភាពភ្នែក (EHG) មិនពឹងផ្អែកលើការអនុវត្ត «យុទ្ធសាស្ត្របញ្ចប់គម្រោង» (Exit Strategy ) ដែលធ្វើឡើងភ្លាមៗ ឬតាមលំដាប់ជាដំណាក់កាលត្រង់តែមួយនោះទេ។ ផ្ទុយទៅវិញ គម្រោងនឹងអនុវត្ត ការផ្លាស់ប្តូរទំនួលខុសត្រូវជាបណ្តើរៗ ដោយនៅពេលប្រព័ន្ធ និងស្ថាប័នរបស់រាជរដ្ឋាភិបាលមានភាពរឹងមាំ និងដៃគូពាក់ព័ន្ធមានសមត្ថភាពកាន់តែប្រសើរ ពួកគេនឹងបន្តកិច្ចការជាមួយការទទួលខុសត្រូវពេញលេញលើមុខងារដែលត្រូវបានពង្រឹង។

ការគាំទ្រផ្នែកបច្ចេកទេសពី The Foundation Cambodia នឹងត្រូវបានដកថយជាបណ្តើរៗ ស្របតាមការកសាងសមត្ថភាព និងការរីកចម្រើននៃប្រព័ន្ធ និងស្ថាប័ន។ ដំណាក់កាលចុងក្រោយនៃគម្រោង នឹងផ្តោតជាចម្បងលើ ការពង្រឹង និងធ្វើឱ្យប្រព័ន្ធមានស្ថិរភាព ការផ្ទេរភារកិច្ច និងទំនួលខុសត្រូវ និងការរៀបចំផែនការធានានិរន្តរភាព។

នៅចុងបញ្ចប់នៃគម្រោង ប្រព័ន្ធស្នូលសម្រាប់អភិបាលកិច្ច ការអភិវឌ្ឍ និងគ្រប់គ្រងធនធានមនុស្ស ការធានាគុណភាព និងប្រព័ន្ធព័ត៌មាន នឹងត្រូវបានដាក់ឱ្យដំណើរការ និងអនុវត្តជាផ្នែកមួយនៃ ការងារប្រចាំរបស់ប្រព័ន្ធសុខាភិបាលរដ្ឋ ដោយកាត់បន្ថយការពឹងផ្អែកលើការគាំទ្រពីគម្រោង និងធានាឱ្យមានការបន្តអនុវត្តប្រកបដោយនិរន្តរភាព។

## 3.3 ក្របខ័ណ្ឌផែនការសកម្មភាព និងថិរវេលានៃគម្រោង

**សំគាល់៖** ការរៀបចំផែនការអនុវត្តលម្អិត នឹងត្រូវបានរៀបចំបន្ថែមតាមរយៈកិច្ចព្រមព្រៀងជាដៃគូ (PAs) រួមទាំងការបញ្ជាក់អំពីតួនាទីរបស់ដៃគូ លំដាប់លំដោយនៃការអនុវត្ត វិសាលភាពភូមិសាស្ត្រ និងវិធីសាស្ត្រអនុវត្តសកម្មភាពនៅតាមកម្រិតនីមួយៗ។ បន្ថែមពីនេះ ផែនការស្វែងរកការគាំទ្រជាក់លាក់ ជាអាទិភាព និងផែនការនានា នឹងត្រូវបានរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត ដើម្បីតម្រង់ទិសការចូលរួមពីភាគីពាក់ព័ន្ធ ការស្វែងការគាំទ្រផ្នែកបច្ចេកទេស និងដំណើរការដែលមានផលជះវិជ្ជមានលើគោលនយោបាយ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| **គោលបំណង/គោលដៅគម្រោង៖** ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាចម្បង។ | | | | | | | |
| **សមិទ្ធផលចុងក្រោយនៃគម្រោង៖** *នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្តល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។* | | | | | | | |
| សមិទ្ធផល / លទ្ធផលរំពឹងទុក ៖ | សកម្មភាព | សម្មតិកម្ម៖ *សូមគិតជាសេចក្តីថ្លែង "ដោយសារ"៖ សកម្មភាពនឹងសម្រេចបានលទ្ធផលរំពឹងទុកដោយសារ... ហើយលទ្ធផលរំពឹងទុកនឹងសម្រេចបានសមិទ្ធផល ដោយសារ...* | រយៈពេល៖ Y1 | Y2 | Y3 | Y4 | Y4 |
| **សមិទ្ធផលទី១៖ អភិបាលកិច្ច ការសម្របសម្រួល និងការដឹកនាំ-គ្រប់គ្រង ត្រូវបានពង្រឹង ដើម្បីលើកម្ពស់ការរៀបចំផែនការ ការកំណត់បទប្បញ្ញត្តិ (ក្រមប្រតិបត្តិវិជ្ជាជីវៈ) គុណភាព និងការទទួលខុសត្រូវខ្ពស់ក្នុងវិស័យសុខភាពភ្នែក។** | | | | | | | |
| **លទ្ធផលរំពឹងទុក ១.១៖** យន្តការសម្របសម្រួល និងការដឹកនាំ-គ្រប់គ្រងវិស័យសុខភាពភ្នែកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹងក្រោមការដឹកនាំរបស់ក្រសួងសុខាភិបាល។ | រៀបចំផែនទីចេនាសម្ព័ន្ធគ្រប់គ្រងសុខភាពភ្នែកពីក្រសួងសុខាភិបាល មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងមន្ទីរពេទ្យ រួមទាំងបញ្ជាក់ខ្សែសង្វាក់ការទទួលខុសត្រូវឱ្យបានច្បាស់លាស់។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖**<br>- សកម្មភាពទាំងនេះនឹងពង្រឹងយន្តការសម្របសម្រួល ដោយសារក្រសួងសុខាភិបាល កម្មវិធីជាតិសុខភាពភ្នែក និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត មានឆន្ទៈក្នុងការកំណត់តួនាទីឱ្យមានលក្ខណៈផ្លូវការ ចូលរួមក្នុងក្រុមការងារបច្ចេកទេស និងចូលរួមក្នុងដំណើរការសម្របសម្រួល និងពិចារណាឆ្លុះបញ្ចាំងជាប្រចាំ។<br><br>**លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ការបង្រឹងកិច្ចសម្របសម្រួល និងអភិបាលកិច្ចដឹកនាំ នឹងកែលម្អអភិបាលកិច្ច និងគណនេយ្យភាព ព្រោះថាអាណត្តិប្រកបដោយភាពច្បាស់លាស់ កិច្ចសម្របសម្រួលទៀងទាត់ និងការឆ្លុះបញ្ចាំងដែលមានរចនាសម្ព័ន្ធច្បាស់លាស់ នឹងជួយឱ្យការរៀបចំផែនការ ការតាមដាន និងការកែតម្រូវសកម្មភាព ប្រកបដោយប្រៀបភាពនៅគ្រប់កម្រិតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។. | | | | | |
| | រៀបចំក្របខណ្ឌនៃការទទួលខុសត្រូវ (TORs) និងផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់អនុក្រុមការងារបច្ចេកទេសសុខភាពភ្នែក (Eye Health Sub-TWG) / រចនាសម្ព័ន្ធអភិបាលកិច្ច នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈសិក្ខាសាលាពិគ្រោះយោបល់។ | | | | | | |
| | ប្រជុំពិនិត្យឡើងវិញប្រចាំឆ្នាំ (Annual Review) លើផែនការសកម្មភាពរបស់អនុក្រុមការងារបច្ចេកទេស នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | | | | | | |
| | ដំណើរការប្រជុំសម្របសម្រួលជាប្រចាំរបស់អនុក្រុមការងារបច្ចេកទេសសុខភាពភ្នែក ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នា និងការត្រួតពិនិត្យបច្ចេកទេសនៅថ្នាក់ជាតិ ព្រមទាំងការធ្វើសមាហរណកម្ម ទៅថ្នាក់ក្រោមជាតិ។ | | | | | | |
| | រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំង និងរៀបចំផែនការប្រចាំឆ្នាំ ដើម្បីពិនិត្យមើលវឌ្ឍនភាព កំណត់បញ្ហាប្រឈម ព្រមព្រៀងលើវិធានការដោះស្រាយ/កាត់បន្ថយហានិភ័យ និងធ្វើបច្ចុប្បន្នភាពផែនការការងារប្រចាំឆ្នាំបន្ទាប់។ | | | | | | |

| គោលបំណង/គោលដៅគម្រោង៖ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាចម្បង។ | | | | | | | |
|---|---|---|---|---|---|---|---|
| **សមិទ្ធផលចុងក្រោយនៃគម្រោង៖** ***នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្តល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។*** | | | | | | | |
| **សមិទ្ធផល / លទ្ធផលរំពឹងទុក៖** | **សកម្មភាព** | **សម្មតិកម្ម៖** *សូមគិតជាសេចក្តីថ្លែង "ដោយសារ"៖ សកម្មភាពនឹងសម្រេចបានលទ្ធផលរំពឹងទុក ដោយសារ... ហើយលទ្ធផលរំពឹងទុកនឹងសម្រេចបានសមិទ្ធផល ដោយសារ...* | **រយៈពេល៖ Y1** | **Y2** | **Y3** | **Y4** | **Y4** |
| **លទ្ធផលរំពឹងទុក ១.២៖** អាទិភាពសុខភាពភ្នែក ត្រូវបានដាក់បញ្ចូលទៅក្នុង គោលនយោបាយ ផែនការ និងក្របខណ្ឌហិរញ្ញប្បទាន របស់រាជរដ្ឋាភិបាល (ក្នុងវិស័យពាក់ព័ន្ធ រួមមាន សុខាភិបាល អប់រំ កិច្ចគាំពារសង្គម យេនឌ័រ និងពិការភាព)។ | រៀបចំវេទិកាអន្តរវិស័យ (ក្រសួងកិច្ចការនារី-MoWA, ក្រសួងអប់រំ យុវជន និងកីឡា-MoEYS, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/ក្រុមប្រឹក្សាសកម្មភាពជនពិការ-MoSVY/DAC, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ-MoLVT, ក្រសួងសាធារណការ និងដឹកជញ្ជូន-MPWT និងដៃគូអភិវឌ្ឍន៍) ដើម្បីបញ្ជ្រាបការងារសុខភាពភ្នែកទៅក្នុងកម្រិតជាតិ។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖**<br>- ការសន្ទនាស្តីពីគោលនយោបាយ ការគាំទ្រដល់ការរៀបចំផែនការ និងសកម្មភាពស្វែងរកការគាំទ្រ នឹងនាំទៅដល់ការបញ្ចូលសុខភាពភ្នែកទៅក្នុងប្រព័ន្ធរួម ពីព្រោះក្រសួង និងដៃគូពាក់ព័ន្ធបានទទួលស្គាល់ថា សុខភាពភ្នែកគឺស្របទៅនឹងអាទិភាពនៃវិស័យសុខាភិបាល អប់រំ កិច្ចគាំពារសង្គម យេនឌ័រ និងពិការភាព។<br><br>**លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ការបញ្ចូលសុខភាពភ្នែកទៅក្នុងគោលនយោបាយ និងការបែងចែកថវិកា នឹងពង្រឹងអភិបាលកិច្ចប្រព័ន្ធ ពីព្រោះការបញ្ចូលទៅក្នុងអាណត្តិផ្លូវការ និងថវិការដ្ឋ នឹងអនុញ្ញាតឱ្យមានការអនុវត្តប្រកបដោយចីរភាព បន្ទាប់ពីការគាំទ្រពីគម្រោងត្រូវបានបញ្ចប់។ | | | | | |
| | ពិនិត្យឡើងវិញ និងធ្វើសមាហរណកម្មសេវាសុខភាពភ្នែក ទៅក្នុងសំណុំសកម្មភាពបង្គ្រប់ (CPA) និងកញ្ចប់សេវាសកម្មភាពអប្បបរមា (MPA) តាមរយៈកិច្ចប្រជុំសិក្ខាសាលា និងការបណ្តុះបណ្តាល នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យ។ | | | | | | |
| | រៀបចំ និងបង្ហាញលទ្ធផលករណីសិក្សានៃការវិនិយោគលើសុខភាពភ្នែក (Eye health investment cases) និងឯកសារសង្ខេបគោលនយោបាយ (Policy briefs) ដើម្បីទាក់ទាញការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) និងស្វែងរកការគាំទ្រដើម្បីទទួលបានជួរថវិកាផ្ទាល់ខ្លួន (Dedicated budget lines) នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់ឃុំ-សង្កាត់។ | | | | | | |
| | ការស្វែងរកការគាំទ្រ គឺដើម្បីបញ្ជ្រាបសេវាសុខភាពភ្នែកបន្ថែម (ដូចជា វ៉ែនតា) ទៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម/គាំពារសង្គម (ដូចជា មូលនិធិសមធម៌សុខាភិបាល-HEF / បេឡាជាតិសន្តិសុខសង្គម-NSSF) ដើម្បីពង្រឹងកិច្ចគាំពារហិរញ្ញវត្ថុសម្រាប់ក្រុមងាយរងគ្រោះ។ | | | | | | |
| | ធ្វើកិច្ចសម្របសម្រួលជាប្រចាំជាមួយដៃគូអង្គការក្រៅរដ្ឋាភិបាល (NGOs) និងរាជរដ្ឋាភិបាល ដើម្បីពង្រឹងការធ្វើសមាហរណកម្ម សុខភាពភ្នែកទៅក្នុងគោលនយោបាយជាតិ។ | | | | | | |
| | ធ្វើការស្វែងរកការគាំទ្រជាយុទ្ធសាស្ត្រ និងការរៀបចំការផ្សព្វផ្សាយព័ត៌មាន តាមរយៈព្រឹត្តិការណ៍ជាតិសំខាន់ៗ (ឧទាហរណ៍៖ ទិវាសុខភាពភ្នែកពិភពលោក -WSD, ទិវានារីអន្តរជាតិ-IWD, ទិវាកុមារ) ដើម្បីរក្សានិរន្តរភាពនៃភាពមើលឃើញ (Visibility) និងការប្តេជ្ញាចិត្តឆ្លងវិស័យ។ | | | | | | |

| គោលបំណង/គោលដៅគម្រោង៖ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាចម្បង។ | | | | | | | |
|---|---|---|---|---|---|---|---|
| **សមិទ្ធផលចុងក្រោយនៃគម្រោង៖** ***នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្តល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។*** | | | | | | | |
| **សមិទ្ធផល / លទ្ធផលរំពឹងទុក៖** | **សកម្មភាព** | **សម្មតិកម្ម៖**<br>*សូមគិតជាសេចក្តីថ្លែង "ដោយសារ"៖ សកម្មភាពនឹងសម្រេចបានលទ្ធផលរំពឹងទុក ដោយសារ... ហើយលទ្ធផលរំពឹងទុកនឹងសម្រេចបានសមិទ្ធផល ដោយសារ...* | **រយៈពេល៖** | | | | |
| | | | Y1 | Y2 | Y3 | Y4 | Y4 |
| **លទ្ធផលរំពឹងទុក ១.៣៖** ការធ្វើផែនការ ការចុះអភិបាលកិច្ច និងការត្រួតពិនិត្យ តាមដានលទ្ធផលការងារ ផ្នែកសុខភាពភ្នែក ត្រូវបានរៀបចំឱ្យមានស្តង់ដាររួម និងបានបញ្ចូលទៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាល។ | ធ្វើការវាយតម្លៃថ្នាក់ជាតិ (ឧទាហរណ៍៖ ការអង្កេតរហ័ស RAAB និងការវាយតម្លៃសុខភាពភ្នែក ECSAT និង RESAT របស់អង្គការសុខភាពពិភពលោក/WHO) ដើម្បីពង្រឹងភស្តុតាងជាមូលដ្ឋាន និងគាំទ្រដល់ការផ្សព្វផ្សាយលទ្ធផលវាយតម្លៃ ដើម្បីជះឥទ្ធិពលដល់ដំណើរការរៀបចំផែនការ និងការអភិវឌ្ឍគោលនយោបាយសំខាន់ៗ។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖**<br>- ការវាយតម្លៃថ្នាក់ជាតិ ការអភិវឌ្ឍយុទ្ធសាស្ត្រ ការចុះ ត្រួតពិនិត្យ/តម្រង់ទិស និងការពង្រឹងប្រព័ន្ធទិន្នន័យ នឹងធ្វើឱ្យការរៀបចំផែនការ និងការតាមដានមានស្តង់ដាររួមមួយ ពីព្រោះប្រព័ន្ធរដ្ឋាភិបាល និងមន្ត្រីបុគ្គលិកមានសមត្ថភាព និងឆន្ទៈក្នុងការយកឧបករណ៍ សូចនាករ និងវិធីសាស្ត្រចុះកាត់ត្រួតពិនិត្យរួមមកអនុវត្ត។<br><br>**លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ការរៀបចំផែនការ និងការតាមដានប្រកបដោយស្តង់ដាររួម នឹងកែលម្អអភិបាលកិច្ច និងគណនេយ្យភាព ពីព្រោះទិន្នន័យ ការចុះត្រួតពិនិត្យ/តម្រង់ទិស និងព័ត៌មានត្រឡប់ដែលមានភាពស៊ីសង្វាក់គ្នា នឹងជួយគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង និងការគ្រប់គ្រងសមិទ្ធកម្ម។. | | | | | |
| | ពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងនិងបង្ការភាពពិការភ្នែក (NSP-BPC) ឆ្នាំ២០២១-២០៣០ និងតាក់តែងសេចក្តីព្រាងយុទ្ធសាស្ត្រដំណាក់កាលបន្ទាប់ឆ្នាំ២០៣១+ ដោយមានអាទិភាព និងទិសដៅអនុវត្តច្បាស់លាស់។ | | | | | | |
| | គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រថ្នាក់ជាតិ និងការអនុវត្តផែនទីបង្ហាញផ្លូវ (Roadmaps) នៅថ្នាក់ក្រោមជាតិ។ | | | | | | |
| | ការចុះអភិបាលកិច្ច គាំទ្រ និងផ្តល់ប្រឹក្សាណែនាំ (ដោយក្រសួងសុខាភិបាល/MoH, មន្ទីរសុខាភិបាលខេត្ត/PHD, ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ/OD) ដោយផ្តោតលើការតម្រង់ទិស (Coaching) និងការកែលម្អប្រសិទ្ធភាពការងារ។ | | | | | | |
| | ការធ្វើសមាហរណកម្ម សូចនាករសុខភាពភ្នែកទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល (HMIS)/DHIS-2 និងប្រព័ន្ធមូលដ្ឋានទិន្នន័យសុខាភិបាលពាក់ព័ន្ធផ្សេងទៀត ព្រមទាំងប្រើប្រាស់ផ្ទាំងគ្រប់គ្រងទិន្នន័យ (Dashboards) សម្រាប់ការតាមដានត្រួតពិនិត្យជាប្រចាំ ការរៀបចំផែនការរួម និងការធ្វើសេចក្តីសម្រេចចិត្ត។ | | | | | | |
| | រៀបចំ និងដាក់ឱ្យអនុវត្តនូវនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ធ្វើការតាមដានត្រួតពិនិត្យនៅមូលដ្ឋានផ្ទាល់ (Field monitoring) និងកសាងសមត្ថភាពសម្រាប់ការប្រើប្រាស់ទិន្នន័យជាប្រចាំនៅគ្រប់លំដាប់ថ្នាក់។ | | | | | | |
| **លទ្ធផលរំពឹងទុក ១.៤៖** ប្រព័ន្ធធានាគុណភាពថ្នាក់ជាតិ ការគ្រប់គ្រងផ្នែកគ្លីនិក និងបទប្បញ្ញត្តិ(ក្រមប្រតិបត្តិវិជ្ជាជីវៈ) / ការ | ធ្វើបច្ចុប្បន្នភាពស្តង់ដារថែទាំព្យាបាលថ្នាក់ជាតិ នីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) និងគោលការណ៍ណែនាំ CPA/MPA ដែលពាក់ព័ន្ធ ឱ្យស្របតាមភស្តុតាងបែបវិទ្យាសាស្ត្រសកល និងអនុសាសន៍របស់អង្គការសុខភាពពិភពលោក (WHO) ព្រមទាំងធ្វើការផ្សព្វផ្សាយ។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖**<br>- ការធ្វើបច្ចុប្បន្នភាពស្តង់ដារ ការពង្រឹងការធានាគុណភាព/ការកែលម្អគុណភាព (QA/QI) ទៅក្នុងប្រព័ន្ធនៃក្រសួងសុខាភិបាល និងការចូលរួមជាមួយស្ថាប័នបញ្ញត្តិ/និយ័តករ នឹងកែលម្អការត្រួតពិនិត្យ និងការគ្រប់គ្រង ពីព្រោះអ្នកផ្តល់សេវាទាំងរដ្ឋ និង | | | | | |

| គោលបំណង/គោលដៅគម្រោង៖ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាចម្បង។ | | | | | | | |
|---|---|---|---|---|---|---|---|
| **សមិទ្ធផលចុងក្រោយនៃគម្រោង៖** *នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្តល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។* | | | | | | | |
| សមិទ្ធផល / លទ្ធផលរំពឹងទុក៖ | សកម្មភាព | សម្មតិកម្ម៖ *សូមគិតជាសេចក្តីថ្លែង "ដោយសារ"៖ សកម្មភាពនឹងសម្រេចបានលទ្ធផលរំពឹងទុកដោយសារ... ហើយលទ្ធផលរំពឹងទុកនឹងសម្រេចបានសមិទ្ធផល ដោយសារ...* | រយៈពេល៖ | | | | |
| | | | Y1 | Y2 | Y3 | Y4 | Y4 |
| ត្រួតពិនិត្យ សេវាសុខភាពភ្នែកក្នុងវិស័យសាធារណៈ និងឯកជន ត្រូវបានពង្រឹង។ | ពង្រឹង និងធ្វើសមាហរណកម្ម ប្រព័ន្ធធានាគុណភាព និងការកែលម្អគុណភាព (QA/QI) សុខភាពភ្នែក ទៅក្នុងប្រព័ន្ធ QA/QI ថ្នាក់ជាតិនៃក្រសួងសុខាភិបាល (រួមមាន ឧបករណ៍វាស់វែង សូចនាករ សវនកម្មថែទាំព្យាបាល និងការវាយតម្លៃដោយរៀមច្បង/មិត្តរួមការងារ) តាមរយៈការបណ្តុះបណ្តាល កិច្ចប្រជុំ ការតម្រង់ទិស (Coaching) និងសិក្ខាសាលា ព្រមទាំងអនុវត្តឧបករណ៍កែលម្អគុណភាពជាបន្តបន្ទាប់នៅកម្រិតមូលដ្ឋានសុខាភិបាល។ | ឯកជន ទទួលស្គាល់ស្តង់ដារជាតិ ហើយចូលរួមក្នុងដំណើរការធានាគុណភាព និងដំណើរការប្បញ្ញត្តិ។<br><br>**លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ការពង្រឹងការធានាគុណភាព និងបទប្បញ្ញត្តិ នឹងកែលម្អអភិបាលកិច្ច និងគុណភាពសេវា ពីព្រោះស្តង់ដារប្រកបដោយភាពច្បាស់លាស់ យន្តការត្រួតពិនិត្យពិនិត្យមើលខុសត្រូវ និងគណនេយ្យភាព គឺជាជម្រុញឱ្យការអនុវត្តគ្លីនិកកាន់តែមានសុវត្ថិភាព និងមានភាពស៊ីសង្វាក់គ្នាកាន់តែប្រសើរ។ | | | | | |
| | ចាត់តាំងមន្ត្រីផ្នែកលើកកម្ពស់គុណភាព (CQI) សុខភាពភ្នែក នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបញ្ជ្រាបពួកគាត់ទៅក្នុងរចនាសម្ព័ន្ធ CQI របស់ក្រសួងសុខាភិបាល ដើម្បីគាំទ្រ និងតាមដានត្រួតពិនិត្យគុណភាពសេវាថែទាំភ្នែក។ | | | | | | |
| | ដាក់ឱ្យប្រើប្រាស់ និងអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ពីអ្នកជំងឺ (ឧទាហរណ៍៖ ការស្ទង់មតិកម្រិតសេចក្តីពេញចិត្ត) ដើម្បីជាព័ត៌មានសម្រាប់ការកែលម្អការផ្តល់សេវា។ | | | | | | |
| | គាំទ្រការពិនិត្យឡើងវិញ និងការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ ព្រមទាំងការផ្តល់អាជ្ញាប័ណ្ណសម្រាប់ហាងវ៉ែនតាឯកជន មណ្ឌលថែទាំភ្នែក (Vision centers) និងគ្លីនិកភ្នែកឯកជនផ្សេងទៀត។ | | | | | | |
| | ពង្រឹងប្រព័ន្ធ និងខ្សែចង្វាក់បញ្ជូនបន្តរវាងវិស័យសាធារណៈ និងឯកជន ព្រមទាំងកែលម្អការចែករំលែក/ការរាយការណ៍ទិន្នន័យ ឱ្យស្របតាមប្រព័ន្ធតាមដានត្រួតពិនិត្យថ្នាក់ជាតិ។ | | | | | | |
| | សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល (MoH) និងក្រសួងពាណិជ្ជកម្ម (MoC) ដើម្បីគ្រប់គ្រងលើសំភារៈបរិក្ខាផ្នែកសុខភាពភ្នែក (ឧ. វ៉ែនតា/កែវភ្នែក) និងស្តង់ដារសេវាកម្មក្នុងវិស័យឯកជន។ | | | | | | |
| | លើកកម្ពស់ក្រមសីលធម៌ និងស្តង់ដារវិជ្ជាជីវៈ ចំពោះមន្ត្រីសុខភាពភ្នែក (រួមទាំងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ)។ | | | | | | |
| **សមិទ្ធិផលទី២៖** មន្ត្រីផ្នែកសុខភាពភ្នែកមានសមត្ថភាព ការគ្រប់គ្រងនិងបែងចែកមន្ត្រីប្រកបដោយសមធម៌ ត្រូវបានអភិវឌ្ឍ និងដាក់បញ្ចូល ជាផ្នែកមួយនៃប្រព័ន្ធរបស់ជាតិប្រកបដោយនិរន្តរភាព។ | | | | | | | |

| គោលបំណង/គោលដៅគម្រោង៖ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាចម្បង។ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **សមិទ្ធផលចុងក្រោយនៃគម្រោង៖** ***នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្តល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។*** | | | | | | | | |
| សមិទ្ធផល / លទ្ធផលរំពឹងទុក៖ | សកម្មភាព | សម្មតិកម្ម៖ *សូមគិតជាសេចក្តីថ្លែង "ដោយសារ"៖ សកម្មភាពនឹងសម្រេចបានលទ្ធផលរំពឹងទុកដោយសារ... ហើយលទ្ធផលរំពឹងទុកនឹងសម្រេចបានសមិទ្ធផល ដោយសារ...* | រយៈពេល៖ | | | | | |
| | | | Y1 | Y2 | Y3 | Y4 | Y4 | |
| **លទ្ធផលរំពឹងទុក ២.១៖** ការអប់រំ និងការបណ្តុះបណ្តាលធនធានមនុស្សផ្នែកសុខភាពភ្នែកមុនចូលបម្រើការងារ ត្រូវបានពង្រឹង និងដាក់បញ្ចូលជាប្រព័ន្ធ រួមទាំងការទទួលស្គាល់គុណភាពជាផ្លូវការ។ | រៀបចំកម្មវិធីសិក្សាមុនពេលបម្រើការងារផ្អែកលើសមត្ថភាព (Competency-based pre-service curricula) និងផែនការបង្រៀនស្តង់ដារ សម្រាប់កម្មវិធីសិក្សាអាទិភាព (រាប់បញ្ចូលទាំងបរិញ្ញាបត្រចក្ខុមាត្រសាស្ត្រ /ការវាស់ភ្នែក និងកាត់វ៉ែនតា)។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖**<br>- ការអភិវឌ្ឍកម្មវិធីសិក្សា ការទទួលស្គាល់គុណភាពអប់រំ (គុណវុឌ្ឍិ) និងការកែលម្អការបង្រៀន នឹងពង្រឹងការអប់រំមុនពេលចូលបម្រើការងារ (Pre-service education) ពីព្រោះសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) និងគ្រឹះស្ថានបណ្តុះបណ្តាលផ្សេងទៀត មានអាណត្តិ និងសមត្ថភាពក្នុងការធ្វើបរិយាបន្នការកែទម្រង់កម្មវិធីសិក្សា និងស្តង់ដារគុណភាពទៅក្នុងប្រព័ន្ធផ្លូវការ។<br><br>**លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ការពង្រឹងការអប់រំមុនពេលចូលបម្រើការងារ នឹងរួមចំណែកដល់ការបង្កើតកម្លាំងពលកម្មដែលមានសមត្ថភាព ពីព្រោះនិស្សិតដែលបញ្ចប់ការសិក្សា ចូលប្រឡូកក្នុងប្រព័ន្ធការងារដោយប្រកបដោយសមត្ថភាពដែលមានភាពស៊ីសង្វាក់គ្នា និងទទួលបានការទទួលស្គាល់គុណភាព ស្របទៅតាមតម្រូវការសេវាកម្មថ្នាក់ជាតិ។ | | | | | | |
| | បង្កើត និងដាក់ឱ្យដំណើរការកម្មវិធីអប់រំកម្រិតបរិញ្ញាបត្រចក្ខុមាត្រសាស្ត្រ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS)។ | | | | | | | |
| | ពង្រឹងគុណភាពអប់រំ ដោយការលើកកម្ពស់វិធីសាស្ត្របង្រៀន ការកែលម្អប្រព័ន្ធវាយតម្លៃ និងការធ្វើបច្ចុប្បន្នភាពវេទិកាសិក្សាឌីជីថល ព្រមទាំងបន្ទប់ពិសោធន៍បំណិនអនុវត្ត (Skills laboratories)។ | | | | | | | |
| | លើកកម្ពស់ការចុះកម្មសិក្សា និងការផ្លាស់ប្តូរវេនថែទាំព្យាបាលដែលមានចេតនាសម្ព័ន្ធច្បាស់លាស់ ដោយពង្រឹងការផ្តល់ប្រឹក្សាណែនាំ និងការត្រួតពិនិត្យគាំទ្រអំឡុងពេលចុះកម្មសិក្សា (Internship) ដើម្បីកែលម្អបំណិនអនុវត្តផ្ទាល់ និងសមត្ថភាពថែទាំព្យាបាល។ | | | | | | | |
| | គាំទ្រដំណើរការទទួលស្គាល់គុណវុឌ្ឍិ/គុណភាព (Accreditation) កម្រិតជាតិ និងតំបន់ សម្រាប់កម្មវិធីសិក្សាអប់រំដែលបានជ្រើសរើស (ឧទាហរណ៍៖ AUN-QA នៅតាមទីកន្លែងដែលពាក់ព័ន្ធ) និងទទួលស្គាល់គុណភាពមន្ទីរពេទ្យជាតិដែលបានជ្រើសរើស ជាទីតាំងបណ្តុះបណ្តាល និងបង្រៀនអនុវត្តថែទាំព្យាបាល។ | | | | | | | |
| | គាំទ្រសកម្មភាពស្រាវជ្រាវផ្នែកថែទាំព្យាបាល និងការបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវទាំងកម្រិតក្នុងស្រុក និងអន្តរជាតិ ដោយនិស្សិត និងសាស្ត្រាចារ្យ ដើម្បីលើកកម្ពស់គុណភាពអប់រំ និងការអនុវត្តការថែទាំព្យាបាល។ | | | | | | | |
| **លទ្ធផលរំពឹងទុក ២.២៖** ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្ត ការបង្វឹក ការចុះអភិបាលកិច្ច ការផ្លាស់ប្តូរចំណេះដឹង និងការរៀនសូត្រពី | ពង្រឹងក្រុមអ្នកផ្តល់ប្រឹក្សាណែនាំផ្នែកថែទាំព្យាបាលថ្នាក់ជាតិជំនាន់ថ្មី (ផ្នែកចក្ខុសាស្ត្រ ការថែទាំអ្នកជំងឺភ្នែក និងការវាស់ភ្នែក និងកាត់វ៉ែនតា) ដើម្បីបង្កើតបណ្តាញអ្នកផ្តល់ប្រឹក្សាណែនាំប្រកបដោយចីរភាព សម្រាប់គាំទ្រដល់ការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តនៅទូទាំងវិស័យ។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖**<br>- សកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ការផ្តល់ប្រឹក្សាណែនាំ ការត្រួតពិនិត្យគាំទ្រ និងការផ្លាស់ប្តូរចំណេះដឹង នឹងត្រូវអនុវត្តយ៉ាងសកម្ម ដោយសារស្ថាប័នវិជ្ជាជីវៈ អ្នកផ្តល់ | | | | | | |

**គោលបំណង/គោលដៅគម្រោង៖ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាចម្បង។**

**សមិទ្ធផលចុងក្រោយនៃគម្រោង៖** ***នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្តល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។***

| សមិទ្ធផល / លទ្ធផលរំពឹងទុក៖ | សកម្មភាព | សម្មតិកម្ម៖<br>*សូមគិតជាសេចក្តីថ្លែង "ដោយសារ"៖ សកម្មភាពនឹងសម្រេចបានលទ្ធផលរំពឹងទុក ដោយសារ... ហើយលទ្ធផលរំពឹងទុកនឹងសម្រេចបានសមិទ្ធផល ដោយសារ...* | រយៈពេល៖ Y1 | Y2 | Y3 | Y4 | Y4 |
|---|---|---|---|---|---|---|---|
| បទពិសោធន៍ ត្រូវបានបង្កើត និងដំណើរការប្រកបដោយប្រសិទ្ធភាព។ | ផ្តល់នូវគំនិតផ្តួចផ្តើមអាទិភាពផ្នែកអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងការពង្រឹងសមត្ថភាព រាប់បញ្ចូលទាំង ការបណ្តុះបណ្តាល ការវះកាត់ភ្នែកឡើងបាយ, ការគ្រប់គ្រងជំងឺភ្នែកនៅកម្រិតមូលដ្ឋាន CPA-1 និង CPA-2 សម្រាប់វេជ្ជបណ្ឌិត, ការថែទាំភ្នែកនៅកម្រិតបឋមសម្រាប់បុគ្គលិកមណ្ឌលសុខភាព, សិក្ខាសាលាតាមបណ្តាញអ៊ីនធឺណិត (Webinars), មហាសន្និបាតវិជ្ជាជីវៈ, ជំនាញឯកទេសរងផ្នែកសុខភាពភ្នែក និងវគ្គបណ្តុះបណ្តាលផ្សេងទៀត។ | ប្រឹក្សាណែនាំ និងបុគ្គលិកសុខាភិបាល ចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការសិក្សា និងការត្រួតពិនិត្យគាំទ្រដែលមានចេតនាសម្ព័ន្ធច្បាស់លាស់។<br><br>**លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងប្រព័ន្ធផ្តល់ប្រឹក្សាណែនាំ ដែលដំណើរការយ៉ាងរលូន នឹងជួយរក្សាសមត្ថភាពបុគ្គលិក ដោយសារការសិក្សាបន្ត និងការត្រួតពិនិត្យគាំទ្រ ជួយកែលម្អប្រសិទ្ធភាពនៃការថែទាំព្យាបាល និងកាត់បន្ថយការបាត់បង់បំណិនទៅតាមពេលវេលា។ | | | | | |
| | អនុវត្តការផ្តល់ប្រឹក្សាណែនាំ ការតម្រង់ទិស (Coaching) ការត្រួតពិនិត្យតាមដានការសិក្សាក្នុងចំណោមក្រុមការងារ (Peer-to-peer learning) ដំណើរទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ និងក្លឹបសិក្សាអត្ថបទវិទ្យាសាស្ត្រ (Journal club) ដើម្បីគាំទ្រ និងពង្រឹងសមត្ថភាពបុគ្គលិកសុខភាពភ្នែក នៅតាមមូលដ្ឋានសុខាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | | | | | | |
| | គាំទ្រសកម្មភាពស្រាវជ្រាវផ្នែកថែទាំព្យាបាល និងការបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិ ដោយបុគ្គលិកសុខភាពភ្នែក ដើម្បីលើកកម្ពស់លទ្ធផលនៃការថែទាំព្យាបាល និងការអនុវត្តវិជ្ជាជីវៈ។ | | | | | | |
| **លទ្ធផលរំពឹងទុក ២.៣៖** ធនធានមន្ត្រីសុខភាពភ្នែក ត្រូវបានបង្កើនឱ្យមានចំនួនគ្រប់គ្រាន់ និងបែងចែកប្រកបដោយសមធម៌ តាមរយៈ ការធ្វើការវាយតម្លៃ និងធ្វើផែនទីបង្ហាញផ្លូវលើការបណ្តុះបណ្តាលជាក់លាក់។ | ការស្វែងរកការគាំទ្រ និងពិនិត្យឡើងវិញនូវផែនការអភិវឌ្ឍធនធានមនុស្សផ្នែកសុខភាពភ្នែក សម្រាប់មូលដ្ឋានសុខាភិបាលសាធារណៈ ជាពិសេសនៅតំបន់ដាច់ស្រយាល និងការស្វែងរកការគាំទ្រដើម្បីបង្កើនការជ្រើសរើសបុគ្គលិកបន្ថែម។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖**<br>- វិធានការរៀបចំផែនការកម្លាំងពលកម្ម អាហារូបករណ៍ ការចាត់តាំងឱ្យបម្រើការងារ និងការរក្សាបុគ្គលិក នឹងជួយកែលម្អភាពអាចរកបាននៃបុគ្គលិក ដោយសាររាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គាំទ្រដល់ការបម្រើសេវានៅជនបទ ការផ្តល់ការលើកទឹកចិត្តចំគោលដៅ និងយន្តការចាត់តាំងឱ្យបម្រើការងារប្រកបដោយប្រព័ន្ធសហការ។<br><br>**លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ការកែលម្អភាពអាចរកបាន និងការបែងចែកកម្លាំងពលកម្ម នឹងពង្រឹងសមធម៌នៃការផ្តល់សេវា ដោយសារបុគ្គលិកដែលមានជំនាញ មានវត្តមាននៅជិតកន្លែងដែលប្រជាជនរស់នៅ ជាពិសេសនៅតំបន់ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់។ | | | | | |
| | គាំទ្រអាហារូបករណ៍ដែលមានកិច្ចសន្យាបម្រើការងារចំគោលដៅ សម្រាប់ខេត្តតាមជនបទ/ខេត្តដែលមានតម្រូវការ លើការអប់រំ និងការបណ្តុះបណ្តាលផ្នែកសុខភាពភ្នែក ព្រមទាំងធ្វើកិច្ចសហការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍។ | | | | | | |
| | ការស្វែងរកការគាំទ្រ និងពង្រឹងការចាត់តាំងឱ្យបម្រើការងារ និងការបែងចែកកម្លាំងពលកម្មសុខភាពភ្នែក។ | | | | | | |

| គោលបំណង/គោលដៅគម្រោង៖ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាចម្បង។ | | | | | | | |
|---|---|---|---|---|---|---|---|
| **សមិទ្ធផលចុងក្រោយនៃគម្រោង៖** ***នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្តល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។*** | | | | | | | |
| សមិទ្ធផល / លទ្ធផលរំពឹងទុក៖ | សកម្មភាព | សម្មតិកម្ម៖<br>*សូមគិតជាសេចក្តីថ្លែង "ដោយសារ"៖ សកម្មភាពនឹងសម្រេចបានលទ្ធផលរំពឹងទុក ដោយសារ... ហើយលទ្ធផលរំពឹងទុកនឹងសម្រេចបានសមិទ្ធផល ដោយសារ...* | រយៈពេល៖ Y1 | Y2 | Y3 | Y4 | Y4 |
| **សមិទ្ធផលទី៣៖** ប្រព័ន្ធគាំទ្រ នវានុវត្តន៍បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធ ដែលអំណោយផល ត្រូវបានពង្រឹង ដើម្បីគាំទ្រដល់ការងារអភិបាលកិច្ច ប្រសិទ្ធភាពការងាររបស់មន្ត្រី និងគុណភាពសេវាសុខភាពភ្នែកប្រកបដោយប្រសិទ្ធភាព។ | | | | | | | |
| **លទ្ធផលរំពឹងទុក ៣.១៖** ប្រព័ន្ធសុខាភិបាលឌីជីថល សេវាពិគ្រោះ និងពិនិត្យជំងឺភ្នែកពីចម្ងាយ (Tele-ophthalmology) និងប្រព័ន្ធប្រមូលនិងកត់ត្រាទិន្នន័យ ត្រូវបានដាក់បញ្ចូលទៅក្នុងការផ្តល់សេវាប្រចាំថ្ងៃ ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពសេវាសុខភាពភ្នែក។ | ពង្រឹង និងពង្រីកវិសាលភាពនៃការពិនិត្យព្យាបាលជំងឺភ្នែកពីចម្ងាយ (Tele-ophthalmology) និងប្រព័ន្ធបញ្ជូនបន្តតាមអេឡិចត្រូនិច (e-Referral pathways) (រាប់បញ្ចូលទាំងការបញ្ជូនបន្តទៅកាន់ផ្នែកឯកទេសរង នៅតាមទីកន្លែងដែលពាក់ព័ន្ធ)។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖**<br>- គំនិតផ្តួចផ្តើមផ្នែកសុខាភិបាលឌីជីថល ការពិនិត្យព្យាបាលជំងឺភ្នែកពីចម្ងាយ (Tele-ophthalmology) និងប្រព័ន្ធទិន្នន័យ នឹងត្រូវដាក់បញ្ជ្រាបយ៉ាងល្អ ដោយសារហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ និងបំណិនឌីជីថល មានកម្រិតគ្រប់គ្រាន់ក្នុងការគាំទ្រដល់ការប្រើប្រាស់ជាប្រចាំ និងការធ្វើអាំងតេក្រាលកម្មជាមួយប្រព័ន្ធជាតិ។<br><br>**លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ប្រព័ន្ធឌីជីថលដែលបានដាក់បញ្ជ្រាប នឹងកែលម្អអភិបាលកិច្ច ប្រសិទ្ធភាពការងាររបស់បុគ្គលិក និងគុណភាពសេវា ដោយសារទិន្នន័យជាក់ស្តែង (Real-time) ការគាំទ្រពីចម្ងាយ និងការបញ្ជូនបន្តតាមប្រព័ន្ធឌីជីថល ជួយពង្រឹងការត្រួតពិនិត្យគាំទ្រ កិច្ចសហការសម្របសម្រួល និងការធ្វើការសម្រេចចិត្ត។ | | | | | |
| | ដាក់ឲ្យប្រើប្រាស់ វាយតម្លៃ និងពង្រីកការពិនិត្យស្វែងរកជំងឺ ការធ្វើរោគវិនិច្ឆ័យ និងឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចចិត្តផ្នែកថែទាំព្យាបាល ដោយប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) នៅតាមទីកន្លែងដែលសមស្រប ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់អំពីសុវត្ថិភាព តម្លៃ និងភាពអាចពង្រីកវិសាលភាពបាន។ | | | | | | |
| | រៀបចំ និងលើកកម្ពស់ការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) សម្រាប់ការផ្តល់សេវាឌីជីថល និងសេវាគាំទ្រដោយបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) ដោយគ្របដណ្តប់លើសុវត្ថិភាពអ្នកជំងឺ ឯកជនភាពទិន្នន័យ ព្រមទាំងគុណភាព និងស្ថិរភាពនៃការថែទាំព្យាបាល។ | | | | | | |
| | ពង្រឹងបំណិនឌីជីថលរបស់បុគ្គលិកសុខាភិបាល ដោយរាប់បញ្ចូលទាំងប្រតិបត្តិការប្រព័ន្ធ ការធ្វើរបាយការណ៍ និងការប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធភាព។ | | | | | | |
| | | | | | | | |
| **លទ្ធផលរំពឹងទុក ៣.២៖** មុខងារ និងសមត្ថភាពប្រើប្រាស់ឧបករណ៍ | ធ្វើសវនកម្ម និងបញ្ជីសារពើភ័ណ្ឌបរិក្ខារ ធ្វើការវិភាគគម្លាត និងរៀបចំផែនការបទលទ្ធកម្ម និងការបែងចែកប្រកបដោយអាទិភាព។ | **សកម្មភាព → លទ្ធផលរំពឹងទុក៖** | | | | | |

| គោលបំណង/គោលដៅគម្រោង៖ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានសេវាសុខភាពភ្នែក ដែលមានគុណភាព ប្រកបដោយនិរន្តរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការគ្របដណ្តប់សុខភាពជាសកល និងការថែទាំសុខភាពភ្នែកដែលធ្វើសមាហរណកម្មដោយផ្តោតលើប្រជាជនជាចម្បង។ | | | | | | | |
|---|---|---|---|---|---|---|---|
| **សមិទ្ធផលចុងក្រោយនៃគម្រោង៖** *នៅចុងបញ្ចប់គម្រោង ប្រទេសកម្ពុជានឹងមាន ប្រព័ន្ធសុខភាពភ្នែកដ៏រឹងមាំ ដឹកនាំដោយរាជរដ្ឋាភិបាល និងមន្ត្រីសុខភាពភ្នែកប្រកបដោយសមត្ថភាព អាចផ្តល់សេវាសុខភាពភ្នែកតាមបែបណៈសមាហរណកម្ម មានគុណភាពខ្ពស់ និងប្រកបដោយសមធម៌នៅទូទាំងប្រទេស។* | | | | | | | |
| សមិទ្ធផល / លទ្ធផលរំពឹងទុក៖ | សកម្មភាព | សម្មតិកម្ម៖<br>*សូមគិតជាសេចក្តីថ្លែង "ដោយសារ"៖ សកម្មភាពនឹងសម្រេចបានលទ្ធផលរំពឹងទុក ដោយសារ... ហើយលទ្ធផលរំពឹងទុកនឹងសម្រេចបានសមិទ្ធផល ដោយសារ...* | រយៈពេល៖ | | | | |
| | | | Y1 | Y2 | Y3 | Y4 | Y4 |
| និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗសម្រាប់សុខភាពភ្នែក ត្រូវបានពង្រឹង តាមរយៈ ការធ្វើសវនកម្មជាប្រព័ន្ធ ការថែទាំជាប្រចាំ និងការគ្រប់គ្រង ឧបករណ៍និងសម្ភារបច្ចេកទេស។ | ពង្រឹងប្រព័ន្ធថែទាំជួសជុល ដោយការកសាងសមត្ថភាពអ្នកបច្ចេកទេសជីវវេជ្ជសាស្ត្រ (Biomedical technicians) ការបង្កើតក្រុមបច្ចេកទេសថែទាំ និងជួសជុល ការដាក់បញ្ចូលការគាំទ្រតាមប្រព័ន្ធឌីជីថល នៅតាមទីកន្លែងដែលអាចធ្វើទៅបាន។ | - ការធ្វើសវនកម្មបរិក្ខារ ប្រព័ន្ធថែទាំ និងការគ្រប់គ្រងសម្ភារ បរិក្ខា នឹងពង្រឹងមុខងារដំណើរការ [នៃបរិក្ខារ] ដោយសារមូលដ្ឋានសុខាភិបាល និងបុគ្គលិកបច្ចេកទេស អនុវត្តតាមពិធីសារថែទាំ ហើយរាជរដ្ឋាភិបាលផ្តល់អាទិភាពដល់ការថែទាំជួសជុលបរិក្ខារ។ | | | | | |
| | អនុវត្តការគ្រប់គ្រងឧបករណ៍បរិក្ខារ និងការរៀបចំផែនការ វដ្តនៃការផ្លាស់ប្តូរជំនួស ដើម្បីកាត់បន្ថយពេលវេលាដែលដំណើរការត្រូវរអាក់រអួល (Downtime) និងការពារការវិនិយោគ។ | **លទ្ធផលរំពឹងទុក → សមិទ្ធផល៖**<br>- ការកែលម្អមុខងារដំណើរការនៃបរិក្ខារ នឹងគាំទ្រដល់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ដោយសារហេដ្ឋារចនាសម្ព័ន្ធដែលមានភាពជឿទុកចិត្តបាន ជួយអនុញ្ញាតឱ្យមានការអនុវត្តការថែទាំព្យាបាលប្រកបដោយសុវត្ថិភាព ព្រមទាំងការពារការវិនិយោគលើកម្លាំងពលកម្ម និងប្រព័ន្ធទាំងមូល។ | | | | | |

## 3.4 ថវិកាសរុបសម្រាប់រយៈពេលអនុវត្តគម្រោង

### a. សេដ្ឋកិច្ចភាព និងប្រសិទ្ធភាពចំណាយ (Economy and Cost-Efficiency)

គម្រោង "អភិបាលកិច្ចសុខភាពភ្នែក" (EHG) អនុវត្តគោលការណ៍សេដ្ឋកិច្ចភាព និងប្រសិទ្ធភាពចំណាយពេញមួយដំណាក់កាលនៃការរៀបចំ និងការអនុវត្តគម្រោង ដើម្បីធានាថាធនធានត្រូវបានប្រើប្រាស់ដោយសន្សំសំចៃ និងចំគោលដៅ ក្នុងបំណងសម្រេចឲ្យបាននូវផលប៉ះពាល់កម្រិតប្រព័ន្ធអតិបរមា និងមានចីរភាព។

#### សេដ្ឋកិច្ចភាព Economy

គម្រោង អភិបាលកិច្ចសុខភាពភ្នែក លើកកម្ពស់សេដ្ឋកិច្ចភាពដោយប្រើប្រាស់ធាតុចូលដែលមានគុណភាពសមរម្យក្នុងតម្លៃសមរម្យ ដោយផ្តោតយ៉ាងខ្លាំងលើការទាញយកផលប្រយោជន៍អតិបរមាពីប្រព័ន្ធ និងសមត្ថភាពដែលមានស្រាប់។ សកម្មភាពទាំងនេះរួមមាន៖

- ធ្វើការតាមរយៈប្រព័ន្ធក្រសួងសុខាភិបាល វេទិកាសម្របសម្រួល និងគ្រឹះស្ថានបណ្តុះបណ្តាលដែលមានស្រាប់ ដោយចៀសវាងការបង្កើតរចនាសម្ព័ន្ធត្រួតស៊ីគ្នា (ដដែល)។
- ផ្តល់អាទិភាពដល់អ្នកជំនាញថ្នាក់ជាតិ និងមូលដ្ឋាន ដោយទាញយកការគាំទ្របច្ចេកទេសថ្នាក់តំបន់ ឬពីការិយាល័យកណ្តាល លុះត្រាតែជំនាញឯកទេសនោះមិនមាននៅក្នុងស្រុក។
- តម្រង់ទិសការវិនិយោគលើបរិក្ខារ និងប្រព័ន្ធ តាមរយៈការវាយតម្លៃតម្រូវការ និងការធ្វើសវនកម្ម ដោយផ្តោតលើការថែទាំ និងការគ្រប់គ្រងទ្រព្យសកម្ម ជាជាងការទិញថ្មីដែលមិនចាំបាច់។
- តម្រឹមសកម្មភាពជាមួយកម្មវិធីដែលមានស្រាប់ និងការវិនិយោគរបស់ដៃគូ ដើម្បីកាត់បន្ថយការត្រួតស៊ីគ្នានិងទាញយកប្រយោជន៍ពីធនធានរួមគ្នា។

វិធីសាស្ត្រទាំងនេះជានាំនូវភាពស័ក្តិសមនៃថវិកា (Value for Money) ខណៈពេលដែលនៅតែរក្សាបាននូវគុណភាព និងភាពត្រឹមត្រូវ។

#### ប្រសិទ្ធភាពចំណាយ Cost-Efficiency

ប្រសិទ្ធភាពចំណាយត្រូវបានសម្រេចតាមរយៈការទាញយកលទ្ធផលអតិបរពីការវិនិយោគនីមួយៗ តាមរយៈអន្តរាគមន៍កម្រិតប្រព័ន្ធ ដែលបង្កើតផលប្រយោជន៍ដល់សេវាជាច្រើន និងមានភាពស្ថិតស្ថេរយូរអង្វែង។ សកម្មភាពទាំងនេះរួមមាន៖

- ពង្រឹងអភិបាលកិច្ច ធនធានមនុស្ស ការធានាគុណភាព និងទិន្នន័យ ដែលគាំទ្រដល់ការផ្តល់សេវាបន្តបន្ទាប់ហួសពីកំឡុងពេលអនុវត្តគម្រោង។
- ធ្វើសមាហរណកម្មការអប់រំដែលមានការទទួលស្គាល់គុណភាព ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) ការចុះត្រួតពិនិត្យ/ការត្រួតពិនិត្យបច្ចេកទេស និងការរៀបចំផែនការធនធានមនុស្ស ដើម្បីកាត់បន្ថយការពឹងផ្អែកលើការបណ្តុះបណ្តាលបណ្តោះអាសន្នដែលធ្វើឡើងដដែលៗ។
- ប្រើប្រាស់ប្រព័ន្ធឌីជីថលដើម្បីកែលម្អការសម្របសម្រួល ការត្រួតពិនិត្យ និងការធ្វើសេចក្តីសម្រេចចិត្ត ខណៈពេលដែលកាត់បន្ថយចំណាយចរន្ត ដូចជាការធ្វើដំណើរ និងការរាយការណ៍ដោយដៃ។

- អនុវត្តការគ្រប់គ្រងបែបបត់បែន និងការរៀបចំផែនការថវិកា ដើម្បីផ្តោតធនធានលើអន្តរាគមន៍ដែលមានប្រសិទ្ធភាព និងស័ក្តិសមបំផុត។

គម្រោងចៀសវាងការកាត់បន្ថយចំណាយណាដែលធ្វើឲ្យប៉ះពាល់ដល់គុណភាព សមធម៌ ឬចីរភាព ដោយផ្ទុយទៅវិញ គម្រោងសម្រេចបាននូវប្រសិទ្ធភាពតាមរយៈការរៀបចំប្រព័ន្ធ ការសម្របសម្រួល និងអភិបាលកិច្ចជឿនលឿនជាងមុន។

### b. សមធម៌ Equity

គម្រោងអភិបាលកិច្ចសុខភាពភ្នែក (EHG) បញ្ចូលបរិយាបន្នសមធម៌ទៅក្នុងថវិកាគម្រោង ដើម្បីធានាថាសមភាពយេនឌ័រ បរិយាបន្នពិការភាព និងគោលដៅសមធម៌ទូលំទូលាយត្រូវបានបញ្ចូលជាប្រព័ន្ធនៅក្នុងការវិនិយោគលើអភិបាលកិច្ច ធនធានមនុស្ស គុណភាព និងការពង្រឹងប្រព័ន្ធ។
ក្នុងនាមជាគំនិតផ្តួចផ្តើមដែលផ្តោតលើអភិបាលកិច្ច និងប្រព័ន្ធ គម្រោង EHG មិនពឹងផ្អែកលើសកម្មភាពសមធម៌ដាច់ដោយឡែកនោះទេ។ ផ្ទុយទៅវិញ ការវិនិយោគដែលបានគ្រោងទុកក្នុងថវិកា នឹងធ្វើសមាហរណកម្មសមធម៌ឆ្លងកាត់៖

- ការអភិវឌ្ឍគោលនយោបាយ ការរៀបចំផែនការ និងក្របខ័ណ្ឌបទប្បញ្ញត្តិ
- ការអប់រំ បណ្តុះបណ្តាលធនធានមនុស្ស ការអភិវឌ្ឍវិជ្ជាជីវៈ និងប្រព័ន្ធចាត់ចែង និងគ្រប់គ្រងធនធានមនុស្ស
- ការធានាគុណភាព ប្រព័ន្ធទិន្នន័យ និងយន្តការត្រួតពិនិត្យសេវា

ការបែងចែកថវិកា គឺដើម្បីគាំទ្រដល់ការបញ្ចូលវិធីសាស្ត្រឆ្លើយតបនឹងយេនឌ័រ និងពិការភាពទៅក្នុងការរៀបចំផែនការ ការតាមដាន និងការធានាគុណភាព ដែលជួយឲ្យប្រព័ន្ធសុខភាពភ្នែកអាចកំណត់ និងឆ្លើយតបទៅនឹងវិសមភាព ក្នុងការទទួលបានសេវា គុណភាពសេវា និងការចូលរួមរបស់មន្ត្រីសុខភាពភ្នែក។ នេះរួមបញ្ចូលទាំងការពង្រឹងប្រព័ន្ធទិន្នន័យ និងការតាមដាន ដើម្បីគាំទ្រដល់ការបំបែកទិន្នន័យតាម អាយុ ភេទ (Disaggregation) ដើម្បីជានិរន្តរភាព និងដើម្បីជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដែលផ្តោតលើសមធម៌។

ធនធានក៏ត្រូវបានបែងចែកដើម្បីដោះស្រាយភាពមិនស្មើគ្នាតាមតំបន់ភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គម រួមមានតាមរយៈការរៀបចំផែនការ និងការបែងចែកកម្លាំងពលកម្ម ដំណោះស្រាយសុខភាពឌីជីថល ការពង្រឹងប្រព័ន្ធថ្នាក់ក្រោមជាតិ និងការធ្វើសមាហរណកម្មសុខភាពភ្នែកទៅក្នុងយន្តការគាំពារសង្គម និងហិរញ្ញវត្ថុសាធារណៈ។

តាមរយៈការបង្កប់សមធម៌នៅក្នុងមុខងារស្នូលនៃប្រព័ន្ធ ជាជាងការបំបែកវានៅក្នុងថវិកាសកម្មភាពតូចៗ គម្រោង EHG ធានាថាធនធានគម្រោងនឹងរួមចំណែកដល់លទ្ធផលសមធម៌ទូទាំងប្រព័ន្ធ និងមានចីរភាព ដែលផ្តល់ប្រយោជន៍ដល់ស្ត្រី ជនមានពិការភាព និងប្រជាជនដែលខ្វះខាតសេវា ក្នុងរយៈពេលវែង។

### c. ថវិកាសរុបបណ្តោះអាសន្នសម្រាប់រយៈពេលអនុវត្តគម្រោង Indicative Life-of-Project Budget

សូមចុចលើតំណភ្ជាប់ (Link) ខាងក្រោម ដើម្បីពិនិត្យមើលថវិកា និងផែនការការងារ។

260413- KH26-01- Budget and Work Plan for Eye Health Governance project.xlsx

# 4. Monitoring, Evaluation, Research and Learning

## 4.1 M&E Plan

| | Indicator* | Definition and Unit of Measure | Baseline | Target | Data Source | Data Disaggregated by | Frequency | Data Collection Methods | Responsible Party |
|---|---|---|---|---|---|---|---|---|---|
| | Establishment of a Bachelor of Optometry program at UHS | Counting on this new accredited pre-service education program will increase the supply of qualified eye health professionals. | 0 | 1 | UHS Report | NA | Annual | Report | |
| | Proportion of targeted provinces with functional eye health Sub-Technical Working Groups (TWGs) that meet at least twice per year | (Target: ≥ 80% of provinces. *Means of verification:* Meeting minutes and TWG action plans (documented evidence of biannual meetings) Functional coordination mechanisms are those that: meet regularly, maintain documented actions, review performance data, and support planning or implementation decisions. | NA | times | Minute | By province | Quarterly | MoH report | |
| | Number of national or sub-national policies or plans that incorporate eye health priorities | Count of national or sectoral policies/guidelines that include eye health. | 0 | 6 | MoH record/partners' record | By province | Annual | Review Report | |

| | Indicator* | Definition and Unit of Measure | Baseline | Target | Data Source | Data Disaggregated by | Frequency | Data Collection Methods | Responsible Party |
|---|---|---|---|---|---|---|---|---|---|
| Outputs indicators | No of community members provided with eye health information | The indicator measures the count of community members that have benefited from eye health information sessions. | 0 | 5,000 | Partners record | Gender and Disability | Quarterly | Review of attendance register | |
| | Number of health staff trained in primary eye care integration into primary health care training | Count number of health staff receive primary eye care training. | 0 | 500 | Project report | Gender | Quarterly | Review record | |
| | Availability of eye health road map at national and sub national level | Existence of a national or subnational strategic plan for eye health with defined targets and budget. | 9 | 14 | Partner Report | By province | Annual | Report | |
| | Number of cataract and other eye diseases surgery performed. | Total number of cataract surgeries performed. | NA | 10,000 | Report | Disaggregated gender and disability | Quarterly | Review record | |
| | Number of Eye Unit, PVC and Primary Health Service provide refractive services improvement in the government health system (eye care service access) | Number of government facilities providing eye care services in the country with available refractive services. | | 12 EUs, 32 PVCs, 500 PHS | Report | Disaggregate by eye unite, PVC, PHS | Annual | Report | |
| | Eye health quality improvement is integrated into | Eye health indicators is integrated into MoH CQI system. | NA | 100% | MoH record | Province | Annual | Report | |

| | Indicator* | Definition and Unit of Measure | Baseline | Target | Data Source | Data Disaggregated by | Frequency | Data Collection Methods | Responsible Party |
|---|---|---|---|---|---|---|---|---|---|
| | government MoH CQI systems. | | | | | | | | |
| | Eye health indicators is update and function in HMIS/DHIS2 | Proportion of facilities reporting eye health data into national health information systems. | NA | 12 EUs,<br>32 PVCs,<br>500 PHS | MoH System | Province | Annual | Report | |
| | Availability of workforce mapping and planning | Existence of national workforce assessment/mapping used to inform planning and deployment. | NA | 1 | Assessment Report | NA | 5 years | Assessment | |
| Activities indicators | Number of health facilities received supportive supervision visit from national and subnational level | The indicator tracks the number of support supervision sessions supported by national MOH | 0 | 500 at sub national level and 20 from national level | Health facility records | None | Annual | Review of attendance register | |
| | Continuous professional development (CPD) annually | Proportion of eye health workforce participating in CPD within a year<br>• Number of partner learning and reflection workshops conducted | NA | 140 | Partner report | Disaggregate by gender | Annually | Report | |
| | % of facilities reporting Cataract Surgical Outcome Monitoring (CSOM) data | Count facilities under FHF support report CSOM | 0 | 14 | Report | By Provinces | Annually | Report | |

| | Indicator* | Definition and Unit of Measure | Baseline | Target | Data Source | Data Disaggregated by | Frequency | Data Collection Methods | Responsible Party |
|---|---|---|---|---|---|---|---|---|---|
| | Number of health are professional received supervision/mentorship | Number staff receiving regular supportive supervision | 0 | 4/Year | Report | By provinces | Quarterly | Report | |
| | Implementation of tele-ophthalmology e-referral network | Establish the tele opt system from national program to subnational level | 0 | 14 | Report | By Provinces | Annually | Report | |
| | Number of health facilities implementation of quality assurance systems | Number of facilities implementing QA/clinical governance standards | 0 | 12 EUs,<br>32 PVCs,<br>500 PHS | Report | By Provinces | Annually | Report | |

## 4.2 Planned Evaluations Table

| Type of evaluation | Timing | Budget | Notes |
|---|---|---|---|
| Baseline Evaluation | 2026 (project start-up phase) | Included within project set-up and routine M&E costs | A standalone baseline evaluation is not planned, as the project design is informed by existing evidence (RAAB 2019, CDHS 2021–22, MSAT, partner assessments, and national planning processes). Baseline data for key governance, workforce, quality, and system indicators will be drawn from routine data systems, policy documents, MSAT results, and early implementation monitoring. |

| | | | |
|---|---|---|---|
| Mid-term evaluation | **January 2029** (mid-Year 3) | **USD 10,000** (internal / mixed-method review) | The mid-term evaluation will focus on implementation progress, effectiveness, and adaptive learning, particularly: (i) functionality of governance and coordination mechanisms; (ii) institutionalisation of workforce systems (pre-service education, CPD, mentoring); and (iii) uptake of quality assurance, planning, and data systems at sub-national level.<br><br>Findings will inform course correction, prioritisation of remaining investments, and sustainability planning.<br><br>MSAT may be reapplied as relevant to assess progress in facility standards where appropriate. |
| End of project evaluation | **March 2031** (final project year) | **USD 20,000** (independent evaluation) | An independent end-of-project evaluation will assess relevance, effectiveness, efficiency, sustainability, equity, and system-level impact of the EHG project.<br><br>The evaluation will focus on whether governance, workforce, quality assurance, and enabling systems are institutionalised within government structures and likely to be sustained beyond project funding.<br><br>It will draw on monitoring data, policy and system changes, workforce outcomes, MSAT trends (where applied), and stakeholder perspectives across national and sub-national levels. |

## 4.3 Key Evaluation Questions

Based on the project's theory of change and logical framework, the following Key Evaluation Questions (KEQs) identify the high-level questions that will be answered at the mid-term and end-of-project stages. These questions are framed around recognised evaluation quality criteria and are designed to guide monitoring, learning, and evaluation throughout the project cycle.

Identifying these questions at the design stage ensures that appropriate data are collected during implementation. Some questions will be answered primarily through routine monitoring, while others will require targeted analysis through the mid-term review and/or final evaluation.

| Area | Key Evaluation Questions | Will be Answered Through |
|---|---|---|
| **Effectiveness** | To what extent is the Eye Health Governance (EHG) project achieving its intended objectives related to strengthened governance (government-led), coordination, workforce distribution and competency, quality assurance, and enabling systems at national and sub-national levels? | Monitoring;<br>Mid-term review;<br>Final evaluation |
| **Effectiveness** | To what extent have government-led coordination and stewardship mechanisms (e.g. TWGs, planning and supervision systems) become functional and institutionalised that led to improved planning, resource allocation, and implementation of eye health services at national and subnational levels during the project period?<br>To what extent has the eye health system transitioned from project-supported to government-led (in planning, financing, and implementation)? | Monitoring;<br>Mid-term review;<br>Final evaluation |
